# ដំណាំសាកវប្បកម្ម



រៀបរៀងដោយ ៖ លោកបណ្ឌិត Kim, IL Seop

បកប្រែជាភាសាខ្មែរដោយ ៖ លោកស្រី មាច សារី និង លោក ឈុន តូរី

២០២០

한국농어촌공사

KNU 강원대학교 KANGWON NATIONAL UNIVERSITY

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# មុខវិជ្ជា
# ដំណាំសាកវប្បកម្ម


**រៀបរៀង និងបកប្រែជាភាសាខ្មែរដោយ៖**

១. លោកស្រី មាច សារី ប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. លោក ឈុន តូរី សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

**ប្រឹក្សា និងត្រួតពិនិត្យដោយ៖**

បណ្ឌិត Kim, IL Seop សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យជាតិកាងវ៉ុននៃសាធារណរដ្ឋកូរ៉េ

**ពិនិត្យអក្ខរាវិរុទ្ធដោយ៖**

១. លោក ផាន ទូច ប្រធានការិយាល័យអប់រំផ្សព្វផ្សាយ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. លោក វ៉ាន់ ពុទ្ធី មន្ត្រីការិយាល័យអប់រំផ្សព្វផ្សាយនៃនាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



**គាំទ្រថវិកាដោយ** ៖ សារជីវកម្មសហគមន៍ជនបទកូរ៉េ នៃសាធារណរដ្ឋកូរ៉េ

**សហការរៀបចំដោយ៖** សាកលវិទ្យាលជាតិកាងវ៉ុន និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បោះពុម្ពលើកទី ១

ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# លិខិតថ្លែងអំណរគុណ

ក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងកសិកម្ម ស្បៀងអាហារ និងកិច្ចការជនបទនៃសាធារណរដ្ឋកូរ៉េ គម្រោងស្តីពី "ការគាំទ្រការសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មនៅកម្ពុជា" បានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៨-២០២២ ក្រោមការគាំទ្រថវិកាដោយរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដោយមាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការអនុវត្តជាមួយសារជីវកម្មសហគមន៍ជនបទកូរ៉េ ដែលមានការចូលរួមពីអ្នកជំនាញបច្ចេកទេសកសិកម្ម មកពីសាកលវិទ្យាល័យជាតិកាង៉រ៉ុន និងមន្រ្តីជំនាញពាក់ព័ន្ធមកពីអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទន្ទឹមនេះសៀវភៅបច្ចេកទេសចំនួន៥មុខមានដូចជា (១)ផលិតកម្មដំណាំស្រូវ និងបច្ចេកវិទ្យាក្រោយប្រមូលផល (២)ការផ្សព្វផ្សាយកសិកម្ម និងសហគ្រិនភាពកសិកម្ម (៣) ដំណាំសាកវប្បកម្ម (៤)ការធ្វើទីផ្សារកសិកម្ម (៥)ការប្រើប្រាស់ និងថែទាំគ្រឿងយន្តកសិកម្ម ត្រូវបានរៀបចំចងក្រង និងបោះពុម្ព ដែលនេះគឺជាផ្នែកមួយនៃការអនុវត្តគម្រោង។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការដឹកនាំប្រកបដោយភាពវៃឆ្លាតរបស់ឯកឧត្តម **វេង សាខុន** រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ តាមរយៈសារជីវកម្មសហគមន៍ជនបទកូរ៉េ និងសាកលវិទ្យាល័យជាតិកាំង៉រ៉ុន ដែលបានខិតខំប្រឹងប្រែងចូលរួមចំណែក ទាំងបច្ចេកទេស និងថវិកាក្នុងការរៀបចំ ចងក្រង និងបោះពុម្ពផ្សាយសៀវភៅបច្ចេកទេសទាំង៥មុខខាងលើនេះ ក្នុងគោលបំណងប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងផ្សព្វផ្សាយបន្ត ដើម្បីរួមចំណែកលើកកម្ពស់គុណភាព និងនវានុវត្តន៍ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្មនៅកម្ពុជា។

សៀវភៅបច្ចេកទេសទាំង៥មុខនេះ នឹងត្រូវប្រើប្រាស់ជាជំនួយស្មារតីដល់មន្រ្តី និងភ្នាក់ងារផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ហើយក៏ត្រូវបានប្រើប្រាស់ក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មតាស្នាង នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពបណ្តុះបណ្តាល បង្កើនសមត្ថភាព និងផ្ទេរចំណេះដឹងដល់អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធស្របទៅតាមតម្រូវការ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមថាសៀវភៅបច្ចេកទេសទាំងនេះ ពិតជាបានបម្រើដល់ផលប្រយោជន៍រួម ហើយបានប្រើប្រាស់ដោយទូលំទូលាយក្នុងវិស័យកសិកម្ម ទាំងអ្នកបច្ចេកទេស ភ្នាក់ងារផ្សព្វផ្សាយ អ្នកប្រើប្រាស់ ផលិតករ កសិករ និងសហគមន៍មូលដ្ឋាន។

ថ្ងៃ ព្រហ ១០ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២០

**ប្រធាននាយកដ្ឋាន**
**ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត ម៉ៅ មិនា**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basac, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥)២៣ ៩៦៥ ៤៤៣ អ៊ីមែល: deaff.maff@gmail.com, គេហទំព័រ: khmeragri.info
Phone : (855)23 965 443 Email: deaff.maff@gmail.com, Website: khmeragri.info

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ក្រ | = គីឡូក្រាម |
| ស.ម | = សង់ទីម៉ែត |
| ហ.ត | =ហិចតា |
| % | = ភាគរយ |
| cm | = Centimetre (សង់ទីម៉ែត) |
| m | = Metre (ម៉ែត) |
| nm | = Nanometre (ណាណូម៉ែត) |
| $m^2$ | = Square metre (ម៉ែតការ៉េ) |
| $m^3$ | = Cubic metre (ម៉ែតគីប) |
| $\mu$mol | = Micromole (មីក្រូម៉ុល) |
| pH | = Potential of Hydrogen (ថាមពលអ៊ីដ្រូសែន) |
| PE | = Poly Ethylene (ប៉ូលីអេទីឡែន) |
| CO2 | = Carbon dioxide (ឧស្ម័នកាបូនិច) |
| H2O | = Hydrogen Oxide (ទឹក) |
| PAR sensor | = Photosynthetically Active Radiation sensor |
| PVC | = Poly Vinyl Chloride (ប៉ូលី វីនីល ក្លរ៉ាយ) |

# សន្ទានុក្រម

- **សាកវប្បកម្ម** : គឺជាការអនុវត្តការដាំដុះដំណាំបន្លែ ដំណាំផ្លែឈើ និង ដំណាំលម្អ។
- **ផ្ទះបៃតង** : គឺជាសំណង់ដែលផ្គុំឡើងដោយដំបូលនិងជញ្ជាំងដែលអាចឲពន្លឺចេញចូលបាន។ ផ្ទះបៃតងរួមមាន ផ្ទះកញ្ចក់ ផ្ទះប្លាស្ទិក និង ផ្ទះសំណាញ់ផ្សេងៗ
- **បរិស្ថានពន្លឺ** : គឺជាកត្តាពន្លឺដែលជះឥទ្ធិពលលើការលូតលាស់ដំណាំ។
- **បរិស្ថានសីតុណ្ហភាព** : គឺជាកត្តាសីតុណ្ហភាពដែលជះឥទ្ធិពលលើការលូតលាស់ដំណាំ។
- **បរិស្ថានសំណើម** : គឺជាកត្តាសំណើមដែលជះឥទ្ធិពលលើការលូតលាស់ដំណាំ។
- **pHដី** : គឺជាការបង្ហាញនៃសារធាតុអាស៊ីតនិងអំបិលរបស់ដី។
- **រស្មីសំយោគ** : គឺជាដំណើរដែលរុក្ខជាតិបៃតងបំលែងថាមពលពន្លឺទៅជាថាមពលគីមី។
- Hydroponics (**អ៊ីដ្រូប៉ូនិច**) :គឺជាការដាំដុះដំណាំជាពិសេសដំណាំបន្លែនៅលើទឹកដែលមានសារធាតុចិញ្ចឹម។
- Sensor(**សេនសឺ**) : ជាឧបករណ៍តាមដានវាស់សីតុណ្ហភាព សំណើម ពន្លឺ និង ឧស្ម័នផ្សេងៗ។

# មាតិកា


## សេចក្តីផ្តើម

## មេរៀនទី១ ប្រភេទ និងទម្រង់នៃផ្ទះបៃតង

១.១ អត្ថប្រយោជន៍ និងស្ថានភាពរបស់សាកវប្បកម្ម .......... 2

១.២ ប្រភេទផ្ទះបៃតង .......... 2

១.២.១ ផ្ទះបៃតងស្លាបទោល .......... 2

១.២.២ ផ្ទះបៃតងមានស្លាបច្រើន .......... 4

១.២.៣ ផ្ទះកញ្ចក់ .......... 5

១.២.៤ ផ្ទះប្លាស្ទិក .......... 6

១.៣ មូលដ្ឋានគ្រឹះផ្ទះបៃតង .......... 9

## មេរៀនទី២ ប្រភេទ និងលក្ខណៈសម្ភារនៅក្នុងផ្ទះបៃតង

២.១ សម្ភារគ្រោងឆ្អឹង .......... 11

២.២ សម្ភារដែលគ្រប់គ្រងបរិស្ថាន

២.២.១ ប្រភេទ និងលក្ខណៈសម្ភារស្រោចស្រព .......... 12

២.២.២ ប្រភេទ និងលក្ខណៈនៃប្រព័ន្ធធ្វើឱ្យត្រជាក់ .......... 14

២.២.៣ ឧបករណ៍បង្កើតសំណើម និង បំបាត់សំណើម .......... 20

២.២.៤ ប្រភេទ និងការប្រើប្រាស់ Sensor សម្រាប់ត្រួតពិនិត្យបរិស្ថាន .......... 21

២.៣ សម្ភាររុំ .......... 28

២.៣.១ គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទកញ្ចក់ .......... 28

២.៣.២ គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទប្លាស្ទិច .......... 29

## មេរៀនទី៣ ការគ្រប់គ្រងបរិស្ថានដាំដុះក្នុងផ្ទះបៃតង

៣.១ បរិស្ថានពន្លឺ .......... 31

៣.១.១ បរិស្ថានពន្លឺ និងការលូតលាស់ដំណាំ .......... 31

៣.១.២ លក្ខណៈបរិស្ថានពន្លឺនៅក្នុងផ្ទះបៃតង .......... 33

៣.១.៣ ការកែលម្អបរិស្ថានពន្លឺនៅក្នុងផ្ទះបៃតង .......... 34

៣.២ បរិស្ថានសីតុណ្ហភាព និងសំណើម .......... 36

៣.២.១ បរិស្ថានសីតុណ្ហភាព និងការលូតលាស់ដំណាំ .......... 37

៣.២.២ លក្ខណៈសីតុណ្ហភាព និងសំណើមនៅក្នុងផ្ទះបៃតង .......... 40

៣.២.៣ ការបញ្ចេញបញ្ចូលខ្យល់ និងទ្រនាប់កម្ដៅ ..... 43
៣.៣ បរិស្ថានទឹក និងដី ..... **47**
៣.៣.១ បរិស្ថានទឹក និងការលូតលាស់ដំណាំ ..... 47
៣.៣.២ លក្ខណៈបរិស្ថានទឹកក្នុងផ្ទះបៃតង ..... 47
៣.៣.៣ ការគ្រប់គ្រងសំណើម និងការស្រោចស្រព ..... 48
៣.៤. លក្ខណៈបរិស្ថានដី ..... **50**
៣.៤.១ បរិស្ថានដី និង ការលូតលាស់ដំណាំរ ..... 50
៣.៤.២ លក្ខណៈ និង ការគ្រប់គ្រងដីក្នុងផ្ទះបៃតង ..... 50
៣.៤.៣ វិធានការណ៍ការពារការកើតឡើងសារធាតុអំបិល ..... 53
**មេរៀនទី៤. ការដាំដំណាំក្នុងប្រព័ន្ធ អ៊ីដ្រូប៉ូនិច**
៤.១ ប្រភេទ និងលក្ខណៈ អ៊ីដ្រូប៉ូនិច (Hydroponics) ..... **55**
៤.១.១ សារធាតុចិញ្ចឹម ..... 55
៤.១.២ ការស្រោចស្រពប្រើប្រាស់ដំណក់ទឹកតូចៗ ..... 55
៤.១.៣ ប្រព័ន្ធដាំដុះដោយប្រើប្រាស់សារធាតុចិញ្ចឹមតាមបំពង់ទុយោ ..... 56
៤.១.៤ ប្រព័ន្ធដាំដុះដោយប្រើបច្ចេកទេសទឹកជ្រៅ ..... 57
៤.២ ប្រភេទ និងលក្ខណៈសារធាតុចិញ្ចឹម ..... **58**
៤.២.១ សំឡីថ្ម ..... 59
៤.២.២ ស្រកីដូង ..... 60
៤.២.៣ ប៉េលីត ..... 61
៤.២.៤ ដីខ្សាច់ ..... 61
៤.៣ ការគ្រប់គ្រងការស្រោចស្រព ..... **62**
៤.៣.១ ការផ្គត់ផ្គង់ និងការបង្ហូរសំងួត ..... 62
៤.៣.២ ការបកស្រាយទិន្នន័យ និងវិធីសាស្ត្រប្រើប្រាស់ ..... 63
៤.៤ សមាសធាតុសារធាតុចិញ្ចឹម និងការគ្រប់គ្រង ..... **64**
៤.៤.១ លក្ខណៈសារធាតុចិញ្ចឹម ..... 64
៤.៤.២ ទំនាក់ទំនងពិសេសរវាងធាតុ និងធាតុ ..... 65
**មេរៀនទី៥ បច្ចេកទេសដំណាំយកផ្លែ**
៥.១ ដំណាំប៉េងប៉ោះ ..... **67**
៥.១.១ ប្រភព ..... 67

៥.១. ២ លក្ខណៈសរីរ និងជីវសាស្ត្រ ........ 67
៥.១.៣ ភាពមិនប្រក្រតី ជម្ងឺ និងសត្វល្អិត ........ 70
**៥.២. ស្ត្របឺរី ........ 70**
៥.២.១ ប្រភព ........ 70
៥.២.២. ការផលិតកូនស្ត្របឺរីដែលមានគុណភាពល្អ ........ 72
**៥.៣.ដំណាំឪឡឹក ........ 72**
**៥. ៤. ដំណាំត្រសក់ ........ 74**
**៥.៥.ដំណាំម្ទេស ........ 78**
**៥.៦. ដំណាំត្រប់ ........ 81**
**មេរៀនទី៦ បច្ចេកទេសដាំបន្លែស្លឹក និងបន្លែមើម**
**៦.១ បច្ចេកវិទ្យាបណ្តុះកូនដំណាំ( *Plug nursery technology*) ........ 86**
**៦.១.២ បច្ចេកវិទ្យាដាំដុះដោយដំណាំ *(Cultivation technology by crop)* ........ 86**
**៦.២ លក្ខណៈសរីរវិទ្យា និងអេកូឡូស៊ីនៃដំណាំដំណាំខ្ទឹមសស្ពៃបូកគោ ........ 93**
**៦.៣ ការ៉ុត ........ 94**
**៦.៤ សាឡាត់ ........ 94**
**៦.៥ ខ្ទឹមស ........ 95**
៦.៦ ស្ពៃក្តោប ........ 95
៦.៧ ការ៉ុត ........ 97
៦.៨ សាឡាត់ ........ 98
៦.៩ ខ្ទឹមស ........ 98

# សេចក្តីផ្តើម

ផ្ទះបៃតង (រួមមាន ផ្ទះកញ្ចក់ ផ្ទះប្លាស្ទិក និងផ្ទះសំណាញ់ផ្សេងៗ) គឺជាសំណង់ដែលផ្គុំឡើងដោយដំបូលនិងជញ្ជាំងដែលអាចឲពន្លឺចេញចូលបាន។ ទំហំផ្ទះបៃតងប្រែប្រួលពីតូចទៅធំ(លក្ខណៈឧស្សាហកម្ម)។ នៅខាងក្នុងផ្ទះបៃតងដែលត្រូវពន្លឺព្រះអាទិត្យជាទូទៅមានសីតុណ្ហភាពខ្ពស់ជាងខាងក្រៅផ្ទះបៃតង។ ផ្ទះកញ្ចក់ដែលមានពាណិជ្ជកម្មជាច្រើនគឺជាសំណង់ផលិតកម្មដែលប្រើប្រាស់បច្ចេកវិទ្យា ទំនើបសំរាប់ផលិតកម្មបន្លែ ផ្លែឈើ និង ដំណាំលម្អ។ នៅក្នុងប្រទេសដែលមានអាកាសធាតុត្រជាក់ផ្ទះកញ្ចក់ទាំងនេះបំពាក់ទៅដោយឧបករណ៍ និងសម្ភារមួយចំនួនដូចជា៖ ម៉ាស៊ីនកម្តៅ ម៉ាស៊ីនត្រជាក់ ភ្លើងអគ្គិសនី ហើយប្រហែលជាគ្រប់គ្រងដោយប្រព័ន្ធកុំព្យូទ័រផងក្នុងបង្កើតលក្ខខណ្ឌល្អសំរាប់ការលូតលាស់ដំណាំ។ ចំណែកនៅក្នុងប្រទេសកម្ពុជាយើងវិញ ការប្រើប្រាស់ផ្ទះបៃតងទើបតែចាប់ផ្តើមបន្តើរៗ។ យើងសង្កេតឃើញកសិករ រឺ អ្នកផលិតដំណាំប្រើប្រាស់ផ្ទះបៃតងដែលប្រក់សំណាញ់ និង ប្លាស្ទិកសំរាប់ដាំបន្លែ ដូចជា៖ សាលាដ៏ ស្ពៃខៀវ ស្ពៃក្រញាញ់ ស្ពៃតឿ...ជាដើម។

# មេរៀនទី១ ប្រភេទ និងទម្រង់នៃផ្ទះបៃតង

## ១.១ អត្ថប្រយោជន៍ និងស្ថានភាពរបស់សាកវប្បកម្ម

- ផ្ទះបៃតង (ផ្ទះកញ្ចក់ និងផ្ទះប្លាស្ទិច)អាចដាំដំណាំសាកវប្បកម្មបានច្រើនប្រភេទប្រចាំឆ្នាំ ពីព្រោះគេអាចគ្រប់គ្រងកត្តាបរិស្ថានបានដោយសិប្បនិម្មិត (ដូចជាកត្តាអាកាសធាតុ និងដី)
- បច្ចេកវិជ្ជាកសិកម្មមានតួនាទីយ៉ាងសំខាន់រហូតដល់ពេលនេះហើយការគ្រប់គ្រងបរិស្ថានផ្តោតសំខាន់ទៅលើដី ប៉ុន្តែនៅមានកម្រិតនៅឡើយចំពោះការកែលម្អផលិតកម្មតាមរយៈការប្រើប្រាស់ថាមពល
- ផ្ទះបៃតងអាចបង្កើតផលិតកម្មដំណាំតាមរយៈការបង្កើតទីតាំងថ្មី ទាន់ពេលវេលា និងទំហំដី ហើយវាអាចឱ្យគេដាំដំណាំប្រចាំឆ្នាំ និងដាំដំណាំនៅជុំវិញពិភពលោក
- កម្រិតចំណូលរបស់អ្នកប្រើប្រាស់អាចកំណត់ពីតំណាក់កាលអភិវឌ្ឍន៍នៃសាកវប្បកម្ម។

## ១.២ ប្រភេទផ្ទះបៃតង

### ១.២.១ ផ្ទះបៃតងស្លាបទោល

❖ **លក្ខណៈផ្ទះបៃតង**

- សមត្ថភាពផ្ទះបៃតង៖ នៅក្នុងករណីមានផ្ទះបៃតងស្លាបទោលពីរនៅក្នុងទីតាំងតែមួយ ត្រូវឱ្យមានទីធ្លាចន្លោះសមស្របរវាងផ្ទះបៃតងទៅផ្ទះបៃតងមួយទៀត។ ដូច្នេះផ្ទៃដីសម្រាប់សាងសង់នៅតិចតួច
- ការវិនិយោគចំណាយតិចតួច
- ជាទូទៅវាមានកម្រិតទាប
- សង់បែរមុខទៅទិសខាងកើត
- គ្មានខ្យល់ចេញចូល ឬទុកឱ្យចន្លោះខ្យល់ចូលតិចតួច
- ផ្ទះបៃតងនេះវាអាស្រ័យលើខ្យល់ចេញចូលនៅផ្នែកដំបូលដែលមានរាងត្រីកោណ
- វាមានការពិបាកក្នុងការប្រើប្រាស់ឧបករណ៍សម្រាប់ផ្ទះបៃតងប្រភេទនេះ

❖ **លក្ខណៈបរិស្ថាន**

- មានការប្រែប្រួលយ៉ាងខ្លាំងអាស្រ័យទៅលើប្រវែងផ្ទះបៃតង
- មានពន្លឺគ្រប់គ្រាន់
- មានម្លប់តិចតួច
- ពិបាកធ្វើឱ្យមានម្លប់
- ការផ្លាស់ប្តូរសីតុណ្ហភាព និងសំណើមនៅពេលថ្ងៃមានការប្រែប្រួលខ្លាំង
- ទ្រនាប់ទប់កម្តៅមានកម្រិតទាប
- សីតុណ្ហភាពកើនឡើងលឿនបន្ទាប់ពីថ្ងៃរះ (ជាពិសេសរដូវក្តៅ) ហើយសីតុណ្ហភាពថយចុះលឿនបន្ទាប់ពីថ្ងៃលិច (រដូវត្រជាក់)
- ខ្យល់ចេញចូលមិនទៀងទាត់
- ការលូតលាស់ដំណាំក៏មិនទៀងទាត់

### ❖ លក្ខណៈលូតលាស់ដំណាំ

- អាចដាំដុះដំណាំភាគច្រើនតែដំណាំរយៈពេលខ្លី
- នៅក្នុងរដូវត្រជាក់ការលូតលាស់ដំណាំអត់ល្អនៅផ្នែកខាងៗ (ដោយសារតែសីតុណ្ហភាពទាប) នៅក្នុងរដូវក្តៅការលូតលាស់មិនល្អនៅផ្នែកកណ្តាលផ្ទះបៃតង(ដោយសារតែសីតុណ្ហភាពក្តៅពេក)
- មានទឹក និងជំងឺជ្រៀតចូលពីខាងក្រៅ
- ជំងឺកើតចេញពីដីមានសភាពធ្ងន់ធ្ងរនៅផ្នែកខាងៗ
- មានការពិបាកក្នុងការរារាំងកត្តាចង្រៃដែលហើរចូលក្នុងផ្ទះបៃតង



**រូបភាពទី១៖** ប្រភេទផ្ទះបៃតងដែលមានដំបូលអាចឱ្យខ្យល់ចេញចូលបាន



**រូបភាពទី២៖** ផ្ទះបៃតងដែលមានដំបូលទោល(លក្ខណៈគ្រួសារ)

### ១.២.២ ផ្ទះបៃតងមានស្លាបច្រើន

❖ **លក្ខណៈផ្ទះបៃតង**

- ផ្ទៃដីមានទំហំធំទូលាយៈ មិនមានផ្លូវសម្រាប់ដើរនៅចំកន្លែងផ្ទះបៃតងសង់ជាប់គ្នា។ដូច្នេះការប្រើប្រាស់ដីកើនឡើង
- នៅក្នុងករណីដែលផ្ទះបៃតងសង់ឡើងជាប់គ្នា និងក្នុងទម្រង់ដូចគ្នា វាមិនចាំបាច់សាងសង់ជញ្ជាំងទេ គឺប្រើជញ្ជាំងរួមដូច្នេះការសាងសង់កាត់បន្ថយការចំណាយ
- កម្ពស់របស់ផ្ទះបៃតងៈក្នុងករណីផ្ទះបៃតងច្រើនមានទីតាំងតែមួយ ជាទូទៅកន្លែងដែលជាប់គ្នាត្រូវតែ គ្របដណ្ដប់ផ្នែកខាងក្រៅសន្ទះបិទបើកខ្យល់ចេញចូលមួយ ដូច្នេះប្រវែងទទឹងរបស់ផ្ទះបៃតងគឺទូលាយហើយកម្ពស់របស់ផ្ទះបៃតងក៏ខ្ពស់ដែរ
- ត្រូវការវិនិយោគច្រើន
- មានការពិបាកបម្លាស់ដីៈ វាមានការពិបាកក្នុងការរំកិលផ្ទះបៃតងពីកន្លែងមួយទៅកន្លែងមួយដោយសារតែគេសង់ជាប់ៗគ្នាច្រើន
- ប្រសិទ្ធិភាពនៃការប្រើប្រាស់ដីមានកម្រិតខ្ពស់
- ទិសសម្រាប់សាងសង់ផ្ទះបៃតងគួរតែពីជើងទៅត្បូង ហើយការបែងចែកពន្លឺគួរតែមានភាពស្មើៗគ្នា
- ត្រូវឱ្យមានទទឹក (សម្រាប់បង្ហូរទឹក)
- ត្រូវមានស្រទាប់ការពារកម្ដៅ
- ប្រើប្រាស់ឧបករណ៍ដែលមានប្រសិទ្ធិភាពខ្ពស់។ ប្រើប្រាស់កម្តៅតិចជាង ផ្ទះបៃតងស្លាបទោល
- ប្រើប្រាស់ឧបករណ៍ឱ្យបានសមរម្យៈ ដោយសារតែវាមានទំហំទូលាយ វាគួរមានទីធ្លាគ្រប់គ្រាន់ដើម្បី ដាក់ឧបករណ៍ឱ្យបានសមស្របដូចជាឧបករណ៍ដាំដុះ
- ផ្ទះបៃតងប្រភេទនេះ មានទីធ្លាទូលាយ ផ្នែកខាងក្នុងដែលបង្កលក្ខណៈងាយស្រួលសម្រាប់ដំណើរឧបករណ៍ស្វ័យប្រវត្តិ
- ងាយទទួលផលវិបាកចំពោះការធ្លាក់ព្រិលទឹកកកៈ ពីព្រោះព្រិលទឹកកកគរលើគ្នានៅផ្នែកដំបូលចុង ស្រួចជាផ្នែកតភ្ជាប់គ្នាទៅផ្ទះបៃតងផ្សេងទៀត ដូច្នេះ គួរតែសាងសង់សសរឆ្អឹងឱ្យបានមាំ ហើយគួរមានឧបករណ៍រំលាយព្រិលទឹកកកនៅត្រង់កំពូលដំបូល។ ដូច្នេះនៅពេលមានព្រិលខ្លាំង ត្រូវបើកឧបករណ៍កម្តៅដើម្បីឱ្យព្រិលទឹកកករលាយបានលឿន ។

❖ **លក្ខណៈបរិស្ថាន**

- មិនមានការប្រែប្រួលសីតុណ្ហភាពខ្លាំងពេញមួយថ្ងៃ
- ពន្លឺមិនស្មើៈ មានពពុះទឹកនៅផ្នែកដំបូលហើយពន្លឺត្រូវបានរារាំងពីព្រោះពពុះទឹករារាំងពន្លឺ។ ដោយសារតែបរិមាណពន្លឺចូលបានតិចដូច្នេះគេគួរប្រើឧបករណ៍ ឬសម្ភារជំនួយពន្លឺដូចជា ក្រដាសហ្វឹមចាំងផ្លាត ដើម្បីឱ្យពន្លឺចូលទៅក្នុងផ្ទះបៃតងបានគ្រប់ទីកន្លែង
- ឧបសគ្គនៃខ្យល់ចេញចូលៈ ខ្យល់ចេញចូលមិនគ្រប់គ្រាន់ដោយសារតែទំហំផ្ទៃផ្ទះបៃតងធំ។ ដូច្នេះការប្រើប្រាស់កង្ហារបន្ថែម បូករួមផ្សំជាមួយខ្យល់ចេញចូលធម្មជាតិ តាមរយៈការដាក់កញ្ចក់ដើម្បីផ្តល់ពន្លឺ

នៅដំបូល។ នៅក្នុងករណីផ្ទះបៃតងដែលសាងសង់ឡើងជាប់ៗរដឹក គេត្រូវធ្វើឱ្យមានខ្យល់ចេញចូលពីផ្នែកខាងដំបូល

- គេគួរគិតថា ការចេញចូលខ្យល់គឺមានការលំបាកហើយសំណើម និងសីតុណ្ហភាពកើនឡើង។ ដូច្នេះ ត្រូវប្រើប្រាស់កង្ហារ។

❖ **លក្ខណៈដាំដុះ**

- ដាំដុះដំណាំភាគច្រើនដែលមានអាយុកាលយូរ
- កុំឱ្យមានទឹកហូរចូលផ្ទះបៃតងពីខាងក្រៅ
- ការដាំដុះឱ្យបានសមស្រប: ក្នុងករណីផ្ទះបៃតងរបស់ Dangdong, ផ្លូវដើរក្នុងផ្ទះបៃតងប៉ះពាល់ដល់ការដាំដុះប៉ុន្តែផ្ទះបៃតងដែលជញ្ជាំងរួមគ្នាគ្មានផ្លូវសម្រាប់ដើរទេ។ ប្រសិទ្ធិភាពការងារមានកម្រិតខ្ពស់
- កម្លាំងពលកម្ម: វាជាការងាយណាស់ក្នុងការជួលកម្លាំងពលកម្មខាងក្រៅ ពីព្រោះមានលក្ខណៈបរិស្ថានប្រសើរជាងផ្ទះបៃតងប្រភេទ Dangdong ។



**រូបភាពទី៣៖** ផ្ទះបៃតងពហុស្លាបនៅក្នុងប្រទេសកូរ៉េ

### ១.២.៣ ផ្ទះកញ្ចក់

❖ **ប្រភេទផ្ទះកញ្ចក់**

- មានដំបូលសងខាង: ជាប្រភេទផ្ទះកញ្ចក់ទូទៅដែលងាយស្រួលពង្រីកទំហំ ហើយទទឹងរបស់វាអាចប្រែប្រួល។ ពន្លឺមានបរិមាណដូចគ្នានៅក្នុងផ្ទះកញ្ចក់ប្រភេទនេះ ហើយខ្យល់ចេញចូលមានលក្ខណៈល្អ ប៉ុន្តែមានហានិភ័យចំពោះការធ្លាក់ព្រិលទឹកកក
- ដំបូលទម្រង់៣/៤: ជាប្រភេទផ្ទះកញ្ចក់ដែលផ្សំពីដំបូលសងខាង និងប្រភេទដំបូលខាងក្រៅ។ ផ្ទះកញ្ចក់ប្រភេទនេះសមស្របសម្រាប់ដំណាំដែលត្រូវការសីតុណ្ហភាពខ្ពស់ ពីព្រោះវាអាចជ្រាបពន្លឺបានល្អនៅរដូវរងា និង ផ្តល់សីតុណ្ហភាពក្តៅល្មម
- ផ្ទះកញ្ចក់ទម្រង់គន្លងជួរ: វាមានកម្ពស់ស្មើៗគ្នា ហើយអាចបង្កើនផ្ទៃដីសម្រាប់ដាំដុះ។ ផ្ទះកញ្ចក់ប្រភេទនេះធ្វើឱ្យលូតលាស់ល្អនៅពេលសីតុណ្ហភាពក្តៅល្មម វាអាចកាត់បន្ថយចំណាយ លើការសាងសង់និង

ជួយពង្រឹងសមត្ថភាពការងារ។ ប៉ុន្តែការចែកចាយពន្លឺមិនបានស្មើហើយខ្យល់ចេញចូលក៏មិនល្អ។ ជាងនេះទៅទៀត វាមិនសូវអន់ទ្រាំទៅនឹងទម្ងន់ព្រិលទឹកកក

- ផ្ទះកញ្ចក់ប្រភេទ (Venlo): ជាប្រភេទផ្ទះកញ្ចក់ដែលភ្ជាប់ដំបូលគ្នាដែលមានសំយ៉ាបខ្ពស់ហើយទទឹងខ្លី ទម្រង់ប្រភេទនេះជួយកាត់បន្ថយការចំណាយលើការសាងសង់តាមរយៈការប្រើប្រាស់គ្រោងឆ្អឹងតិច ហើយជួយ ជម្រុញឱ្យមានពន្លឺចូលទៅក្នុងផ្ទះកញ្ចក់
- ប្រភេទដំបូលហុលឡុង: វាជាប្រភេទផ្ទះកញ្ចក់ដែលមានដំបូលសងខាង។ ដំបូលខាងនីមួយៗមិនជ្រែងទៅនឹងជញ្ជាំងទេ ប៉ុន្តែវាជ្រាលទៅខាងក្រៅបន្តិចដែលធ្វើសមត្ថភាពទប់លំនឹងរបស់ផ្ទះកញ្ចក់មានឱ្យមានភាពរឹងមាំអាច ទប់នឹងកម្លាំងខ្យល់ខ្លាំងបាន
- ប្រភេទដំបូលកោង(Curved roof): ផ្ទះកញ្ចក់ប្រភេទនេះគេឃើញមានច្រើនក្នុងឧទ្យានរុក្ខជាតិ។




**រូបភាពទី៤៖** ប្រភេទដំបូលផ្ទះកញ្ចក់ដែលមានរាងខុសៗគ្នា

### ១.២.៤ ផ្ទះប្លាស្ទិក

❖ **ប្រភេទផ្ទះបៃតងប្លាស្ទិក**

- ផ្ទះបៃតងរាងTunnel: រាងពាក់កណ្ដាលរង្វង់គ្មានសំយ៉ាបលយចេញ។ វាទប់កម្ដៅបានខ្លាំងធន់ទ្រាំនឹងកម្លាំងខ្យល់ខ្លាំង ហើយអាចចែកចាយពន្លឺបានស្មើ ប៉ុន្តែខ្យល់ចេញចូលមិនសូវល្អ
- ប្រភេទផ្ទះបៃតងប្លាស្ទិកដំបូល: ជាប្រភេទផ្ទះបៃតងមានស្លាបច្រើន មានគ្រោងឆ្អឹងរឹង
- ផ្ទះបៃតងប្លាស្ទិចរាងកោង: ផ្ទះបៃតង ប្រភេទនេះគេសង្កេតឃើញមានច្រើននៅប្រទេសកូរ៉េ។ ផ្ទះប្រភេទនេះមានដំបូលរាងកោងហើយជ្រែងទៅនឹងជញ្ជាំង



**រូបភាពទី៥៖** ប្រភេទផ្ទះបៃតងប្លាស្ទិករាងរូងភ្នំ(Tunnel)



**រូបភាពទី៦៖** ការដាំដុះដោយប្រើប្រាស់គម្របប្លាស្ទិក



**រូបភាពទី៧៖** ការដាំដុះដោយប្រើប្រាស់គម្របប្លាស្ទិក



**រូបភាពទី៨៖** ដំបូលមូលដែលអាចឱ្យខ្យល់ចេញចូល



ដំបូលរាងត្រីកោណ　　ដំបូលរាងរូងភ្នំ　　ដំបូលរាងកោង

**រូបភាពទី៩៖** ប្រភេទដំបូលផ្ទះបៃតង



រាងកោងមានស្លាប២



រាងកោងមានស្លាប៣



ដំបូលរាងកោងមានស្លាបច្រើន(១-២w)



រាងកោងទូលាយមានស្លាបទោល



រាងកោងមានស្លាបទោល



ស្លាបទោលរាងស្មើ

**រូបភាពទី១០៖** ប្រភេទដំបូលផ្ទះបៃតង (ប្រក់ដោយប្លាស្ទិក)

### ១.៣ មូលដ្ឋានគ្រឹះផ្ទះបៃតង

❖ **ទម្រង់គ្រឹះផ្ទះបៃតង**

- មូលដ្ឋានគ្រឹះ : ការងារចាក់គ្រឹះសំណង់គ្រោងឆ្អឹងដែកបង្គួចអាលុយមីញ៉ូម និងសំណង់កញ្ចក់ទរ និងប្រពន្ធ័បង្ហូរទឹក ឧបករណ៍បិទបើក (Tunnel) ឧបករណ៍បិទបើកជញ្ជាំង ឧបករណ៍បាំងជញ្ជាំង ឧបករណ៍បញ្ចេញ បញ្ចូលខ្យល់ ប្រពន្ធ័ចរន្តអគ្គិសនី
- ឧបករណ៍ និងសម្ភារគ្រឹះ : វាំងនន(របាំងពន្លឺ) ម៉ាស៊ីនកម្តៅ ឧបករណ៍គ្រប់គ្រងចរន្តអគ្គិសនី
- ឧបករណ៍ផ្សេងទៀតៈ ម៉ាស៊ីនបញ្ចេញខ្យល់ក្តៅ ម៉ាស៊ីនបាញ់ថ្នាំ ម៉ាស៊ីនសម្អាតដី កង្ហារធំ អំពូលភ្លើងធំ ម៉ាស៊ីនត្រជាក់។ល។

❖ **ទម្រង់មូលដ្ឋានគ្រឹះរបស់ផ្ទះបៃតងប្លាស្ទិក**

- ការប្រៀបធៀបលក្ខណៈផ្ទះបៃតងមានដំបូលទាល និងរាងត្រីកោណ។

**តារាងទី១៖** ការប្រៀបធៀបលក្ខណៈរវាងផ្ទះបៃតងដំបូលកោង និងដំបូលត្រីកោណ

| លក្ខណៈ | ដំបូលកោង | ដំបូលត្រីកោណ |
|---|---|---|
| ភាពធន់ទ្រាំ | ធន់ទ្រាំ និងខ្យល់ខ្លាំង, ខ្សោយក្នុងទឹកកកព្រិល | ធន់នឹងព្រិលទឹកកក, ខ្សោយនឹងខ្យល់ |
| ខ្យល់ ចេញចូល | មានលទ្ធភាពរមូល | ខ្យល់ចេញចូលតាមដំបូល និងជញ្ជាំង |
| ទម្រង់ឆ្អឹង | ប្រើបំពង់ទីបជាចំបង | ប្រើបំពង់ទីប និងដែករាងអក្សរ C |
| ការចំណាយ | ចំណាយតិច | ចំណាយច្រើន |
| ទំហំ | ទំហំផ្ទះតូច | ទំហំផ្ទះធំ |

❖ **ផ្ទះបៃតងពហុស្លាបស្វ័យប្រវត្តិ**

- ទំហំស្តង់ដាៈ ទទឹង២១ម (៧ម×ស្លាប៣), បណ្តោយ៥០ម ដូច្នេះមានផ្ទៃក្រលា ១០៥០ម២, កម្ពស់សំយ៉ាប ២,៨ម, កម្ពស់ដំបូល ៤,៧ម
- មូលដ្ឋានគ្រឹះសំណង់ៈ សំណង់ឆ្អឹង, ក្រណាត់គ្របសំណង់, ឧបករណ៍បើក/បិទ,ក្រណាត់វាំងនន
- ឧបករណ៍ផ្សេងៗទៀតៈ ប្រព័ន្ធទឹក និងកម្តៅឧបករណ៍បង្កើតឧស្ម័នកាបូនិច ឧបករណ៍គ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទំនើប។

❖ **ប្រភេទទម្រង់ផ្ទះបៃតង**

- សម្ភារគ្រោងឆ្អឹងៈ ឈើ, ដែក, សម្ភារដែលលាយជាមួយឈើ, សម្ភារអាលុយមីញ៉ូម
- ស្ថេរភាពៈ សំណង់ត្រឹមត្រូវ, សំណង់ខុសប្រក្រតី
- គ្រោងឆ្អឹងទប់ៈ គ្រោងឆ្អឹងផ្គុំឡើងដោយបន្ទះដែលត្រង់ៗ ជាច្រើនដែលតម្រៀបជារាងត្រីកោណមួយ ឬច្រើនហើយតភ្ជាប់គ្នាទៅវិញទៅមក។



**រូបភាពទី១១៖** គ្រោងឆ្អឹងដែកសម្រាប់ដំបូលត្រីកោណ

# មេរៀនទី២ ប្រភេទ និងលក្ខណៈសម្ភារនៅក្នុងផ្ទះបៃតង

## ២.១ សម្ភារគ្រោងឆ្អឹង

❖ **ឈើ**

- វាងាយស្រួលរកបានពីព្រោះវាជាសម្ភារដែលគេប្រើប្រាស់ជាទូទៅនៅផ្ទះបៃតង និងផ្ទះបៃតងប្លាស្ទិក
- ជាសម្ភារសមស្របពីព្រោះវាមានតម្លៃថោកសម្រាប់សាងសង់ ងាយរកទិញហើយងាយយកវាទៅកែច្នៃ
- ប៉ុន្តែវាងាយបាក់បែក និងងាយពុកផុយ ដូច្នេះវាមិនជាប់បានយូរទេ ហើយថ្មីៗនេះគេកម្រប្រើវាសម្រាប់សាង សង់ផ្ទះបៃតង។

❖ **ឫស្សី**

- នៅក្នុងដំណាក់កាលដាំដុះដំបូង នៅក្នុងប្រទេសកូរ៉េ បំពង់ឫស្សីត្រូវបានគេសូកបញ្ចូលទៅក្នុងជញ្ជាំងសងខាង ហើយខាងចុងបំពង់ឫស្សីត្រូវបត់ជារាងរូងភ្នំ(Tunnel)
- វាអាចប្រើបានរយៈពេលប្រហែល ៣ឆ្នាំ ប្រសិនបើឫស្សីទាំងនេះត្រូវបានប្រមូលផលចាប់ពីខែវិច្ឆិកាដល់ខែធ្នូ។

❖ **ដែក**

- សម្ភារគ្រោងឆ្អឹងដែកចែកចេញជាកំណាត់ដែក និងបំពង់ទីប
- ទម្រង់ដែក (ទម្រង់ផ្សេងៗ)ត្រូវបានគេប្រើជាគ្រឿងផ្សំសម្រាប់សាងសង់ផ្ទះបៃតងឬសាងសង់ដំបូលផ្ទះ គ្រឿងផ្សំទាំងនេះរួមមាន បន្ទះដែកអក្សរ H បន្ទះដែកអក្សរ L បន្ទះដែកអក្សរ U និងបន្ទះដែករាងការ៉េ
- បំពង់ទីបត្រូវ បានគេប្រើជារឿយៗ សម្រាប់ជាសម្ភារគ្រោងឆ្អឹង សម្រាប់សាងសង់ផ្ទះបៃតងប្លាស្ទិកដំបូលកោង
- បន្ទះដែកស្តើងអាចបត់បាន ហើយខ្លាំងមាំប្រសិនបើទម្ងន់ដូចគ្នាជាមួយបន្ទះដែករាង H និង L
- ប៉ុន្តែវាងាយច្រេះចាប់នៅក្នុងលក្ខខណ្ឌក្តៅ ហើយមានសំណើមខ្ពស់សម្ភារលោហៈស្រាល
- លោហៈស្រាលៗមានប្រភេទផ្សេងៗដែលសំខាន់ផលិតចេញពីអាលុយមីញ៉ូម។ លោហៈទាំងនេះត្រូវបានគេកំណត់លក្ខណៈថាមានទម្ងន់ស្រាលប៉ុន្តែមិនច្រេះចាប់ទេ
- វាអាចមានទម្ងន់ស្រាល និងទំហំតូច ដូច្នេះ វាអាចបង្កើនការបញ្ជូនពន្លឺហើយអាចកាត់បន្ថយការប្រើប្រាស់គ្រោងឆ្អឹង។



**រូបភាពទី១២៖** បំពង់ទីប

ទោះបីលោហៈស្រាល ឬអាលុយមីញ៉ូមនេះមានកម្លាំងខ្សោយជាង និងតម្លៃថ្លៃជាងដែកក៏ដោយប៉ុន្តែវាអាច បំពេញគ្នាទៅវិញទៅមក នៅពេលដែលគេប្រើលោហៈទាំងពីរជាមួយគ្នា សម្រាប់គ្រោងឆ្អឹងសំណង់។

## ២.២ សម្ភារដែលគ្រប់គ្រងបរិស្ថាន

### ២.២.១ ប្រភេទ និងលក្ខណៈសម្ភារស្រោចស្រព

❖ **បំពង់ទុយោប៉ូលីអេទីឡែន (PE)**

ទុយោរឹង (ទុយោទឹកដង់ស៊ីតេខ្ពស់),ទុយោទន់(ទុយោបាញ់បង្វិលទឹក,ទុយោតំណក់ទឹក)។

❖ **ម៉ាស៊ីនបូមទឹក**

ពេលប្រើប្រាស់: ទុយោបាញ់ទឹក (Springler) ឬទុយោតំណក់ទឹកត្រូវកំណត់ពីប្រភេទ ម៉ាស៊ីនបូមទឹក ដែលមានលក្ខណៈសម្ពាធផ្សេងៗ។

❖ **ទុយោសាចទឹក (Springler)**

- ទុយោសាចទឹកតូច (សម្រាប់ស្រោចស្រពថ្នាលបណ្តុះដំណាំ) ត្រូវបានគេតម្លើងពីក្រោមទៅលើ និងពីលើទៅក្រោម។

❖ **ប្រព័ន្ធទុយោតំណក់ទឹក**

- ជំពួយបញ្ចេញតំណក់ទឹកទូទៅ: ជំពួយទុយោទន់មានបំពង់បន្តក់ភ្ជាប់ជាមួយបន្ទះដែកមានរាងជាធ្មេញរណា ហើយជាទូទៅមានប្រវែង ២០ស.ម
- ប្រភេទបំពង់បន្តក់ទឹកមានប៊ូតុង: គេប្រើវាជាទូទៅសម្រាប់ស្រោចស្រពដំណាំចំការនៅក្នុងទសវត្សឆ្នាំ ១៩៩០។
- ជំពួយទុយោទឹកដែលមានសម្ពាធ: គេប្រើប្រាស់វាដោយប្រើសម្ពាធសមស្រប ហើយតម្លើងចំណុចបង្ហូរទឹកចន្លោះ ២០-៣០ស.ម ហើយវាតម្រូវការសម្ពាធច្រើនជាង ១,៥ក្រ/ស.ម២
- ទុយោទឹកមានចំណុចបញ្ចេញទឹកច្រើន: ថ្មីៗនេះសម្រាប់ការដាំដំណាំក្នុងទឹកសម្ពាធ ២,០គ.ក្រ/ស.ម២ ឬច្រើនជាងនេះត្រូវការចាំបាច់។

❖ **ឧបករណ៍ត្រួតពិនិត្យចរន្តទឹកហូរ**

- ឧបករណ៍ត្រូវបានគេប្រើជាបំពង់បង្ហូរហើយវាត្រូវការដំណើរការមានសម្ពាធ ០,៣គ.ក្រ/ស.ម² ខ្លាំង ជាងនេះ វាជាមេដែកអគ្គិសនីមួយ។

❖ **ឧបករណ៍តម្រង(Filter)**

- វាជាឧបករណ៍ដែលអាចចម្រុះទឹកឱ្យស្អាតហើយឧបករណ៍នេះត្រូវបានគេប្រើស្បៃច្រោះនិងធុងចម្រុះ។

❖ **ល្បឿននៃការហូរទឹកអាស្រ័យទៅលើសម្ពាធទឹក(ខ្នាត L/H)**

**តារាងទី២៖** ល្បឿននៃការហូរទឹក

| ប្រភេទ | សម្ពាធទឹក (ម) | | | |
|---|---|---|---|---|
| | ៥ | ១០ | ១៤ | ១៨ |
| ១២L/H | ០,៨២ | ១.១៤ | ១,៣៣ | ១,៥ |

❖ **ការតំឡើងចំណុចបញ្ចេញទឹកជាអតិបរិមានៅលើដី(១០%)**

**តារាងទី៣៖** សម្ពាធទឹក

| សម្ពាធទឹក (ម$^3$) | ចំណុចចន្លោះបញ្ចេញទឹក (ម$^3$) | | | | | |
|---|---|---|---|---|---|---|
| | ១៥ | ២០ | ៣០ | ៤០ | ៥០ | ៧៥ |
| ១០ | ៧២ | ៨៩ | ១១៩ | ១៤៤ | ១៦៨ | ២១៩ |
| ១៥ | ៧៤ | ៩១ | ១២១ | ១៤៧ | ១៧២ | ២២៤ |



**រូបភាពទី១៣៖** ស្រោចស្រពបាចសាច



**រូបភាពទី១៤៖** ប្រភេទផ្សេងៗនៃ សូឡេណូត(solenoid)

### ២.២.២ ប្រភេទ និងលក្ខណៈនៃប្រព័ន្ធធ្វើឱ្យត្រជាក់

❖ **ការធ្វើឱ្យត្រជាក់ដោយបំភាយខ្យល់**

- ពេលដែលខ្យល់ស្ងួតប៉ះជាមួយទឹក ត្រជាក់ រំហួត ខ្យល់ដែលបំភាយចេញមានសីតុណ្ហភាពត្រជាក់
- សំណើមខ្យល់កាន់តែទាប វិធីសាស្ត្រធ្វើឱ្យត្រជាក់កាន់តែមានប្រសិទ្ធិភាព
- វិធីសាស្ត្រប្រើកង្ហារ និងទ្រនាប់ត្រជាក់, វិធីសាស្ត្រប្រើកង្ហារ និង ផ្សែងអ័ព្ទត្រជាក់

० **វិធីសាស្ត្រប្រើកង្ហារ និងចំហាយទឹក**



**រូបភាពទី១៥៖** ប្រព័ន្ធប្រើផ្សែងអ័ព្ទចំហាយត្រជាក់



**រូបភាពទី១៦៖** ការបញ្ចេញបញ្ចូលខ្យល់ដោយប្រើកង្ហារបឺតខ្យល់

- ក្នុងវិធីសាស្ត្រប្រើកង្ហារ ដាក់នៅជញ្ជាំងគេប្រើឧបករណ៍បញ្ចេញចំហាយត្រជាក់ជំនួសវិញ
- សីតុណ្ហភាពខាងក្រៅត្រជាក់នៅពេលដែលវាហើរឆ្លងកាត់បន្ទប់ចំហាយត្រជាក់ហើយខ្យល់ត្រជាក់ នេះត្រូវបានគេបញ្ចូលទៅក្នុងផ្ទះបៃតង
- នៅពេលគេប្រើកង្ហារ និងប្រព័ន្ធបញ្ចេញចំហាយត្រជាក់ ធ្វើឱ្យមានបម្រែបម្រួលសីតុណ្ហភាពនៅក្នុងផ្ទះបៃតងហើយវាត្រូវការឧបករណ៍ដើម្បីកាត់បន្ថយសីតុណ្ហភាពនៅពេលកម្ដៅកើនខ្ពស់
- នៅក្នុងវិធីសាស្ត្រប្រើចំហាយត្រជាក់ដូចដែលបានពិពណ៌នាខាងលើ, ខ្យល់ដែលមានសីតុណ្ហភាពខ្ពស់ត្រូវបានគេធ្វើឱ្យប៉ះជាមួយទឹកដែលមានសីតុណ្ហភាពទាបដើម្បីប្ដូរពីចំហាយទៅជាទឹកដូច្នេះធ្វើឱ្យខ្យល់ប្រែក្លាយជាត្រជាក់ ហើយបំភាយបង្កើតបានជាសំណើម
- ដូចដែលបានបង្ហាញពីប្រសិទ្ធិភាពនៃការធ្វើឱ្យត្រជាក់នៅក្នុងផ្ទះបៃតងវិធីសាស្ត្រនេះមានឥទ្ធិពលធំ នៅពេលដែលសំណើមខាងក្រៅផ្ទះបៃតងមានកម្រិតទាប។ ប៉ុន្តែដោយសារតែរដូវក្ដៅភ្ជាប់ជាមួយនឹងភ្លៀងធ្លាក់ ប្រសិទ្ធិភាពធ្វើឱ្យត្រជាក់គឺមានកម្រិតទាបដោយសារតែសំណើមខ្ពស់។




**រូបភាពទី១៧៖** ប្រព័ន្ធចំហាយអ័ព្ទ



មុនប្រើ　　　　　　　　កំពុងប្រើប្រាស់

**រូបភាពទី១៨៖** ប្រព័ន្ធប្រើចំហាយត្រជាក់

- កម្តៅមានចលនាពីខ្ពស់មកទាបហើយម៉ូទ័រកម្តៅគឺជាឈ្មោះដែលត្រូវបានគេដាក់ឱ្យដោយសារតែវា អាចធ្វើឱ្យកើនឡើងសីតុណ្ហភាពពីទាបទៅខ្ពស់
- ជាដំបូងឡើយឧបករណ៍នេះត្រូវបាន បង្កើតឡើងក្នុងគោលបំណង ដើម្បីសំងួតឧបករណ៍ក្នុងទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនក្លាសេ និងដើម្បីផ្លុំបញ្ចេញចោលកម្តៅ
- ប៉ុន្តែបច្ចុប្បន្នវាត្រូវបានគេប្រើប្រាស់ក្នុងប្រព័ន្ធធ្វើឱ្យត្រជាក់ដែលផ្ទេរខ្យល់ត្រជាក់ឱ្យទៅជាខ្យល់ក្តៅដោយប្រើប្រាស់ឧបករណ៍ដែលធ្វើឱ្យត្រជាក់ឬប្រព័ន្ធកម្តៅដែលបញ្ជូនសីតុណ្ហភាពខ្ពស់ឱ្យទៅជួបជាមួយសីតុណ្ហភាពទាបទាំងនេះគេហៅថាប្រព័ន្ធធ្វើឱ្យក្តៅ និងប្រព័ន្ធធ្វើឱ្យត្រជាក់
- ឧបករណ៍ម៉ូទ័រកម្តៅនេះផ្សំឡើងពី កុំប្រែស័រ, អ៊ីវ៉ាប៉ូរ៉ើទ័រ, ខនដេនស័រ និងសន្ទះបិទបើក
- នៅក្នុងករណីបង្កើតកម្តៅ,ឧបករណ៍ធ្វើឱ្យត្រជាក់ត្រូវបានសង្កត់ឱ្យណែនដោយសម្ពាធខ្ពស់នេះត្រូវបានបង្ហួតចេញដោយ កុំប្រែស័រ ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅ ខនដេនស័រ ដើម្បីដំណើរការ ឡើងវិញនូវវដ្តបញ្ចេញសីតុណ្ហភាពខ្ពស់ហើយបង្កើតសីតុណ្ហភាពទាប


16

- ប្រព័ន្ធធ្វើឱ្យត្រជាក់ផ្សំឡើងដោយ កុំប្រែស័រ និងអ៊ីវ៉ាប៉ូរ៉ែទ័រ មានតួនាទីជា ខនដេនស័រ ដូច្នេះខ្យល់ត្រជាក់ដែលប្រមូលផ្តុំអាចផ្លាស់ប្តូរជាមួយខ្យល់ក្តៅខាងក្រៅដើម្បីធ្វើឱ្យត្រជាក់ចំណុចដែលគេចង់បាន។

❖ **ម៉ូទ័រ:** បញ្ជូនទឹកពីទីទាបទៅទីខ្ពស់

- ទឹកធម្មតាហូរពីទីខ្ពស់ទៅកន្លែងទាប
- ការបម្លាស់ទីធ្វើឡើងដោយការប្រើប្រាស់ថាមពល(ម៉ូទ័រអគ្គីសនី)។

❖ **កម្តៅ:**ធ្វើចលនាពីសីតុណ្ហភាពខ្ពស់មកទាប

- កម្តៅដែលសម្ភារផ្ទុកមានសីតុណ្ហភាពដូចគ្នាទាំងអស់។

❖ **ម៉ូទ័រកម្តៅ:**ធ្វើចលនាពីសីតុណ្ហភាពទាបទៅសីតុណ្ហភាពខ្ពស់

- ជាឧបករណ៍ជួយដែលស្រូបយកតែកម្តៅនៅក្នុងលក្ខខណ្ឌសីតុណ្ហភាពទាបហើយធ្វើចលនាទៅកន្លែងមានសីតុណ្ហភាពខ្ពស់
- ម៉ូទ័រកម្តៅ គឺមានមូលដ្ឋានគ្រឹះស្រូបយកកម្តៅ និងរំសាយកម្តៅ
- ជាប្រភេទប្រើសម្ពាធជាប្រភេទស្រូប...។ល។
- ប្រភេទម៉ូទ័រប្រើសម្ពាធត្រូវបានគេប្រើប្រាស់ជាទូទៅ
- ប្រភេទម៉ូទ័រនេះមានគោលការណ៍បង្កើតកម្តៅត្រលប់ទៅត្រលប់មក(វដ្តកម្តៅ)ចំណែកឯម៉ូទ័រកម្តៅគឺ ត្រូវបានគេហៅថា វដ្តកម្តៅបញ្ច្រាស់
- ម៉ូទ័រកម្តៅប្រើសម្ពាធ(វដ្តកម្តៅវិលជុំ)មានទិសដៅបង្កើតភាពត្រជាក់ និងកម្តៅ
- ម៉ូទ័រកម្តៅបង្កើតភាពត្រជាក់: មានដូចជាម៉ាស៊ីនត្រជាក់ និងទូរទឹកកក
- ម៉ាស៊ីនត្រជាក់ស្រូបយកកម្តៅពីឧបករណ៍ប្តូរកម្តៅដែលគេតម្លើងនៅក្នុងបន្ទប់ ដើម្បីធ្វើឱ្យបន្ទប់ ត្រជាក់ និងប្រើប្រាស់ឧបករណ៍ផ្លាស់ប្តូរកម្តៅខាងក្រៅដើម្បីរំសាយកម្តៅនៅក្នុងបន្ទប់។

❖ **កញ្ចក់ស្រូបកម្តៅ**

- ជាកញ្ចក់ដែលស្រូបយករលកកម្តៅម៉ាញ៉េទិច នៅពេលវាបញ្ជូលពន្លឺ ដើម្បីរារាំងការកើនឡើងកម្តៅនៅក្នុងផ្ទះ។



**រូបភាពទី១៩៖** ការបង្កើតកម្តៅដោយប្រើម៉ូទ័រកម្តៅ

❖ **ការបង្កើតម្លប់**

- នៅក្នុងករណីពេលថ្ងៃ,  ពន្លឺ  និងកម្តៅផ្ទុកមានកម្រិតខ្ពស់ហើយមធ្យោបាយជំនួយដែលមានប្រសិទ្ធិភាព ដើម្បីធ្វើឱ្យត្រជាក់ គឺគេប្រើប្រពន្ធ័ធ្វើឱ្យត្រជាក់ (Cooling System)និង ការធ្វើឱ្យ ម្លប់។ បរិមាណពន្លឺគួរតែត្រូវបានគេកែសម្រួលទៅតាមតម្រូវការរបស់ដំណាំ។



**រូបភាពទី២០៖** ការធ្វើឱ្យមានម្លប់នៅក្នុងផ្ទះបៃតង

### ❖ គោលការណ៍ប្រើម្លប់ធ្វើឱ្យត្រជាក់

- ប្រើប្រាស់សម្ភារពណ៌ខ្មៅ(ក្រណាត់ខ្មៅ)បាំងពីខាងក្រៅអាចកាត់បន្ថយពន្លឺ និង កម្ដៅ ៤០%។ ដូច្នេះ នៅសល់៦០%ថាមពលកម្ដៅចូលទៅក្នុងផ្ទះបៃតង
- នៅក្នុងផ្ទះបៃតងសម្ភារខ្មៅអាចបង្កើតម្លប់បាន៤០%។ ៩០%នៃកម្ដៅចូលទៅក្នុងថាមពលកម្ដៅក្នុងផ្ទះបៃតង។




**រូបភាព២១៖** ចលនាលំហូរ និងបញ្ចេញកម្ដៅនៅក្នុងផ្ទះបៃតង

### ២.២.៣ ឧបករណ៍បង្កើតសំណើម និង បំបាត់សំណើម

- **ឧបករណ៍សំងួត:** មានតួនាទីកាត់បន្ថយសំណើមដោយសំងួតចំហាយពីខាងក្នុងផ្ទះបៃតង
- **លក្ខខណ្ឌនៃការប្រើប្រាស់ឧបករណ៍សម្ងួត**

- អាចធ្វើឱ្យសំណើមថយចុះនៅក្នុងផ្ទះបៃតងទៅដល់កម្រិតមួយដែលគេចង់បាន
- ធ្វើឱ្យមានសំណើមនៅក្នុងផ្ទះបៃតងមានកម្រិតស្មើៗគ្នា
- វាគួរមិនប៉ះពាល់ដល់ការងារនៅក្នុងផ្ទះបៃតង
- វាត្រូវតែសន្សំសំចៃ។

- **វិធីសាស្រ្តក្នុងការកាត់បន្ថយសំណើមដោយប្រើឧបករណ៍សំងួត**

- ឧបករណ៍សំងួតរួមមាន ឧបករណ៍បំភាយ(evaporator) និង condenser
- ការកាត់បន្ថយសំណើមដោយប្រើឧបករណ៍សំងួតដែលតម្លើងនៅលើឧបករណ៍បំភាយខ្យល់ត្រជាក់ដូច្នេះ ខ្យល់ត្រជាក់ត្រូវបានបំភាយចេញ
- នៅក្នុងខ្យល់ស្ងួតមានសីតុណ្ហភាពល្មម ហើយត្រូវបានបញ្ចេញចោល
- ការបញ្ចូលគ្នារវាងខ្យល់ត្រជាក់ និងខ្យល់ក្ដៅឧណ្ហៗត្រូវបានបញ្ចេញទៅក្នុងផ្ទះបៃតង
- កំណកញើសត្រូវបានបញ្ចេញចោលតាមរយៈបំពង់បង្ហូរ
- ការប្រើប្រាស់ឧបករណ៍សំងួត គេកែតម្រូវទៅលើប្រភេទការងារ។

- **បញ្ហានៃឧបករណ៍សំងួត**

- សីតុណ្ហភាពកាន់តែខ្ពស់ការងារ នៃការប្រើប្រាស់ឧបករណ៍សំងួតកាន់តែមានប្រសិទ្ធិភាព។ ប៉ុន្តែការប្រើប្រាស់ ឧបករណ៍នេះមិនសូវមានប្រសិទ្ធិភាពនៅពេលផ្ទះបៃតង មានសីតុណ្ហភាពទាបខ្លាំង និងមានកំណកញើសទឹក
- ប្រើប្រាស់ថវិកាច្រើន ពីព្រោះគេត្រូវប្រើប្រាស់ថាមពលដើម្បីប្រើឧបករណ៍សំងួតនេះ
- មានប្រទេសតិចតួចប៉ុណ្ណោះប្រើប្រាស់ឧបករណ៍សំងួតនៅក្នុងផ្ទះបៃតង។

- **វិធីសាស្រ្តវាយតម្លៃនៃការប្រើប្រាស់ឧបករណ៍សំងួត**

- ចាប់ផ្ដើមសំងួត និងត្រួតពិនិត្យបរិមាណសំណើមមុន និងក្រោយការប្រើប្រាស់ឧបករណ៍ សំងួត
- ចាប់ផ្ដើមសំងួត និងត្រួតពិនិត្យបរិមាណកំណកញើសទឹកនៅក្នុងផ្ទះបៃតង។

- **បរិមាណចំហាយទឹកដែលត្រូវបានសំងួតនៅក្នុងផ្ទះបៃតង**

- បរិមាណចំហាយទឹកដែលត្រូវបានសំងួតនៅក្នុងផ្ទះបៃតងត្រូវបានគណនាដោយប្រើប្រាស់បរិមាណសំណើមដាក់លាក់ និងទំហំដាក់លាក់នៅក្នុងផ្ទះបៃតងទៅនឹងសំណើមដែលទាក់ទង
- បរិមាណចំហាយទឹកដែលត្រូវបានសំងួត គឺអាស្រ័យលើសីតុណ្ហភាព។

- **បង្កើនសីតុណ្ហភាពដើម្បីបញ្ចុះបរិមាណសំណើមនៅក្នុងផ្ទះបៃតង**

- បង្កើនសីតុណ្ហភាពនៅក្នុងផ្ទះបៃតងដើម្បីកាត់បន្ថយសំណើម ដូច្នេះអ្នកអាចកែតម្រូវសំណើមដែលអ្នកចង់បានសម្រាប់ដំណាំ
- ស្ថានភាពការបង្កើនសីតុណ្ហភាពអាស្រ័យទៅតាមបរិមាណសំណើមនិងសីតុណ្ហភាពនៅក្នុងផ្ទះបៃតង។

### ២.២.៤ ប្រភេទ និងការប្រើប្រាស់ Sensor សម្រាប់ត្រួតពិនិត្យបរិស្ថាន

- **ប្រភេទឧបករណ៍វាស់បរិស្ថាន**

- ទែម៉ូម៉ែត(Thermometer)
- ឧបករណ៍វាស់សំណើម(Hygrometer)
- ឧបករណ៍វាស់ពន្លឺ(Photometer)
- ឧបករណ៍វាស់ល្បឿនខ្យល់(anemometer)
- ឧបករណ៍វាស់ឧស្ម័នកាបូនិច(Carbone dioxide sensor)

- **ប្រភេទ និងលក្ខណៈរបស់ទែម៉ូម៉ែត**

**១. ការបែងចែកថ្នាក់**

- ការប្រើប្រាស់វត្ថុរាវៈ រួមមានបារ៉ត ឬអាល់កុល
- ការប្រើប្រាស់លោហៈ : ប្រើប្រាស់លោហៈជីវសាស្ត្រ
- ប្រើប្រាស់ចរន្តអគ្គិសនីៈ ប្រើប្រាស់ចរន្តអគ្គិសនីដែលបានមកពីលោហៈផ្សេងៗ
- ប្រើប្រាស់សម្ភារៈធន់ទ្រាំនឹងអគ្គិសនីៈ ប្រើផ្លាទីន ឬសម្ភារធន់ទ្រាំនឹងកម្ដៅ
- ប្រើប្រាស់រលកកម្ដៅៈ សម្រាប់វាស់កម្ដៅដែលចេញមកពីវត្ថុដូចជា ទែម៉ូម៉ែតសម្រាប់វាស់កាំរស្មី។

**២. ការបែងចែកយោងទៅតាមការប្រើប្រាស់**

- ទែម៉ូម៉ែតអប្បបរមា និងអតិបរមាៈ អាចឱ្យគេវាស់វែង វាស់សីតុណ្ហភាពអតិបរមា និងអប្បបរមាបានជាមួយគ្នា
- ទែម៉ូម៉ែតចង្វាក់សម្លេងៈ វាអាចវាស់សីតុណ្ហភាពដោយគេគ្រាន់តែចាក់វាទៅក្នុងដី ឬអាចដាក់នៅកន្លែងដែលគេចង់វាស់
- ទែម៉ូម៉ែតកែវស្ងួងស្ងួតៈ គេបង្កើតឡើងដើម្បីវាស់សីតុណ្ហភាព និងសំណើមក្នុងពេលតែមួយ។

**៣. ទែម៉ូម៉ែតវាស់សីតុណ្ហភាពអប្បរមា និងអតិបរមា**

- អនុញ្ញាតិឱ្យគេវាស់សីតុណ្ហភាពអប្បរមា និងអតិបរមាបានជាមួយគ្នា
- វាមានតម្លៃថោកហើយមានប្រយោជន៍ណាស់សម្រាប់ប្រើប្រាស់ក្នុងផ្ទះបៃតង។

**៤. ទែម៉ូម៉ែតកាំរស្មីដែលមើលមិនឃើញ**

- ដើម្បីវាស់សីតុណ្ហភាពលើផ្ទៃរាបរបស់វត្ថុមួយដែលប្រើប្រាស់កាំរស្មីដែលមើលមិនឃើញ
- ជាទូទៅគេប្រើវាដើម្បីវាស់សីតុណ្ហភាពរបស់ស្លឹករបស់រុក្ខជាតិ។

**៥. ទែម៉ូម៉ែតចង្វាក់សម្លេង(ឧបករណ៍វាស់សីតុណ្ហភាព)**

- គេដាក់ទែម៉ូម៉ែតនេះនៅក្នុងដី ឬនៅក្នុងសូលុយស្យុងរាវដើម្បីវាស់សីតុណ្ហភាព។
- វាអាចការពារទែម៉ូម៉ែតពីការបែកបាក់

**៦. ទែម៉ូម៉ែតកែវស្ងួងស្ងួត**

- គេអាចប្រើវាសម្រាប់វាស់សីតុណ្ហភាព និងសំណើមក្នុងពេលជាមួយគ្នា

- ត្រូវតែមានទឹកនៅក្នុងធុងជានិច្ច
- មានប្រភេទទែម៉ូម៉ែតកែវស្ងួត និងទែម៉ូម៉ែតកែវសើម
- ទែម៉ូម៉ែតកែវស្ងួតបង្ហាញពីសីតុណ្ហភាពធម្មតា
- គណនាសំណើមដោយការប្រៀបធៀបសីតុណ្ហភាពរបស់កែវស្ងួតជាមួយនឹង សីតុណ្ហភាពរបស់កែវសើម ហើយគេអាចមើលឃើញតម្លៃដែលមាននៅក្នុងតារាង ឬការប្រើប្រាស់ខ្សែបន្ទាត់ឧបករណ៍ស្ងួត។




ទែម៉ូម៉ែត្រសីតុណ្ហភាពអតិប្បរមា និងអប្បរមា




ទែម៉ូម៉ែត្រប្រើកាំរស្មី



ទែម៉ូម៉ែត្រសើ ឬទែម៉ូម៉ែតចង្វាក់សំឡេង



ទែម៉ូម៉ែត្រកែស្ងង់ស្ងួត

**រូបភាពទី២២៖** ប្រភេទផ្សេងៗនៃទែម៉ូម៉ែត្រ

- **ឧបករណ៍ស្ទង់សំណើមខ្យល់**
  - ជាប្រភេទទែម៉ូម៉ែតកែវស្ងង់ស្ងួត
  - ប្រើប្រាស់សម្រាប់វាស់ចំណុចសំណើម
  - ជាប្រភេទឧបករណ៍ប្រើអគ្គិសនី
- **របៀបប្រើប្រាស់ទែម៉ូម៉ែត និងឧបករណ៍ស្ទង់សំណើមខ្យល់**

**១. ត្រូវមានការប្រុងប្រយត្ន័ពេលតម្លើងទែម៉ូម៉ែត និងឧបករណ៍ស្ទង់សំណើមខ្យល់**

- កុំទុក Sensor ឱ្យត្រូវពន្លឺ
- ទុកឱ្យមានខ្យល់ចេញចូលបានល្អបើមិនដូច្នេះទេវាមិនអាចវាស់វែងត្រឹមត្រូវបានទេ តាមពិតសីតុណ្ហភាពពេលថ្ងៃជារឿយៗត្រូវបានគេវាស់ឃើញខ្ពស់
- ជៀសវាងទុកដាក់កន្លែងសើម និងសំណើមខ្ពស់

**២. របៀបតម្លើង Sensor**

- មានលក្ខខណ្ឌមួយចំនួនដែលតម្រូវឱ្យគេបង្កើត ដើម្បីមានខ្យល់ចេញចូលបានល្អដោយមិនប៉ះពាល់ពន្លឺថ្ងៃ។ ចរន្តខ្យល់ចេញចូលមូលគួរតែយ៉ាងហោចណាស់មានល្បឿន ២m/s
- ជីឡាវ ឬដបប្លាស្ទិអាចឱ្យគេប្រើដើម្បីផលិតកម្មប្រើប្រាស់ខ្លួនឯង
- គេអាចកាត់ដបប្លាស្ទិចផ្នែកខាងលើចេញបង្កើតជារាងជីឡាវ
- គេអាចប្រើក្រដាស់អាលុយមីញ៉ូមស្រោបខាងក្នុង និងខាងក្រៅធុង ឬប្រអប់ស្នោ ដូច្នេះវាអាចចាំង ផ្លាតទៅនឹងពន្លឺថ្ងៃបានល្អ
- ដាក់បញ្ចូល Sensor ទៅក្នុងជីឡាវ ប៉ុន្តែកុំឱ្យ Sensor ប៉ះទៅនឹងផ្ទៃខាងក្នុងជីឡាវ ហើយដាក់ Sensor ១-២សម លៀនចេញពីជីឡាវ។

**៣. ទីតាំងនៃការដាក់ សេនសឺ(Sensor)**

- សីតុណ្ហភាព និងសំណើមរបស់ផ្ទះបៃតងខុសគ្នាតិចតួចអាស្រ័យទៅទីតាំង
- ពេលដាក់ **សេនសឺ** តែមួយ, គួរដាក់នៅកន្លែងដែលមានតម្លៃមធ្យម។ ជៀសវាងដាក់កន្លែងចំពន្លឺ ពេកកន្លែងមានសសរ សំយ៉ាប ឬផ្លូវចូលផ្ទះបៃតង។ កុំដាក់ **សេនសឺ** នៅពីមុខម៉ាស៊ីនកម្តៅ ឬម៉ាស៊ីនត្រជាក់
- គេគួរដាក់ ឬតម្លើង **សេនសឺ** នៅចំណុចកម្ពស់នៃការលូតលាស់ដំណាំ។ ចំណុចកម្ពស់នៃការ លូតលាស់ដំណាំប៉េងប៉ោះ គឺមានការប្រែប្រួល ដូច្នេះកម្ពស់នៃការដាក់ **សេនសឺ** ត្រូវផ្លាស់ប្តូរដែរ។

**៤. បញ្ហានៅក្នុងអនុវត្តន៍របស់កសិករ**

- កសិករជាច្រើនប្រើទែម៉ូម៉ែតដាក់ទៅនឹងម៉ាស៊ីនកម្តៅ។ នៅពេលនេះទែម៉ូម៉ែតមិននៅឆ្ងាយពីកម្តៅទេ ហើយសីតុណ្ហភាពត្រូវគេកំណត់ឱ្យទាបជាងសីតុណ្ហភាពជាក់ស្តែង
- **សេនសឺ** មិនត្រូវបានគេតភ្ជាប់ជាមួយកន្លែងបិទភ្លើងទេ ដូច្នេះមានករណីជាច្រើន ដូចជាកំណកទឹក ឬពន្លឺព្រះអាទិត្យ
- មានករណីជាច្រើន សីតុណ្ហភាពនៅជិតកន្លែងបញ្ចេញបញ្ចូលខ្យល់មានកម្រិតទាបពេក ដែលគួរត្រូវពិចារណា
- ទែម៉ូម៉ែតអំពូលស្ងួតស្ងួតជារឿយៗគ្មានទឹក។

- **ឧបករណ៍វាស់ពន្លឺ**

**១. ប្រភេទឧបករណ៍វាស់ពន្លឺ**

- ឧបករណ៍វាស់ពន្លឺ: ប្រើសម្រាប់វាស់ពីទំហំរបស់ពន្លឺ
- ឧបករណ៍វាស់រលកកម្តៅ: ប្រើប្រាស់សម្រាប់វាស់រលកកម្តៅរបស់ពន្លឺ
- PAR **សេនសឺ**: ប្រើប្រាស់សម្រាប់វាស់របបពន្លឺទាំងក្នុងខ្យល់ និងក្នុងទឹក





**រូបភាពទី២៣៖** ប្រភេទផ្សេងៗនៃឧបករណ៍វាស់ពន្លឺ

**២. របៀបប្រើប្រាស់ឧបករណ៍វាស់ពន្លឺ**

- ទីតាំងតម្លើងៈ ដាក់តម្លើងឧបករណ៍នេះទៅត្រង់កន្លែងដែលមានពន្លឺជាប្រចាំ
- វិធីសាស្ត្រតម្លើងៈ តម្លើងផ្តេក(ដាក់ផ្តេក)
- សម្អាតឧបករណ៍ឱ្យបានទៀងទាត់ធូលីដែលស្អិតជាប់នឹងឧបករណ៍
- ប្រុងប្រយ័ត្នធ្វើការផ្លាស់ប្តូរឧបករណ៍ពីព្រោះរយៈពេលប្រើប្រាស់ឧបករណ៍នេះមិនយូរទេ។

**០ ឧបករណ៍វាស់កម្លាំងខ្យល់ និងឧបករណ៍រាំងខ្យល់**

**១. ប្រភេទបង្វិល**

- គោលការណ៍ៈ វាប្រើចំនួនផ្លាស់ប្តូរនៃកង្ហារបង្វិលទៅតាមល្បឿនខ្យល់
- ប្រភេទៈ Aerobane, Anemoshi Nemo, Photoelectric និងSmall Robinson Anemometer.

**២. កម្តៅ**

- គោលការណ៍ៈប្រសិនបើមានប្រភពកម្តៅប្រើប្រាស់កម្រិតកម្តៅដែលបាត់បង់តាមរយៈល្បឿនខ្យល់
- ប្រភេទៈ ឧបករណ៍វាស់កម្លាំងខ្យល់ធន់នឹងកម្តៅ។ល។
- លក្ខណៈ៖ វាមានការពិបាកដើម្បីប្រើប្រាស់ឧបករណ៍ទាំងនេះនៅកន្លែងមានធូលីច្រើនជាញឹយៗ ត្រូវពិនិត្យមើលកម្រិតរ៉ុលរបស់អាគុយ ឬថ្មពិលដែលប្រើ។ វាមានការពិបាកប្រើប្រាស់នៅពេលមានភ្លៀងពីព្រោះវាត្រូវបានវាស់វែងដោយសីតុណ្ហភាពផ្លាស់ប្តូរ។

**៣. ប្រភេទប្រេកង់រលកសម្លេង**

- គោលការណ៍ៈ ប្រើប្រាស់សម្រាប់វាស់វែងល្បឿននៃចេញផ្សាយរលកសម្លេងរបស់ Ultrasonic តាមរយៈល្បឿនខ្យល់
- ប្រភេទៈ ជាឧបករណ៍វាស់ទិសខ្យល់ Ultrasonic និងឧបករណ៍វាស់សម្លេង Ultrasonic ជាដើម
- លក្ខណៈ គេប្រើឧបករណ៍ទាំងនេះសម្រាប់ឧតុនិយមហើយវាឆ្លើយតបបានយ៉ាងល្បឿន។

## ៤. របៀបប្រើប្រាស់ឧបករណ៍វាស់កម្លាំងខ្យល់ និងព្រួញចង្អុលទិសខ្យល់

- ទីតាំងតម្លើង: តម្លើងនៅកន្លែងដែលមិនប៉ះពាល់ដល់ខ្យល់
- ប្រើប្រាស់ Sensor ដែលសមរម្យសម្រាប់លក្ខខណ្ឌទូលំទូលាយ



**រូបភាពទី២៤៖** ស្ថានីយ៍អាកាសធាតុខាងក្រៅ

- **Sensor សម្រាប់វាស់ $CO_2$**
- ប្រភេទ: ជាប្រភេទឧបករណ៍វិភាគឧស្ម័នដែលមើលមិនឃើញ




**រូបភាពទី២៥៖** ឧបករណ៍វិភាគ $CO_2$

**១. របៀបប្រើប្រាស់ ឧបករណ៍(Sensor) សម្រាប់វាស់ឧស្ម័នកាបូនិច ($CO_2$)**

- ពេលតម្លើងឧបករណ៍នេះតែមួយគួរតម្លើងវានៅកន្លែងដែលមានពន្លឺមធ្យមនៅក្នុងផ្ទះបៃតង។ជៀសវាងដាក់ Sensor នៅពីមុខម៉ាស៊ីនកម្ដៅ ឬម៉ាស៊ីនត្រជាក់
- ត្រូវមានការប្រុងប្រយត្ន័ពីព្រោះវាមានការខុសគ្នាខ្លាំងពីកន្លែងមួយទៅកន្លែងមួយ
- ឧបករណ៍វាស់ ឬវិភាគ CO2 នេះមានតម្លៃថ្លៃជាងឧបករណ៍ដទៃ ដូច្នេះប្រើប្រាស់វាឱ្យមានការប្រុងប្រយត្ន័
- ត្រូវមានការប្រុងប្រយត្ន័ ពីព្រោះតម្លៃវាស់វែងមានការប្រែប្រួលយ៉ាងខ្លាំងតាមរយៈការដកដង្ហើមរបស់មនុស្ស។






**រូបភាពទី២៦៖** តម្លើងឧបករណ៍វាស់ $CO_2$

### ២.២.៥ កម្មវិធីគ្រប់គ្រងបរិស្ថាន

**ㅇ និយមន័យនៃការត្រួតពិនិត្យបរិស្ថានក្នុងផ្ទះបៃតង**

- ការកែលម្អផលិតកម្មដំណាំ និងគុណភាពអាចធ្វើទៅកើតតាមរយៈការគ្រប់គ្រងបរិស្ថាន
- កត្តាបរិស្ថានសំខាន់ៗក្នុងផ្ទះបៃតងរួមមានចរន្តចេញចូលខ្យល់, សីតុណ្ហភាពនិងសំណើម
- ដំណើរការនៃប្រព័ន្ធកែតម្រូវលក្ខខណ្ឌបរិស្ថាននៅក្នុងផ្ទះបៃតងគឺធ្វើឡើងដោយសប់វែ (Software) ក្នុងប្រព័ន្ធកុំព្យូទ័រ (Computer) ដែលអាចធ្វើឱ្យដំណាំលូតលាស់បានល្អ ហើយសន្សំសំចៃថាមពល។

**ㅇ កុំព្យូទ័រត្រួតពិនិត្យបរិស្ថាន**

- ការវាស់វែង៖ ការប្រែប្រួលបរិស្ថានត្រូវវាស់វែងដោយចរន្តវ៉ុល្ដស៊ីស្តង់ និងកម្លាំងអគ្គិសនីដែលបានមកពី Sensor ដែលបំលែងទៅជាទិន្នន័យជាលេខតាមរយៈឧបករណ៍បំលែង ដើម្បីឱ្យក្លាយពត៌មាននៅក្នុងកុំព្យូទ័រ
- ឧបករណ៍ទំនាក់ទំនងមានតួនាទីច្រើនមុខ៖ ពេលដែលមានការវាស់វែងច្រើនមុខ ច្រើនបែប ទិន្នន័យទាំងនេះត្រូវបានផ្ទេរតាមរយៈឧបករណ៍ទំនាក់ទំនងមានតួនាទីច្រើនមុខនេះ ជាទិន្នន័យ ក្នុងរយៈពេលចន្លោះ ១៥ទៅ ៦០វិនាទីសម្រាប់ការវាស់វែងម្ដងៗ។ ទិន្នន័យ analog នេះត្រូវបានផ្ទេរទៅជាទិន្នន័យជាលេខ តាមរយៈឧបករណ៍ផ្ទេរ ហើយត្រូវបានស្តុកនៅក្នុងប្រពន្ធ័កុំព្យូទ័រ។

## ០ មេម៉ូរីកុំព្យូទ័រត្រួតពិនិត្យបរិស្ថាន

- ប្រព័ន្ធកុំព្យូទ័រត្រួតពិនិត្យបរិស្ថាននៅក្នុងផ្ទះបៃតង ប្រមែប្រមូលទិន្នន័យ ហើយប្រៀបធៀបជាមួយលក្ខខណ្ឌដែលយើងបានដាក់ពី (Sensor) និងត្រួតពិនិត្យឧបករណ៍រក្សាតុល្យភាពនីមួយៗ ជាមួយនឹងតម្លៃ ដែលត្រូវបានគណនាដើម្បីឱ្យត្រូវប្រហាក់ប្រហែលគ្នា។ ដំណើរការនេះ ហៅថាប្រព័ន្ធត្រួតពិនិត្យ
- ការត្រួតពិនិត្យឧបករណ៍ដែលមានតួនាទីកែតម្រូវ

**១. ការបង្កើនកម្តៅបំពង់ទុយោ ឬការបង្កើនកម្តៅខ្យល់ក្តៅ:** បើក/បិទ

**២. ការត្រួតពិនិត្យបង្អួចខ្យល់ចេញចូល:** ខ្យល់ចេញចូលមានឥទ្ធិពលទៅលើ

បម្រែបម្រួល សីតុណ្ហភាព សំណើម និងបរិមាណ $CO_2$ នៅក្នុងផ្ទះបៃតង។ ការគណនាទំហំនៃការបើក និងបិទ គឺវាអាស្រ័យ ទៅលើ p-band។

**៣. ការត្រួតពិនិត្យការបញ្ចេញបញ្ចូលខ្យល់ និងកម្តៅ**(ត្រួតពិនិត្យសីតុណ្ហភាព) សីតុណ្ហភាពតំបន់អសកម្ម គឺមានការខុសគ្នារវាងសីតុណ្ហភាពខ្យល់ និងសីតុណ្ហភាពដែលបានមកពីដុតកម្តៅ ហើយសីតុណ្ហភាពតំបន់អសកម្មត្រូវបានគេកំណត់ពី ០.៥-២°C។ សីតុណ្ហភាពដែលបានមកពីចរន្តខ្យល់ចេញចូល និងសីតុណ្ហភាពដែលបានមកពីការដុតកម្តៅ គឺអាចប្រែប្រួលតាមរយៈការលូតលាស់របស់ដំណាំ បរិមាណពន្លឺ និងអាំងតង់ស៊ីតេពន្លឺ។

**៤. ការត្រួតពិនិត្យប្រើ Screen កុំព្យូទ័រ:** បើក/បិទសម្រាប់ត្រួតពិនិត្យពន្លឺសន្សំថាមពល ការធ្វើ ឱ្យមានម្លប់។ ការបិទ/បើកអាចឱ្យគេត្រួតពិនិត្យសីតុណ្ហភាពខាងក្រៅ សំណើមខាងក្នុង កម្រិតពន្លឺ ល្បឿនខ្យល់ និងប្រព័ន្ធកម្តៅ។




**រូបភាពទី២៧:** គំនូសបង្ហាញការត្រួតពិនិត្យដោយប្រព័ន្ធកុំព្យូទ័រ




**រូបភាពទី២៨៖** ប្រព័ន្ធកុំព្យូទ័រ(Computer)គ្រប់គ្រងបរិស្ថាន

៥. **ការគ្រប់គ្រង និងប្រើប្រាស់$CO_2$:** ការគ្រប់គ្រងបើក/បិទ និងការកំណត់តម្លៃគឺផ្លាស់ប្តូរជាស្វ័យប្រវត្តិដោយអត្រាបើក និងអាំងតង់ស៊ីតេពន្លឺនៃបង្អួចដែលបញ្ចេញបញ្ចូលខ្យល់។ ដោយសារតែពន្លឺថ្ងៃមានសីតុណ្ហភាពលើសីតុណ្ហភាពខ្យល់ដែលចេញចូល, បរិមាណឧស្ម័ន $CO_2$ គឺមានឥទ្ធិពលដោយសីតុណ្ហភាពផ្ទៃ ក្នុងផ្ទះបៃតង។

៦. **ការគ្រប់គ្រងសំណើម:** សីតុណ្ហភាព និងសំណើមគឺទាក់ទងគ្នាយ៉ាងជិតស្និទ្ធទៅវិញទៅមក ដូច្នេះវាត្រូវបានគេប្រើសម្រាប់ការគ្រប់គ្រងទាំងសំណើម និងសីតុណ្ហភាពដោយការបង្កើតកម្តៅ និងការបញ្ចេញបញ្ចូលខ្យល់។ សំណើមខាងក្នុងផ្ទះបៃតងកាន់តែទាបសីតុណ្ហភាពដែលបានមកពីខ្យល់ចេញចូលកាន់តែខ្ពស់។

## ២.៣ សម្ភារៈ

### ២.៣.១ គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទកញ្ចក់

- **កញ្ចក់:** ត្រូវបានគេប្រើជាសម្ភារស្រោបដែលជាទូទៅរួមមានបន្ទះកញ្ចក់ ពុម្ពកញ្ចក់ កញ្ចក់ស្រូបកម្តៅ (ចាំង ផ្លាត) និងកញ្ចក់ខុប
- **បន្ទះកញ្ចក់ធម្មតា:** ទទឹង ៣មម, ៥០៨មម ឬ៦១០mm និង៩៦០មម ត្រូវបានគេប្រើប្រាស់ជាទូទៅ។ ក៏ប៉ុន្តែវាមានសុវត្ថិភាពជាងក្នុងការប្រើប្រាស់បន្ទះកញ្ចក់ដែលមានកម្រាស់ ៤មម នៅតំបន់ដែលធ្លាក់ ព្រិល ទឹកកក និងមានខ្យល់ និងនៅក្នុងផ្ទះបៃតងស្តើងៗ
- **កញ្ចក់ថ្លា:** ការបញ្ចូលពន្លឺមានកម្រិតខ្ពស់បំផុត។ ជាពិសេសការបញ្ជូនពន្លឺដែលអាចមើលឃើញគឺ ៩០%
- **ប្រភេទបន្ទះកញ្ចក់:** ផ្ទៃលើកញ្ចក់មានរាងមិនធម្មតា ដូច្នេះការបញ្ជូនពន្លឺគឺមានកម្រិតទាបជាងកញ្ចក់ថ្លា ប៉ុន្តែវាមានគុណសម្បត្តិអាចបញ្ចូលពន្លឺស្មើៗគ្នាទៅក្នុងផ្ទះបៃតង

- **កញ្ចក់ស្រូបកម្តៅ (កញ្ចក់ផ្លាត)** : គេលាយលោហៈអុកស៊ីតតិចតួចដូចជានីកែល ឬប៉ូតាស្យូមជាមួយកញ្ចក់ដើម្បីឱ្យវាអាចស្រូប ឬចាំងផ្លាតកាំរស្មីដែលមានរលកកម្តៅយូរ ដូច្នេះអាចបញ្ចុះសីតុណ្ហភាពនៅក្នុងផ្ទះក្នុងកំឡុងពេលថ្ងៃ និងកែលម្អទ្រនាប់កម្តៅនៅពេលយប់។

**២.៣.២ គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទប្លាស្ទិច**

❖ ជាប្រភេទហ្វីមប្រឆាំងនឹងតំណក់ទឹក

- ប្រភេទហ្វីមនេះអាចជ្រៀបទឹកនៅលើផ្ទៃខាងលើ ហើយដំណក់ទឹកក្លាយជាហ្វីមស្តើងពេលដែលទឹកប៉ះទៅលើវា។ ហ្វីមនេះមានលក្ខណៈល្អបែបនេះ
- វាជាសម្ភារសម្រាប់ប្រក់ផ្ទះបៃតងដែលមិនជ្រាបទឹកនៅលើផ្ទៃលើ។

❖ សម្ភារហ្វីមប្លាស្ទិកទន់

**១. ប្រភេទហ្វីម ប៉ូលីវីនីលក្លរ៉ាយ** PVC (Poly Vinyl Chloride)

- មាំ និងជាប់បានយូរ(អាចប្រើបានពី ៥-៨ឆ្នាំ): ធន់ទ្រាំបានល្អបំផុត និងប្រើប្រាស់បានយូរ
- ការរក្សាទុករយៈពេលយូរៈ ការបង្កើតឱ្យមានស្រទាប់ហ្វីមឱ្យមានប្រេងពិ សេសអាចឱ្យគេរក្សាទុកវាបានយូរ
- មិនឆ្លងនឹងកម្តៅបានល្អបំផុតៈ វាមានបរិមាណតិចបំផុតចំពោះកាំរស្មីព្រះអាទិត្យហើយវាមិនឆ្លងកម្តៅខ្លាំងបំផុតនៅពេលយប់
- បញ្ជូនបានល្អបំផុតៈ ខ្លាំងទប់ទល់នឹងការបំពុលផ្សេងៗ ហើយអាចរក្សាបញ្ជូនពន្លឺបានរយៈពេល យូរ។
- រារាំងអព្ទៈ រារាំងការបង្ករអ័ព្ទនៅពេលព្រឹក និងល្ងាចហើយការបញ្ជូនពន្លឺមានលក្ខណៈល្អ
- ការជ្រៀតចូលកាំរស្មីUV: វាមានលក្ខណៈសមរម្យសម្រាប់ការដាំដុះដំណាំយកផ្លែនិងបន្លែពីព្រោះ វាបញ្ចេញកាំរស្មី UV ហើយដំណាំដុះបានល្អព្រមជាមួយវត្តមានរបស់សត្វឃ្មុំ។

**២. ហ្វីម ប៉ូលីហ្វីន** Polyefin(PO)

- ទម្ងន់ស្រាលជាមួយនឹងសម្ភារថ្មី(កម្លាំងទំនាញពិសេសមួយ)
- ទម្រង់ស្រទាប់ច្រើន(ស្រទាប់ការពារធូលី, ស្រទាប់ខ្លាំង, ស្រទាប់ការពារកម្តៅ, ស្រទាប់រក្សាភាពថ្លា, ស្រទាប់កាកសំណល់, ស្រទាប់ជាន់ៗគ្នា)ដែលអាចមានរយៈពេលយូរ(៥-៨ឆ្នាំ)
- ជាមួយនឹងបច្ចេកវិជ្ជាទំនើប សម្ភារនេះអាចប្រើប្រាស់បានរយៈពេលយូរ ដោយសារតែវាអាចធន់ទ្រាំបានល្អ
- វាអាចធន់នឹងកម្តៅបានល្អ និងអាចប្រើប្រាស់បានល្អនៅរដូវត្រជាក់
- វាអាចរក្សាបានរយៈពេលយូរនូវកម្តៅល្មមពីព្រោះវាប្រើប្រាស់សម្ភាររារាំងការលិចទឹក (អាចការពារធូលី និងមេរោគផ្សិត)
- អាចបញ្ជូនពន្លឺពី ៣០០nm ទៅកាំរស្មីដែលមាន ៨០០nm ហើយអាចធ្វើឱ្យដំណាំលូតលាស់ បានល្អ និងសត្វល្អិតដូចជាឃ្មុំមានចលនាសកម្ម។

**៣. ហ្វីម ប៉ូលីអេទីឡែន** Polyethylene (PE)

**៤. ហ្វីម អេទីឡែនអាសេទិចអាស៊ីត** Ethylene acetic acid (EAA)

**៥. ហ្វីមដែលមានតែ ប៉ូលីអូឡេហ្វីន** Polyolefin (PO)

❖ **ការប្រៀបធៀបលក្ខណៈហ្វីមទន់:**

- លក្ខណៈសមត្ថភាពបញ្ជូនពន្លឺគឺស្ថិតនៅក្នុងលំដាប់លំដោយដូចតទៅ (ប៉ូលីអេទីឡែន >អេទីឡែនអាសេទិចអាស៊ីត > ប៉ូលី វីនីល ក្លរ៉ាយ) ហើយ ការបំភាយកាំរស្មីគឺ៨០% សម្រាប់ ប៉ូលីអេទីឡែន និង៤៨% សម្រាប់ អេទីឡែនអាសេទិចអាស៊ីត
- សមត្ថភាពនៃការជ្រៀបចូលមានលំដាប់ (ប៉ូលីអេទីឡែន >អេទីឡែនអាសេទិចអាស៊ីត > ប៉ូលី វីនីល ក្លរ៉ាយ) បន្ទាប់ពីមានការបំពុលបរិយាកាស កើតឡើង។

❖ **ហ្វីមប្លាស្ទិចរឹង**

- ហ្វីម ប៉ូលីអ៊ីស្ទើ Polyester រឹង (PET)
- ហ្វីមជ័រ ហ្វ័រីន(Fluorine)

# មេរៀនទី៣ ការគ្រប់គ្រងបរិស្ថានដាំដុះក្នុងផ្ទះបៃតង

## ៣.១ បរិស្ថានពន្លឺ

ពន្លឺមិនគ្រាន់តែជាធាតុសំខាន់ នៅក្នុងផលិតកម្មដំណាំ ដែលជាប្រភពថាមពលសម្រាប់ធ្វើរស្មីសំយោគប៉ុណ្ណោះទេ ប៉ុន្តែពន្លឺជាប់ពាក់ព័ន្ធយ៉ាងខ្លាំងដល់ការលូតលាស់ និងការអភិវឌ្ឍដូចជាប្រតិកម្មរបស់ពន្លឺទៅលើការលូតលាស់ និងការចេញផ្កា។

### ៣.១.១ បរិស្ថានពន្លឺ និងការលូតលាស់ដំណាំ

ពន្លឺមានតួនាទីក្នុងការធ្វើរស្មីសំយោគ, រយៈពេលទទួលពន្លឺ និងការបង្កើតសារពាង្គកាយការលូតលាស់ របស់ដំណាំ ហើយការលូតលាស់ទាំងនេះជះឥទ្ធិពលដោយគុណភាពពន្លឺ, អាំងតង់ស៊ីតេ និងទីតាំងដាំដុះ។

- រស្មីសំយោគ
- ការឆ្លើយតបទៅនឹងរបបពន្លឺ
- ឥទ្ធិពលរបស់ពន្លឺទៅលើការលូតលាស់របស់ដំណាំ

❖ **គុណភាពពន្លឺ និងការលូតលាស់ដំណាំ**

- ប្រសិទ្ធភាពរស្មីសំយោគៈ ពន្លឺពណ៌ក្រហម
- ដំណុះគ្រាប់ និងគុណភាពន្លឺៈ ពន្លឺពណ៌ក្រហម និងកាំរស្មីពន្លឺសឹងតែមើលមិនឃើញ
- ពន្លឺពណ៌ខៀវបង្ហាញពីការលេចឡើងរបស់ សមាសភាពគីមីដែលបង្កើតជាពណ៌ នៅក្នុងដំណាំ
- កាំរស្មី យូវី (UV) មានប្រវែងខ្លី និងក្រាស់នៅក្នុងស្លឹក
- កាំរស្មី យូវី (UV) ជម្រុញការបង្កើតស្ករ

❖ **បរិមាណពន្លឺ និងការលូតលាស់ដំណាំ**

- សកម្មភាពរស្មីសំយោគទៅដល់ចំណុចឆ្អែកបន្ទោរអាចបង្កើនអត្រាលូតលាស់ដំណាំ
- ការបង្កើតរូបរាងប្រែប្រួលទៅតាមអាំងតង់ស៊ីតេពន្លឺ
- កោសិកា mesophyll និងកោសិកាដទៃទៀតរបស់ស្លឹកក្លាយជាទំហំតូចហើយបរិមាណ chlorophyll ថយចុះ
- អាំងតង់ស៊ីតេពន្លឺចុះទាប រារាំងការពង្រីកទំហំឬសរបស់ពពួកបន្លែ, ខ្ទឹមស និងខ្ទឹមបារាំង
- ការថយចុះពន្លឺនាំឱ្យថមថយការកើនឡើងទំហំផ្លែ

❖ **ពន្លឺ និងការលូតលាស់ដំណាំ**

- ពន្លឺ គឺជាធាតុសំខាន់បំផុតសម្រាប់ធ្វើរស្មីសំយោគគឺ អាំងតេស៊ីពន្លឺ និងគុណភាពពន្លឺ
- ចំណុចទូទាត់ពន្លឺ
- ចំណុចឆ្អែតរបស់ពន្លឺ
- អត្រារស្មីសំយោគជាអតិបរមា

❖ **រយៈពេលពន្លឺ និងការលូតលាស់**

- រយៈពេលមួយថ្ងៃពាក់ព័ន្ធនឹងប្រតិកម្មដំណេក និងការចេញផ្ការបស់រុក្ខជាតិ ការវិវត្តសារពាង្គកាយ និងការអភិវឌ្ឍរបស់រុក្ខជាតិ
- រយៈពេលថ្ងៃៈ ចំនួនថ្ងៃតិចត្រូវការចាំបាច់ដើម្បីឱ្យចេញផ្កា

- មើមខ្ទឹមស និងខ្ទឹមបារាំងបង្កើតឡើងនៅសីតុណ្ហភាពខ្ពស់ និងរយៈពេលថ្ងៃវែង បន្ទាប់ដំណើរការសីតុណ្ហភាពទាប។
- មើមដំឡូងបារាំងអាចពង្រីកទំហំរបស់វាក្នុងលក្ខខណ្ឌតែមួយគត់(រយៈពេលពន្លឺ១២ម៉ោង និងយប់ ១២ ម៉ោង ក្នុងមួយថ្ងៃ។
- បង្កើនផ្កាឈ្មោលក្នុងពេលតែមួយពេលត្រជាក់

❖ **ការឆ្លើយតបទៅនឹងរបបពន្លឺ**

- ប្រតិកម្មរបស់សារពាង្គកាយដែលបង្កឡើងដោយផ្លាស់ប្តូររយៈពេលលូតលាស់របស់រុក្ខជាតិ
- ការឆ្លើយតបទៅនឹងរយៈពេលនៃការអភិវឌ្ឍរបស់ផ្កា
- ការឆ្លើយតបរបស់ពន្លឺគឺ ប្រែប្រួល ៥៨០-៦៨០mm ពន្លឺពណ៌ទឹកក្រូច ឬពណ៌ក្រហម

A B




រុក្ខជាតិដែលត្រូវការពន្លឺរយៈពេលខ្លី រុក្ខជាតិដែលត្រូវការពន្លឺរយៈពេលវែង

**រូបភាព ទី២៩** ៖ ការចេញផ្កាក្រោមលក្ខខណ្ឌរយៈពេលថ្ងៃខ្លី (A) និងរយៈពេលថ្ងៃវែង (B)




**រូបភាពទី៣០៖** ការចេញផ្កាដែលយោងទៅលើពន្លឺ

❖ **ហ្វីតូក្រូម**

- ការចេញផ្កាអាស្រ័យទៅនឹងការស្រូបយកពន្លឺនៃហ្វីតូក្រូមក្រហម (Pr) និងហ្វីតូក្រូមក្រហមខ្លាំង (Pfr)
- ប្រតេអ៊ីនដែលផលិតសារធាតុពណ៌របស់រុក្ខជាតិស្រូបយកពន្លឺ និងផ្លាស់ប្តូរវិសាលភាពស្រូបរបស់វា ក្នុងលក្ខណៈត្រលប់ទៅដូចដើមវិញ
- វាពាក់ពន្ធ័ទៅនឹងដំណើរការបាតុភូតគីមីរូបសាស្រ្តផ្សេងៗ
- ជម្រុញការចេញផ្កាស្រូវបាឡេដែលមានដើមវែង ប៉ុន្តែវារារាំងការចេញផ្កាពពួកសណ្តែក
- ការផ្ទេរសេនទៅក្នុងរុក្ខជាតិ វាដំណើរការដោយកម្រិត ហ្វីតូក្រូមក្រហម និងហ្វីតូក្រូមក្រហមខ្លាំង ដែលមានន័យថារុក្ខជាតិអាចរកឃើញ ពេលវេលាដែលហ្វីតូក្រូមផ្លាស់ប្តូរទៅ ៦០% ក្នុងកំឡុងពេលថ្ងៃ ហើយផ្លាស់ប្តូរត្រលប់ទៅ និងហ្វីតូក្រូមក្រហម វិញនៅពេលយប់
- ការជម្រុញការចេញផ្កានៃរុក្ខជាតិដែលដើមវែង។ ពេលបរិមាណ ហ្វីតូក្រូមក្រហមខ្លាំង នៅក្នុងរុក្ខជាតិមានច្រើន(ពេលដែលវាមិនត្រូវបានផ្លាស់ប្តូរទៅ ហ្វីតូក្រូមក្រហម ដោយពន្លឺក្រហម នៅពេលយប់ក្រោមលក្ខខណ្ឌតែមួយគត់។ បរិមាណហ្វីតូក្រូមមានវត្តមានក្នុងទម្រង់ជា ហ្វីតូក្រូមក្រហមខ្លាំង មានការកើនឡើងពីព្រោះវាមិនអាចផ្លាស់ប្តូរទៅជា ហ្វីតូក្រូមក្រហម នៅសារពាង្គកាយរុក្ខជាតិ។

**៣.១.២ លក្ខណៈបរិស្ថានពន្លឺនៅក្នុងផ្ទះបៃតង**

❖ **ការកាត់បន្ថយបរិមាណពន្លឺ**

- ការផ្តល់ម្លប់ដែលអាចកាត់បន្ថយ ១៥-២០% ចំពោះផ្ទះកញ្ចក់ ៥%ចំពោះផ្ទះបៃតងផ្លាស្ទិច
- ការចាំងផ្លាត និងការបញ្ជូនពន្លឺដោយសម្ភារស្រោប: អត្រាស្រូបពន្លឺ ១%(២-៦%ធូលី ដំណក់ទឹក)

- ការបំពុល និងការជាប់ស្អិតសម្ភារស្រោបៈ ពេលសារធាតុផ្លាស្ទិចត្រូវបានគេដាក់វាជួយបង្កើនសមត្ថភាពឆ្លងចរន្ត ហើយអាចបង្កើនការស្អិតជាប់នៃធូលីបាន ៥០-៦០%។ ដំណក់ទឹកតូចៗក៏អាចកាត់បន្ថយការបញ្ជូនពន្លឺ និងបង្កើតទៅជាក្រដាស់ហ្វីបមួយដែលរឹងមាំ
- ទិសដៅផ្ទះបៃតង និងការបញ្ជូនពន្លឺៈ នៅរដូវរងានៅតំបន់ខាងកើត និងខាងលិច ជាតិអំបិលមានកម្រិត ២៦% ខ្ពស់ជាងតំបន់ខាងជើង និងត្បូង ហើយខ្ពស់ជាង ៨៤% នៅពេលរសៀល។ ប៉ុន្តែវាមានលក្ខណៈ បញ្ច្រាស់មកវិញនៅរដូវក្តៅ។

❖ **ការផ្លាស់ប្តូរគុណភាពពន្លឺ**

- ការបំភាយរលកកាំរស្មីវែងខុសគ្នា
- ការបំភាយកាំរស្មី យូវី (UV) កើនឡើងៈ ការបង្កើតឱ្យមានកាំរស្មីពណ៌
- ការរារាំងបំភាយកាំរស្មី (UV): ការកំចាត់សត្វល្អិត
- កែតម្រូវសមាមាត្រ R/FR : ការគ្រប់គ្រងការលូតលាស់កម្ពស់ដើម

❖ **ការប្រែប្រួលក្នុងមួយថ្ងៃ**

- ការដាំដុះមុនរដូវកាលៈ ការធ្លាក់ទឹកសន្សើមនៅរដូវរងា ពេលវេលាសម្រាកមិនចេញផ្លែ
- ប្រើប្រាស់ចង្កៀងអំពូលច្រើនរយ ដើម្បីបង្កើនកម្តៅ

❖ **ភាពមិនស្មើនៃការចែកចាយពន្លឺ**




**រូបភាពទី៣១៖** ការបញ្ជូនពន្លឺ

### ៣.១.៣ ការកែលម្អបរិស្ថានពន្លឺនៅក្នុងផ្ទះបៃតង

- រលកអេឡិចត្រូម៉ាញ៉េទិច
- បំណែកតូចៗ: ហ្វូតុង
- រលកពន្លឺៈ រលកពន្លឺ
- កាំរស្មីដែលមានប្រសិទ្ធិភាពៈ ចាប់ពី ៣០០ទៅ ៨០០nm
- កាំរស្មីសម្រាប់ធ្វើរស្មីសំយោគដែលមានប្រសិទ្ធិភាពៈ ចាប់ពី ៤០០ទៅ ៧០០nm
- ការបញ្ចេញកាំរស្មីព្រះអាទិត្យៈ ថាមពលដែលបញ្ចេញពន្លឺដែលត្រូវទទួលក្នុងមួយខ្នាតពេលវេលា ក្នុងមួយខ្នាតផ្ទៃក្រឡាពន្លឺផ្ទាល់បូកជាមួយពន្លឺរាយប៉ាយ, W/m2, Kcal/m2/h
- បរិមាណពន្លឺៈ បរិមាណថាមពលរបស់ពន្លឺ, អាំងតង់ស៊ីតេ=អាំងតង់ស៊ីតេពន្លឺ, ភាពចាំងចែងនៃពន្លឺ
- ការបញ្ចេញពន្លឺសម្រាប់ធ្វើរស្មីសំយោគ (PAR): ត្រូវបានសំដែងចេញជាចំនួន Photon នៅក្នុងកម្រិតរលកប្រវែង ៤០០ទៅ ៧០០nm μmol/m2/s PAR

- បរិមាណពន្លឺថ្ងៃៈ ពេលវេលាដែលអាំងតង់ស៊ីតេពន្លឺលើសពី ១៩,៤ W/m2 PAR (៨៨,៩ µmol/ m2/s PAR)
- គុណភាពពន្លឺៈ ពន្លឺថ្ងៃ និងការគ្រប់គ្រងអាំងតង់ស៊ីតេពន្លឺ

❖ **ការបង្កើនបរិមាណពន្លឺ និងប្រសិទ្ធភាពប្រើប្រាស់ពន្លឺ**

- ការជ្រើសរើសគ្រោងឆ្អឹងផ្ទះដាំៈ សម្ភាររាងបំពង់ និងចម្រឹងដែកមានតម្លៃថោក
- ការជ្រើសរើស និងសម្អាតសម្ភារស្រោបៈ ក្រដាសផ្លាស្ទិក មិនជ្រៀបទឹក អាចឆ្លងចរន្ត
- ការកែតម្រូវទិសនៃការតម្លើងផ្ទះបៃតងៈ កើត-លិចនៅរដូវរងា និងត្បូង-ជើង នៅរដូវក្តៅ (ត្រូវវាស់សីតុណ្ហភាពនៅរដូវក្តៅ)
- ប្រើប្រាស់សម្ភារចំណាំងផ្លាត Shatou: វាអាចកើនឡើងពន្លឺ ១២% ពេលប្រើប្រាស់ចំណាំងផ្លាត
- វិធីសាស្ត្រដាំកូនដំណាំៈ ដាំដោយទុកចន្លោះគុម្ពទូលាយ ប៉ុន្តែដាំញឹកនៅចំទិសពីកើតទៅលិច

❖ **ការដាក់បន្ថែមពន្លឺសប្បនិម្មិត**

- នៅក្នុងករណីដាក់ពន្លឺបន្ថែម ឥទ្ធិពលនៃការកើនឡើងនៃការបញ្ចេញពន្លឺ ពីចំណុចពន្លឺតិចទៅពន្លឺខ្លាំងកើនឡើង(ប៉ុន្តែត្រូវធ្វើការកែតម្រូវទៅតាមតម្រូវការ)
- អាស្រ័យទៅតាមប្រភេទពន្លឺសប្បនិម្មិត គុណភាពពន្លឺ និងបរិមាណពន្លឺគឺខុសពីគ្នា។

**១. ប្រភេទពន្លឺសប្បនិម្មិត**

- អំពូលមូលសៈ ជាប្រភេទកាំរស្មីមើលមិនឃើញ ដែលត្រូវបានគេប្រើជាសំខាន់សម្រាប់មួយថ្ងៃ, ប្រសិទ្ធភាពបញ្ចេញពន្លឺ ១០-២០%
- អំពូលម៉ែតៈ អំពូលម៉ែតមានប្រសិទ្ធិភាព ៤ដង បើប្រៀបធៀបជាមួយចង្កៀងពន្លឺពណ៌ស។ គេអាចប្រើអំពូលម៉ែតសម្រាប់បំភ្លឺការដាំដុះដំណាំ ហើយអាចប្រើជិតនឹងដំណាំ ប៉ុន្តែត្រូវមានអាំងតង់ស៊ីតេទាប (១០ µmol/m2/s)
- អំពូលប្រើកម្លាំងអគ្គិសនីសម្ពាធខ្ពស់ បញ្ចេញពន្លឺដោយកម្លាំងអគ្គិសនីដែលបំភាយ ចេញពីលោហៈ
- អំពូលប្រើបារតៈ បញ្ចេញពន្លឺភ្លឺចាំង ប៉ុន្តែមិនអាចបញ្ចេញបានឆ្ងាយទេ ដោយសារតែពន្លឺដែលពទ្ធ័ជុំវិញមានកម្រិតកម្លាំងខ្សោយ
- អំពូល (Metal halide etc) បញ្ចេញពន្លឺមានលក្ខណៈស្រដៀងគ្នាទៅនឹងពន្លឺព្រះអាទិត្យ
- អំពូលប្រើសូដ្យូមសម្ពាធខ្ពស់ៈ មានប្រសិទ្ធិភាពខ្ពស់បំផុត ពីព្រោះរុក្ខជាតិគ្មានផ្ទុកពន្លឺពណ៌ក្រហម ទេ។ ពន្លឺនេះមានពណ៌លឿង ពីព្រោះវាបំភាយតែ ៥៩០nm (៥៩០០A°)។







**រូបភាពទី៣២៖** ការប្រើប្រាស់អំពូលផ្សេងៗគ្នាក្នុងការដាំដុះដំណាំ

**២. អំពូល អិលអ៊ីឌី**

- បញ្ចេញពន្លឺតែមួយពណ៌ដែលមានរលកពន្លឺពិសេសដែលត្រូវការសម្រាប់ការលូតលាស់រុក្ខជាតិមិនអាចរួមបញ្ចូលកាំរស្មីមើលមិនឃើញ ហើយអាចត្រូវបានគេប្រើប្រាស់សម្រាប់ការបំភ្លឺជិតៗ។ ពន្លឺក្រហម+ក្រហម **អិលអ៊ីឌី** សម្រាប់អាំងតង់ស៊ីតេពន្លឺលើសពី ២១០០ μmol/m$^2$/s
- មានប្រសិទ្ធភាពខ្ពស់ក្នុងការបញ្ចេញពន្លឺ ហើយប្រើប្រាស់កម្លាំងភ្លើងតិច
- គេអាចធ្វើការផ្លាស់ប្តូរកម្រិតពន្លឺបានយ៉ាងងាយ
- អំពូល **អិលអ៊ីឌី** មានទម្ងន់ស្រាល អាចប្រើប្រាស់បានយូរ ហើយស៊ីភ្លើងតិច
- គេប្រើវាដោយចរន្តភ្លើង ឌីស៊ី ឬ អេស៊ី
- ជាប្រភេទអំពូលដែលគ្មានត្រូវអេឡិចត្រូត។ វាមានអាយុកាលយូរដោយសារតែមិនត្រូវការអេឡិចត្រូត។ ការចែកចាយពន្លឺរបស់វាគឺមានលក្ខណៈស្រដៀងទៅនឹងពន្លឺធម្មជាតិ និងប្រសិទ្ធិភាពរបស់វាគឺ ១៣០ lm/w
- **អិលអ៊ីឌី**: ត្រូវបានទទួលចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះហើយមានពាក្យពេញដែលប្រើប្រាស់ចរន្តអគ្គិសនីហើយបញ្ចេញពន្លឺ។

**៣.២ បរិស្ថានសីតុណ្ហភាព និងសំណើម**

- ល្បឿននៃការលូតលាស់ដំណាំពេលវេលានៃការប្រមូលផលគុណភាពនិងការការពារជំងឺ
- វាមានឥទ្ធិពលផ្ទាល់

- កត្តាសីតុណ្ហភាពជះឥទ្ធិពលទៅលើបរិមាណទឹកដែលរំហួតចេញទៅបរិយាកាស សម្ពាធទឹក និងធ្វើឱ្យផ្លាស់ប្តូរបរិមាណសំណើម
- អត្ថន័យនៃសីតុណ្ហភាពពាក់ព័ន្ធនឹងការគ្រប់គ្រងការលូតលាស់ និងគុណភាពដំណាំ
- សំណើម គឺខុសពីបរិមាណចំហាយទឹក បរិមាណញើស និងសំណើមទាំងស្រុង ដោយអាស្រ័យទៅលើទម្ងន់ ឬមាឌខ្យល់

### ៣.២.១ បរិស្ថានសីតុណ្ហភាព និងការលូតលាស់ដំណាំ

- ការគ្រប់គ្រងសីតុណ្ហភាពនៅក្នុងផ្ទះបៃតងទាមទារឱ្យមានការបញ្ចេញបញ្ចូលខ្យល់ ការបង្កើនកម្តៅ និងបន្ថយកម្តៅដូច្នេះវាជាមូលដ្ឋានគ្រឹះក្នុងការឆ្លើយតបទៅនឹងសីតុណ្ហភាពដែលត្រូវការសម្រាប់ដំណាំ។

❖ **រស្មីសំយោគ និងដំណកដង្ហើមដោយសីតុណ្ហភាព**

- អ្វីទៅជារស្មីសំយោគៈ កាបូនអ៊ីដ្រាតដែលជាផលិតផលរស្មីសំយោគ ក្លាយជាបន្សំរបស់រុក្ខជាតិ
- ដូចដែលបង្ហាញនៅក្នុងរូបភាពខាងក្រោម សីតុណ្ហភាពសមរម្យសម្រាប់ដំណើរការរស្មីសំយោគគឺ ស្ថិតនៅក្នុងរង្វង់ ២០°C ចំណែកឯការធ្វើរស្មីសំយោគសរុបដកដំណកដង្ហើម គឺជាផ្នែកមួយយ៉ាងធំ។
- ក្នុងលក្ខខណ្ឌពន្លឺតិច រស្មីសំយោគសរុបគឺទាបហើយមាឌវាដូចគ្នា ដូច្នេះសីតុណ្ហភាពសមស្របក៏ទាបដែរ
- ដើម្បីធានារ៉ាប់រងផ្លែស្លឹក កូនរុក្ខជាតិបង្កើនអត្រាដំណកដង្ហើមដោយសីតុណ្ហភាពខ្ពស់ជាងសីតុណ្ហភាពសម្រាប់ធ្វើរស្មីសំយោគបន្តិច ហើយបង្កើនចំនួនស្លឹក




**រូបភាពទី៣៣៖** ការធ្វើរស្មីសំយោគរុក្ខជាតិ

- ជាដំណើរការដែលរុក្ខជាតិសំយោគសារធាតុសរីរាង្គពី $CO_2$ និង $H_2O$ ដោយប្រើប្រាស់ថាមពលព្រះអាទិត្យ
- ATP និង NADPH ផ្លាស់ប្តូរទៅជាថាមពលសេរី (ប្រតិកម្មគីមី) ដោយស្រូបយកថាមពលពន្លឺតាមរយៈ Carotenoids, chlorophyllab (ដែលមានវត្តមានក្នុងទម្រង់ភ្ជាប់ជាមួយប្រូតេអ៊ីនដទៃនៅក្នុងប្រព័ន្ធរស្មីសំយោគ II) នៅក្នុង Thylakoids និង $CO_2$។

## ១. ប្រតិកម្មពន្លឺ

- នៅពេលដំណើរការចាប់យកថាមពលពន្លឺ, ម៉ូលេគុលទឹកបំបែកទៅជា H2 និង O2 ដែល ឯករាជ្យពីសីតុណ្ហភាព(ប្រតិកម្ម Hill)
- អុកស៊ីសែនដែលបំភាយចេញជាឧស្ម័ន និងអ៊ីដ្រូសែនបង្កើតជា ATP តាមរយៈNADP (អ៊ីដ្រូសែន, ប្រព័ន្ធដឹកជញ្ជូនអេឡិចត្រុង) និងពន្លឺ-អុកស៊ីតកម្ម
- Hill ចែកចេញជាប្រតិកម្មអុកស៊ីតកម្មគីមី និងថាមពលពន្លឺដែលបំលែងទៅជាថាមពល ATP ឬ NADPH ។

## ២. ប្រតិកម្មគ្មានពន្លឺ(ងងឹត)

- ប្រតិកម្មគ្មានពន្លឺ ឬពេលងងឹត គឺជាប្រតិកម្មគីមីដែលមានឥទ្ធិពលយ៉ាងខ្លាំងដោយសីតុណ្ហភាព ហើយមិនទាក់ទងទៅនឹងពន្លឺទេ
- ដំណើរការនៃការផលិតសារធាតុស្ករដោយប្រើប្រាស់ CO2, H2O, ATP ដែលបន្ថែមអាតូមអ៊ីដ្រូសែន និងអេឡិចត្រុងនៅឱ្យ CO2
- កាបូនអ៊ីដ្រាតត្រូវបានបង្កើតឡើង នៅពេលនេះសារធាតុស្ករបានភ្ជាប់ជាមួយ CO2 បង្កើតជា Phosphoglyceric acid (PGA) ក្នុងក្រុមរុក្ខជាតិ C3 និង malic acid នៅក្នុងក្រុមរុក្ខជាតិ C4។

## ៣. ការដកដង្ហើម និងសីតុណ្ហភាព

- នៅពេលដែលសីតុណ្ហភាពកើនឡើងសកម្មភាពធ្វើរស្មីសំយោគក៏កើនឡើងដែរ ហើយនៅពេលដែលសីតុណ្ហភាពឡើងកាន់តែខ្ពស់ គេឆ្ងល់ថាហេតុអ្វីការធ្វើរស្មីសំយោគទៅជាខ្សោយទៅវិញ។ ការធ្វើរស្មីសំយោគដោយខ្លួនឯង (បរិមាណរស្មីសំយោគសរុប) មិនថយចុះទេ ក្រោមលក្ខខណ្ឌ សីតុណ្ហភាពខ្ពស់ ក៏ប៉ុន្តែនៅពេលសីតុណ្ហភាពខ្ពស់ខ្លាំង ដំណកដង្ហើម (ការដកដង្ហើមដោយប្រើពន្លឺ) និងបរិមាណរស្មីសំយោគដែលនៅសេសសល់ (បរិមាណរស្មីសំយោគពិតប្រាកដ) ដកចេញផលិតផល រស្មីសំយោគដែលបានប្រើប្រាស់។

**របៀបដែលរុក្ខជាតិដុះលូតលាស់**




**រូបភាពទី៣៨៖** រុក្ខជាតិលូតលាស់ដោយរស្មីសំយោគ និងការដកដង្ហើម

## ៤. សីតុណ្ហភាព និងចរន្តនៃផលិតផលរស្មីសំយោគ

❖ ចលនា និងសីតុណ្ហភាពរបស់សារធាតុចិញ្ចឹម

❖ នៅក្នុងករណីភាគច្រើន រស្មីសំយោគនៅក្នុងដំណាំឈើហូបផ្លែ និងបន្លែបានទៅជាសមាសធាតុស្ករដែលមានទម្រង់មិនអាចរលាយក្នុងទឹកដែលគេហៅថា ម្សៅដែលស្តុកទុកបណ្តោះអាសន្ននៅក្នុងស្លឹក និងផ្លាស់ប្តូរទៅជាសារធាតុស្ករ អាស៊ីតអាមីណេ។ល។

❖ **ការចែកចាយផលិតផលរស្មីសំយោគ**

- ការចែកចាយដោយផ្នែកផលិត-ប្រើប្រាស់ (តម្រូវការ -ផ្គត់ផ្គង់): ផលិតផលរស្មីសំយោគរបស់ស្លឹកគឺ ជាតំបន់ដែលមានសកម្មភាពសរីរៈសាស្ត្រ ឬប្រតិកម្មលូតលាស់គឺខ្លាំង(ផ្នែកលើដីចំណុចលូតលាស់ក្រោមដី)
- សារធាតុចិញ្ចឹមលើ ៩0% ជាសារធាតុកាបូនអ៊ីដ្រាត និងសមាសធាតុស្ករ សាការ៉ូស
- កំហាប់ សាការ៉ូស ក្នុងស្លឹកគឺកម្រិតខ្ពស់ក្នុងកោសិកា Mesenchymal ជាកោសិកា Mesophyll
- ការពិតកំហាប់សារធាតុស្ករគឺខ្ពស់ជាកោសិកាដែលនៅជុំវិញដែលបញ្ជាក់ថាសារធាតុស្ករធ្វើចលនាយ៉ាងសកម្មទប់ទល់នឹងជម្រាលសក្តានុពលសារធាតុគីមី។

❖ **សីតុណ្ហភាព និងការលូតលាស់**

- សីតុណ្ហភាពមានឥទ្ធិពលលើការពន្លូតកោសិកា និងចែកកោសិកា
- ពេលវេលាប្រមូលផលផ្លែគឺ មានរយៈពេលខ្លីជាង នៅពេលដែលសីតុណ្ហភាពក្នុងរយៈពេល ២៤h ខ្ពស់ជាងកម្រិតសីតុណ្ហភាពលូតលាស់ធម្មតារបស់ដំណាំ
- នៅពេលសីតុណ្ហភាពខ្ពស់ជាង ឬទាប ១៨$^{0}$Cពេលនោះទំហំផ្លែទៅជាតូច
- នៅពេលដែលសីតុណ្ហភាពលូតលាស់កាន់តែខ្ពស់ ពេលនោះកម្តៅក៏កាន់តែជ្រៀតចូលក្នុងផ្លែ ប៉ុន្តែវាមានទំនាក់ទំនងជាវិជ្ជមានជាមួយអាំងតង់ស៊ីតេពន្លឺ
- DIF (ការខុសគ្នារវាងសីតុណ្ហភាពពេលថ្ងៃ និងយប់) ដើម្បីត្រួតពិនិត្យទីធ្លាសម្រាប់ការលូតលាស់ដំណាំ
- ឥទ្ធិពលសីតុណ្ហភាពលើការលូតលាស់ដំណាំ
- ការខូចខាតដំណាំដោយសីតុណ្ហភាពត្រជាក់: សីតុណ្ហភាព -១ ទៅ -៣ °C ធ្វើឱ្យជាលិកាកក ហើយស្រទាប់ Plasma នឹងរងការបំផ្លិចបំផ្លាញ ហើយជាចុងក្រោយកោសិការុក្ខជាតិនឹងងាប់
- ការខូចខាតដំណាំដោយសីតុណ្ហភាពទាបៈ នៅពេលសីតុណ្ហភាពចាប់ពី0-១0°C វានឹងធ្វើឱ្យ មានលិចជ្រៀបកោសិកាដោយសារតែការផ្លាស់ប្តូរវគ្គស្រទាប់កោសិកាដែលបណ្តាលឱ្យខ្វះខាតសារធាតុចិញ្ចឹម។ កត្តាទាំងនេះនឹងនាំទៅរកការថយចុះការធ្វើរស្មីសំយោគ, ការរារាំងចលនាមេតាបូលីស និងការកើន ឡើងសារធាតុពុលក្នុងកោសិការុក្ខជាតិ...។ល។
- នៅសីតុណ្ហភាពខ្ពស់ការគ្រប់គ្រងសីតុណ្ហភាពគួរតែអនុវត្តន៍ទៅតាមអត្រារស្មីសំយោគដែលចុះខ្សោយ។

❖ **យន្តការរារាំងការលូតលាស់ដោយសីតុណ្ហភាព**

- ចាប់ផ្តើមជាមួយនឹងការផ្លាស់ប្តូរទម្រង់ ផូស្វូលីពីត នៃស្រទាប់ ប្លាស្មា ផ្សេងៗ
- ការផ្លាស់ប្តូរស្រទាប់ ប្លាស្មា បង្កើនកំហាប់ប្រភេទប្រតិកម្មអុកស៊ីសែន
- ការថយចុះសារធាតុខ្លាញ់, ប្រូតេអ៊ីន និង ឌីអិនអេ ដោយប្រភេទអុកស៊ីសែនសកម្ម
- បង្អាក់ដំណើរដំណកដង្ហើម និងការធ្វើរស្មីសំយោគ។

❖ **ឥទ្ធិពលរបស់សីតុណ្ហភាព**

- សីតុណ្ហភាពសមរម្យគឺ ១៥-២០ °C, លើ ៣០ °C រារាំងការលូតលាស់ឬសជញ្ជក់រារាំង ការពន្លូតប្រវែងឬស និងបន្ថយសមត្ថភាពការស្រូបយកសារធាតុចិញ្ចឹម
- សីតុណ្ហភាពក្រោម ១៣ °C ធ្វើឱ្យខ្វះខាតសារធាតុផូស្វ័រដែលបណ្តាលឱ្យមានការកើនឡើងសារធាតុពណ៌ក្នុងផ្លែប៉េងប៉ោះ។ សីតុណ្ហភាពក្រោម១០°C ថយចុះការស្រូបយកប៉ូតាស្យូម(K) និងអាសូត (N)។

❖ **គំរូនៃការគ្រប់គ្រងសីតុណ្ហភាពឱ្យបានសមស្រប**

- ការគ្រប់គ្រងមូលដ្ឋានគ្រឹះនៃសីតុណ្ហភាពគឺធ្វើយ៉ាងណាអាចបន្ថយសីតុណ្ហភាពមកត្រឹម ១°C ក្នុងរយៈពេលមួយម៉ោង
- ការគ្រប់គ្រងកម្តៅ

## ៣.២.២ លក្ខណៈសីតុណ្ហភាព និងសំណើមនៅក្នុងផ្ទះបៃតង

❖ **កម្តៅនៅក្នុងផ្ទះបៃតង**




**រូបភាពទី៣៥៖** ចលនាពន្លឺ និងកម្តៅក្នុងផ្ទះបៃតង

❖ **លក្ខណៈសីតុណ្ហភាពនៅក្នុងផ្ទះបៃតង**

- ពន្លឺព្រះអាទិត្យផ្ទាល់ និងពន្លឺរាយប៉ាយៈ ( ពន្លឺព្រះអាទិត្យ + រលកពន្លឺវែង ) = កម្តៅដែលត្រូវបានប្រើប្រាស់សម្រាប់ការរំហួត+កម្តៅខាងក្រៅដែលរួមមានចរន្តខ្យល់ចេញចូល+កម្តៅដែល+កម្តៅក្នុងផ្ទះបៃតង
- កម្តៅពេលយប់ៈ សីតុណ្ហភាពថយចុះនៅក្នុងផ្ទះបៃតងដោយសារតែផ្ទៃរាប និងដំណាំ
- ថាមពលកាឡូរីដែលស្រូបបានរៀងរាល់យប់ថាមពលពាក់កណ្តាលត្រូវស្តុកទុកក្នុងកំឡុងពេលថ្ងៃ។

❖ **លក្ខណៈសីតុណ្ហភាពនៅក្នុងផ្ទះបៃតង**

- សីតុណ្ហភាពពេលថ្ងៃ និងយប់ គឺមានលក្ខណៈខុសគ្នាខ្លាំង
- សីតុណ្ហភាពចែកចាយនៅក្នុងផ្ទះបៃតង ផ្នែកខាងដំបូលមានកម្រិតខ្ពស់នៅទិសខាងកើត

❖ **លក្ខណៈសីតុណ្ហភាពដីនៅក្នុងផ្ទះបៃតង**

- ទំហំផ្ទះបៃតងកាន់តែធំ កាន់តែមានការខុសប្លែកគ្នា សីតុណ្ហភាពពីកន្លែងមួយទៅកន្លែងមួយនៅក្នុងផ្ទះបៃតង។

០ **បរិស្ថានសំណើម**

- លក្ខខណ្ឌលូតលាស់, គុណភាព, ការបំភាយទឹក, ការបម្លាស់ទីនៃជីវម៉ាស់, ដង់ស៊ីតេកក្តាចង្រៃ
- នៅពេលសំណើមទាបនៅក្នុងផ្ទះបៃតង ពេលនោះ កង្វះខាតសារធាតុកាល់ស្យូមដែលធ្វើឱ្យមានការថយចុះទំហំស្លឹក និងកំពស់ដើម, ការកើនឡើងសត្វល្អិត។ល។
- ប្រសិនបើបង្កើនសំណើមក្នុងផ្ទះបៃតង វានឹងបណ្តាលឱ្យមានបញ្ហាមួយចំនួនកើតឡើង ដូចជាការខ្វះខាតសារធាតុចិញ្ចឹម ធ្វឱ្យការលូតលាស់ជាលិការុក្ខជាតិចុះខ្សោយ និងការកើនឡើងជំងឺលើរុក្ខជាតិ។

❖ **សំណើម និងចំហាយទឹក**

- សំណើមនៅខាងក្នុងផ្ទះបៃតងផ្លាស់ប្តូរអាស្រ័យទៅលើ បរិមាណចំហាយទឹកនៅក្នុងខ្យល់។ ជាទូទៅសំណើមគិតជាភាគរយ
- ភាគរយសំណើម(%)=សំណើមជាក់លាក់($g/m^3$)/ចំហាយទឹកឆ្អែត($g/m^3$)x100%

❖ **សំណើម និងសរីរៈវិទ្យារបស់ដំណាំ**

- ការបង្កើនសកម្មភាព: ការបង្កើនបរិមាណចំហាយទឹក ដែលបណ្តាលមកពីភាពខុសគ្នា បរិមាណចំហាយទឹករវាង សំណើមខ្យល់ និងលក្ខខណ្ឌ សំណើមខ្យល់។ ពេលដែលសំណើមកើនឡើងខ្ពស់ពេលនោះបរិមាណរំហួតពីរុក្ខជាតិថយចុះ។
- ការធ្វើរស្មីសំយោគ: ប្រសិនបើសំណើមកើនឡើងនៅពេលថ្ងៃ ពេលនោះ Stomata បើកទាំងស្រុង ដូច្នេះការស្រូបយក $CO_2$ របស់រុក្ខជាតិកើនឡើង ហើយអត្រារស្មីសំយោគកើនឡើង។
- ការលូតលាស់ និងគុណភាព: ការលូតលាស់រុក្ខជាតិគឺល្អ នៅក្នុងករណីសំណើមខ្ពស់ ដឹងតែគ្រប់ករណីទាំងអស់ ប៉ុន្តែសំណើមខ្ពស់ពេក រារាំងការស្រូបយកសារធាតុចិញ្ចឹមអសរីរាង្គ។



**រូបភាពទី៣៦៖** ការផ្លាស់ប្តូរលូតលាស់របស់រុក្ខជាតិអាស្រ័យលើការបំភាយទឹកនិងបរិមាណទឹកដែលស្រូបយក

- **ការកែតម្រូវតម្រូវការសីតុណ្ហភាព និងសំណើម**

- ចរន្តខ្យល់នៅក្នុងផ្ទះបៃតងៈ ចរន្តខ្យល់ធ្វើឱ្យថយចុះភាពធន់ទ្រាំរបស់ស្លឹក ហើយចំហាយទឹកដែលបង្កើតដោយរន្ធ បានជ្រាបចូលក្នុងស្លឹក។ កង្ហាដែលបង្កើតខ្យល់ធ្វើឱ្យបម្រែ បម្រួលសីតុណ្ហភាពនៅក្នុងផ្ទះបៃតងថយចុះប៉ុន្តែវាជំរុញឱ្យអត្រារំហាយតតាមរយៈលំហូរខ្យល់ពេលដែលគេបិទកង្ហារ
- ការបញ្ចេញបញ្ចូលខ្យល់ៈ ប្រើប្រាស់ 80-100% ពេលគ្មានចរន្តខ្យល់ចេញចូល។ ប្រើប្រាស់ 40% ពេលមានខ្យល់ចេញចូល។ នៅពេលយប់ពេលដែលគេបិទទ្វារផ្ទះបៃតង ធ្វើឱ្យសំណើម កើនឡើងខ្ពស់ ដែលធ្វើឱ្យកើតជំងឺលើរុក្ខជាតិ
- ការរាំងសីតុណ្ហភាពកើនខ្ពស់ៈ ចាប់ពីខែមីនាបរិមាណពន្លឺព្រះអាទិត្យនឹងកើនឡើង ដូច្នេះខ្យល់ចេញចូលទៅក្នុងផ្ទះបៃតងត្រូវការចាំបាច់ដើម្បីរក្សាសីតុណ្ហភាព ឱ្យនៅក្រោម30%
- ការគ្រប់គ្រងសំណើមៈ សំណើមខ្ពស់បង្កឱ្យកើតជំងឺ ដូចជាជំងឺបង្កដោយពពួកផ្សិត បាក់តេរីជាដើម
- ការផ្គត់ផ្គង់ឧស្ម័នកាបូនិច និងការបញ្ចេញចោលឧស្ម័នគ្រោះថ្នាក់ៈ កម្រិត CO2-នៅក្នុងផ្ទះបៃតងដែលបិទជិតធ្លាក់ក្រោម 200ppm រវាងរយៈពេល11និង13ម៉ោង→ដំណាកដង្ហើមរបស់រុក្ខជាតិ→ ការថយចុះយ៉ាងលឿននូវអត្រាធ្វើរស្មីសំយោគ, ការរារាំងឧស្ម័នគ្រោះថ្នាក់ដូចជាអាម៉ូញាក់ ឬ
នីត្រាតជាដើម
- ចរន្តខ្យល់នៅក្នុងផ្ទះបៃតងៈ ល្បឿនខ្យល់ 0.5-1.0m/sនៅជុំវិញស្លឹកអាចដោះស្រាយបញ្ហាកម្រិត CO2 ទាបដែលនៅជុំវិញស្លឹក។

- **ការគ្រប់គ្រងសំណើមទូទៅនៅក្នុងផ្ទះបៃតង**

- លក្ខខណ្ឌសំណើមៈ ទឹកក្រោមដីមានកម្រិតខ្ពស់ ដូច្នេះគេគួរ បិទផ្ទះបៃតងបន្ទាប់ពីបាញ់ទឹកស្រោចដំណាំ ឬនៅពេលមេឃស្រទុំ
- លក្ខខណ្ឌស្ងួតៈ សំណង់ផ្ទះបៃតងនៅលើដីដែលដាំដំណាំច្រើន អត្រាជ្រាបទឹកខ្ពស់ ប្រើប្រាស់កម្តៅច្រើនពេក
- ការការពារសំណើមខ្ពស់ៈ ធ្វើឱ្យមានខ្យលចេញចូល, បង្កើតកម្តៅ, ដាក់ឱ្យមានប្រព័ន្ធស្រោចស្រពសមស្រប ការគ្របដីដោយប្រើប្លាស្ទិក។ល។
- ការការពារកុំឱ្យស្ងួតពេកៈ ធ្វើឱ្យមានខ្យល់ចេញចូល, ឱ្យមានម្លប់ ដាក់ឱ្យមានប្រព័ន្ធស្រោចស្រពសមស្រប។

**តារាងទី៤**ៈឥទ្ធិពលខ្យល់សំណើមក្នុងកំឡុងពេលថ្ងៃ លើគុណភាពផ្លែត្រសក់ (NHR), 1991

| សំណើម | ផ្លែធម្មតា | ផ្លែមិនល្អ | ផ្លែសរុប |
|---|---|---|---|
| ៦៣-៧៤ | ៧០,០ | ២៩,០ | ១០០ |
| ២៣-៤៨ | ៥១,០ | ៤៩,០ | ១០០ |

**តារាងទី៥**៖ឥទ្ធិពលនៃសំណើមលលើទិន្នផលផ្លែ និងការប្រេះផ្លែម្ទេសប្លោកនៅក្នុងរដូវរងា និងនិទាឃរដូវ (choi et al,1999)

| សំណើម (ភាគរយ%) | ទិន្នផលផ្លែលក់បាន (ក្រាម/ផ្លែ) | ទំងន់ផ្លែជាមធ្យម (ក្រាម) | បរិមាណផ្លែដែលប្រេះ (ភាគរយ%) |
| --- | --- | --- | --- |
| ទាប (60-70) | 2,060 | 176 | 17.4 |
| ខ្ពស់ (70-80) | 1,755 | 181 | 26.3 |

**៣.២.៣ ការបញ្ចេញបញ្ចូលខ្យល់ និងទ្រនាប់កម្តៅ**

- **គោលការណ៍មូលដ្ឋាននៃទ្រនាប់កម្តៅ**

- កាត់បន្ថយកម្តៅ
- ការកាត់បន្ថយកម្តៅដែលបំភាយពីផ្ទៃក្រោម
- ការកាត់បន្ថយកម្តៅព្រះអាទិត្យនៅក្នុងផ្ទះបៃតង
- ការកាត់បន្ថយកម្តៅដែលបំភាយចេញពីជញ្ជាំង
- ការកាត់បន្ថយកម្តៅពីចរន្តខ្យល់ចេញចូល
- ការកាត់បន្ថយកម្តៅបំភាយ និងកម្តៅព្រះអាទិត្យពីខាងក្រៅផ្ទះបៃតង
- លំហូរកំដៅៈ កម្តៅបំភាយ+កម្តៅក្នុង+កម្តៅបំភាយ, បញ្ជូនកម្តៅទៅលើផ្ទៃកជញ្ជាំងក្តៅនិងត្រជាក់, និងកម្តៅក្នុងជញ្ជាំង
- កម្តៅបំភាយៈ សំដៅទៅម៉ូលេគុលកម្តៅដែលបំភាយចេញពីវត្ថុរាវ
- ចលនាខ្យល់ដែលមានកម្តៅកើនឡើងដោយទំនាញ និងដោយការបង្កើនកម្តៅ គឺជាឧទាហរណ៍នៃការបំភាយកម្តៅ
- លំហូរកំដៅៈ កម្តៅត្រូវបានបញ្ជូនពីផ្ទៃកដែលមានសីតុណ្ហភាពខ្ពស់ទៅកន្លែងដែលមានសីតុណ្ហភាពទាប
- ការបំភាយកំដៅៈ ដំណើរការនៃការបញ្ជូនថាមពលតាមរយៈលំហរហើយមានទម្រង់ជារលក ឬបំណែកតូចៗ។ ការបំភាយកម្តៅក៏អាចផងដែរនៅក្នុងសុញ្ញកាសពីព្រោះវាត្រូវបានបញ្ជូនដោយផ្ទាល់តាមរយៈសារធាតុចិញ្ចឹមសំលេងបំណែកតូចៗឆ្លងកាត់ផ្លូវត្រង់។

- **ការបង្កើនថាមពលកម្តៅ**

- បង្កើនសមាមាត្រកម្តៅ (ផ្ទៃក្រោមផ្ទះបៃតង/ផ្ទៃដាំដំណាំ)
- នៅក្នុងផ្ទះបៃតងៈ ការបង្កើនថាមពលព្រះអាទិត្យ កាត់បន្ថយផ្ទៃនៃការបំភាយកម្តៅ និងពន្លឺ
- តំឡើងស្រទាប់ច្រើន (ទុកគម្លាត 10cmពីស្រទាប់នីមួយៗ) ខ្យល់ចេញចូល កម្តៅបំភាយ និងរនាំងកម្តៅ
- បង្កើតស្រទាប់អត់ឆ្លងកម្តៅ ឱ្យមានច្រើនស្រទាប់លើពិដាន(បន្ទះចាំងផ្លាត+២ស្រទាប់)
- បំភាយកម្តៅ, កម្តៅខាងក្នុង និងរនាំងកាត់បន្ថយពន្លឺ

- ស្រទាប់ខាងក្រៅផ្ទះបៃតង-កម្តៅបំភាយ និងរនាំងកាត់បន្ថយកម្តៅ
- -តំឡើងទ្រនាប់ការពារខ្យល់ដើម្បីកាត់បន្ថយល្បឿនខ្យល់-រនាំងបាំងខ្យល់ចេញចូល
- បង្កើតគម្របដីនៅក្នុងផ្ទះបៃតង
- កាត់បន្ថយកម្តៅបំភាយចេញពីដី(រារាំងការកើនឡើងសំណើម)
- ការតំឡើងស្រទាប់អ៊ីសូឡង់(ស្រទាប់មិនឆ្លងកម្តៅ) ដើម្បីការពារការខាតបង់កម្តៅ
- រារាំងការបញ្ជូនកម្តៅលើផ្ទៃដី
- បង្កើនការប្រើប្រាស់ថាមពលធម្មជាតិ
- សង់ផ្ទះបៃតងក្នុងទិសដៅពីកើតទៅលិចដើម្បីបង្កើនថាមពលពន្លឺព្រះអាទិត្យ
- ការប្រើប្រាស់បាវស្តុកទុកកម្តៅ
- ប្រើប្រាស់វិធីសាស្ត្របង្កើតរូងនៅក្នុងផ្ទះបៃតងហើយស្តុកទឹកនៅក្នុងបំពង់ (PE) ដើម្បីស្តុកថាមពលព្រះអាទិត្យក្នុងការបង្កើនសីតុណ្ហភាព
- ការប្រើប្រាស់ឧបករណ៍ស្តុកទុកកម្តៅក្រោមដី-ជាវិធីសាស្ត្រផ្លុំខ្យល់កម្តៅក្នុងពេលថ្ងៃនៅក្រោមដីហើយផ្ទះកញ្ចក់នៅពេលយប់ដើម្បីរក្សាសីតុណ្ហភាពនៅក្នុងផ្ទះបៃតង
- ការប្រើប្រាស់ទឹកដើម្បីរក្សាកម្តៅនៅក្នុងផ្ទះបៃតង-សីតុណ្ហភាព ១០អង្សារ សីតុណ្ហភាព៥អង្សារ ឬខ្ពស់ជាងនេះ។

**០ ការដាំដុះដំណាំនៅក្នុងផ្ទះបៃតងដោយការរក្សាកម្តៅ**

- វាជាវិធីសាស្ត្រនៃការរក្សាកម្តៅនៅក្នុងផ្ទះបៃតងជាពិសេសដំណាំយកស្លឹក
- រក្សាសីតុណ្ហភាពនៅក្នុងផ្ទះបៃតងដោយបង្ហូរទឹកក្រោមដីទៅលើចង្អូរដំបូល
- ចំពោះគោលបំណងនេះត្រូវត្រួតពិនិត្យកុំឱ្យមានរន្ធលិចនៅលើចង្អូរដំបូលដែលប្រក់ប្លាស្ទិក ហើយគេគួរដាក់ឧបករណ៍តម្រងដើម្បីកុំឱ្យស្ទះទឹក
- ជាទូទៅគេបង្ហូរទឹករយៈពេល ៣០នាទីទៅ១ម៉ោង
- ត្រូវប្រុងប្រយ័ត្នកុំធ្វើឱ្យត្រជាក់កកដល់បំពង់ទឹកក្នុងកំឡុងពេលថ្ងៃ។







**រូបភាពទី៣៧៖** ការតំឡើងផ្ទះបៃតង

- **បញ្ហាទឹកដែលប្រើប្រាស់ក្នុងផ្ទះបៃតង**

- ជាទូទៅសីតុណ្ហភាពទឹកមានកម្រិតទាបហើយប្រសិទ្ធភាពរបស់វាទាប
- ជាងនេះទៅទៀតដោយសារតែការដាំដំណាំធ្វើនៅរាយប៉ាយច្រើនកន្លែង។ ដូច្នេះគេប្រើប្រាស់ទឹកក្រោមដីច្រើនហើយគ្មានប្រសិទ្ធភាព
- មានកត្តាជាច្រើននៅក្នុងផ្ទះបៃតងដោយសារតែសំណើមខ្ពស់ពេកដូច្នេះការបង្កើតឱ្យមានខ្យល់ចេញចូលជាមធ្យោបាយល្អសម្រាប់កាត់បន្ថយសំណើម។

- **អត្រាខ្យល់ចេញចូល**

- បរិមាណលំហូរនៃខ្យល់ខាងក្រៅក្នុងមួយខ្នាតពេល
- អត្រាលំហូរខ្ពស់ គឺជាបរិមាណខ្យល់ ចូលពីខាងក្រៅហើយត្រូវបានផ្ទេរជាខ្យល់លើផ្ទៃដី
- លំហូរខ្យល់គិតជា ($m^3$/mh) = បរិមាណនៃលំហូរខ្យល់/ផ្ទៃទឹកផ្ទៃដី$m^2$

- **ប្រភេទលំហូរខ្យល់**

**១. លំហូរខ្យល់តាមបែបធម្មជាតិ**

- វាបង្កើតឡើងតាមរយៈកម្លាំងខ្យល់ដែលបុកពីខាងក្រៅ និងការខុសគ្នារវាងសីតុណ្ហភាពខាងក្នុង និងខាងក្រៅ
- អាស្រ័យទៅតាមផ្ទៃ និងទីតាំងនៃបង្អួចសម្រាប់ខ្យល់ចេញចូល
- ការចែកចាយសីតុណ្ហភាពនៅក្នុងផ្ទះបៃតងគឺស្មើៗគ្នា
- ឥទ្ធិពលលើលក្ខខណ្ឌអាកាសធាតុខាងក្រៅ (ទិសខ្យល់ ល្បឿនខ្យល់)
- ផ្ទៃបង្អួចសម្រាប់លំហូរខ្យល់គឺ ១៥%



**រូបភាពទី៣៨៖** លំហូរខ្យល់របស់ផ្ទះកញ្ចក់



**រូបភាពទី៣៩៖** លំហូរខ្យល់ដោយរមូលប្លាស្ទិក

## ២.លំហូរខ្យល់ដោយបង្ខំ

- លក្ខណៈនៃលំហូរខ្យល់ដោយបង្ខំ
- បរិមាណលំហូរខ្យល់ប្រភេទនេះអាស្រ័យទៅលើផ្ទៃ  និងទីតាំងនៃល្បឿនខ្យល់ពីកន្លែងខ្យល់ចូលទៅសីតុណ្ហភាពទាបកន្លែងខ្យល់ចេញ
- កាត់បន្ថយបរិមាណពន្លឺនៅខាងក្នុងដោយបាំងកង្ហារ
- បញ្ហាអគ្គីសនីសំឡេង ការដាច់ចរន្តអគ្គិសនី
- ជាធម្មតាខ្យល់ត្រូវបានបត់ចេញទៅខាងក្រៅ ប៉ុន្តែពេលដែលទទឹងផ្ទះបៃតងទូលាយគេអាចតម្លើងបំពង់ខ្យល់នៅកម្ពស់ ១.៨ម៉ែត្រ ទៅ ២ម៉ែត្រនៅក្នុងផ្ទះបៃតង។





**រូបភាពទី៤០៖** លំហូរខ្យល់ដោយបង្ខំដោយការប្រើប្រាស់បំពង់ខ្យល់

## ៣.៣ បរិស្ថានទឹក និងដី

### ៣.៣.១ បរិស្ថានទឹក និងការលូតលាស់ដំណាំ

- **សំណើម និងការលូតលាស់ដំណាំ**

- ដំណាំដែលដាំនៅក្នុងផ្ទះបៃតងមានសំណើមពី ៧០-៩៥%។ ដំណាំយកផ្លែ ស្លឹក និងមើមមានសមាសធាតុទឹកខ្ពស់ខណៈដែលដមណាំយកគ្រាប់មានកម្រិតជាតិទឹកទាប។ ទិន្នផលគឺជាទិន្នន័យដើម្បីវិនិច្ឆ័យពីតម្រូវការសំណើមរបស់ដំណាំ
- ប្រសិនបើសំណើមមិនគ្រប់គ្រាន់ tomata បិទ ដូច្នោះសកម្មភាពរស្មីសំយោគការសំយោគប្រូតេអ៊ីន និងសកម្មភាពមេតាបូលីសផ្សេងៗទៀតនឹងថយចុះ។ ជាមួយគ្នានេះ អរម៉ូនរុក្ខជាតិ Abscisic Acid (ABA) កើនឡើង ដែលធ្វើឱ្យទម្រង់កោសិកាផ្លាស់ប្តូរ
- ប្រសិនបើការខ្វះខាតទឹកពន្យារពេលយូរ
- ធ្វើឱ្យការលូតលាស់ថយចុះ ធ្វើឱ្យដំណាំក្រិន ជ្រុះស្លឹក។ល។
- ប្រសិនបើលើសសំណើមដី
- ធ្វើឱ្យអុកស៊ីសែននៅក្នុងដីថយចុះធ្វើឱ្យឫសលែងមានតួនាទីត្រឹមត្រូវដែលបណ្តាលឱ្យដំណាំលូតលាស់ខ្សោយ សរីរៈសាស្ត្រខុសប្រក្រតី និងការកកើតជំងឺ។

### ៣.៣.២ លក្ខណៈបរិស្ថានទឹកក្នុងផ្ទះបៃតង

- **បរិស្ថានសំណើមដី**

- ដីដែលខ្វះខាតទឹកងាយនឹងកើតឡើងដោយសារតែការស្រោចស្រពមិនបានស្មើ។ ម្យ៉ាងវិញទៀតទឹកអាចបាត់បង់ដោយសារការបំភាយ។

- **បរិស្ថានសំណើម**

- សំណើមដែលបញ្ចេញពីសារធាតុចិញ្ចឹមមិនអាចបញ្ចេញទៅខាងក្រៅផ្ទះបៃតងបានទេ។ បរិមាណនៃការបំភាយ (បំភាយចេញពីដំណាំ និងដី) គឺមានកម្រិតខ្ពស់នៅសីតុណ្ហភាពខ្ពស់។ សំណើមខ្យល់កើនឡើងដោយសារតែការរាំងលំហូរខ្យល់ពីខាងក្រៅនៅពេលសីតុណ្ហភាពទាប

- សំណើមខ្យល់ខ្ពស់៖ ថយចុះប្រតិកម្មដំណកដង្ហើម ឬសកម្មភាពស្មើសំយោគ។ កើនឡើងជំងឺនៅក្នុងផ្ទះបៃតង។

- **កាត់បន្ថយឥទ្ធិពលផ្សែងអ័ព្ទ**
- ជំរុញការលូតលាស់តាមរយៈបង្កើនសកម្មភាពស្មើសំយោគ
- ដោយសារតែមានការកើតឡើងតិចតួចនៃផ្សែងអព្ទ័នៅក្នុងផ្ទះបៃតង ហើយមានបរិមាណពន្លឺព្រះអាទិត្យច្រើននៅពេលព្រឹកដូច្នេះវាជំរុញការលូតលាស់ដំណាំ
- កាត់បន្ថយកត្តាចង្រៃ
- វាមានប្រសិទ្ធភាពដើម្បីការពារសំណើមខ្ពស់នៅក្នុងផ្ទះបៃតង
- កាត់បន្ថយលំហូរខ្យល់ ឬបង្កើនកម្តៅ។

**៣.៣.៣ ការគ្រប់គ្រងសំណើម និងការស្រោចស្រព**

- សន្ទទស្សន៍នៃសំណើមដី៖ ភាគរយនៃទំងន់ឬមាឌ(%), សំណើមដី
- ប្រភេទសំណើមដី៖ ទឹកធ្លាក់ពីលើចុះក្រោម ទឹកលើដី ចំហាយទឹក
- ការវាស់សំណើមដី៖ វិធីសាស្រ្តវាស់ម៉ាស់ វិធីសាស្រ្តវាស់មាឌ
- វិធីសាស្រ្តវាស់ភាពធន់ទ្រាំទៅនឹងអគ្គិសនី វិធីសាស្រ្តវាស់សំណើមដី។ល។

- **ការកំណត់ចំណុះទឹក**
- PF (Potential Foro) ប៉ូតង់ស្យែលហ្វូរ៉ូ
- ប្រភេទសំណើម៖ ទឹកធ្លាក់ពីលើ(ទឹកសេរី), ទឹកលើដី,ចំហាយទឹក
- ការគ្រប់គ្រងសំណើមដី៖ វារក្សាកំរិតសំណើមឱ្យ ប៉ូតង់ស្យែលហ្វីរ៉ូ សមស្របសម្រាប់ផ្ទៃស្រូបរបស់ដំណាំ
- ការកំណត់រយៈពេលស្រោចស្រពនិងបរិមាណទឹកស្រោចស្រពចំណុចចាប់ផ្តើមនៃការស្រោចស្រពគឺ PF 2-0
- វិធីសាស្រ្តស្រោចស្រព៖ ការស្រោចស្រពពីលើខ្ពស់ ការស្រោចស្រពលើផ្ទៃរាបការស្រោចស្រពជាលក្ខណៈសន្សើម(អ័ព្ទ) ការស្រោចស្រពដំណក់ ការស្រោចស្រពក្រោមដី ការស្រោចស្រពនៅខាងក្រោម
- វាជាវិធីសាស្រ្តមួយដើម្បីផ្គត់ផ្គង់ទឹកដោយឱ្យទឹកហូរធ្លាក់ទៅដើមដំណាំនៅក្នុងផ្ទះបៃតង ឬតាមរយៈស្រោចទឹកក្នុងបរិមាណាមួយ ហើយឱ្យទឹកជ្រៀបទៅក្នុងប្រព័ន្ធឫសរបស់ដំណាំ។
- ទឹកចេញពីទុយោតូចៗ រឺ ទឹកចេញយ៉ាងយឺតៗការស្រោចស្រពដោយប្រព័ន្ធដំណក់ទឹកនេះ គេប្រើបរិមាណទឹកតិចតួចបំផុត ហើយមិនមានការបាត់បង់ជីវជាតិដីផ្នែកខាងលើទេ។



**រូបភាពទី៤១៖** វិធីសាស្រ្តបាញ់ទឹកស្រោចស្រពទៅលើផ្ទៃដី




**រូបភាពទី៤២៖** សំពាធទឹកថេរ(A)និងសំពាធទឹកផ្លាស់ប្តូរ(B)




**រូបភាពទី៤៣៖** រចនាសម្ព័ន្ធទុយោក្រោមដី






**រូបភាពទី៤៤៖** ការស្រោចស្រព

## ៣.៤. លក្ខណៈបរិស្ថានដី

### ៣.៤.១ បរិស្ថានដី និង ការលូតលាស់ដំណាំ

### ៣.៤.២ លក្ខណៈ និង ការគ្រប់គ្រងដីក្នុងផ្ទះបៃតង

- សមាសធាតុដី
- វិធីសាស្ត្រត្រីកោណ

○ **ដីជាការលូតលាស់ដំណាំ:** ដីខ្សាច់ ល្បប់ម៉ដ្ឋ មមោក ដីឥដ្ឋ

○ **ទំរង់ដី ការលូតលាស់ដំណាំ:** ដីខ្សាច់: ប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹក




**របរូបភាពទី៤៥៖** វិធីសាស្ត្រត្រីកោណដែលវិភាគសមាសធាតុដី

- **ការលូតលាស់សំណើមដី ខ្យល់ និង ដំណាំ**

- សំណើមដីសមស្រប គឺ ៦០-៨០% នៃបរិមាណតំលៃស៊ីម៉ង់ក្នុងផ្ទះបៃតង ហើយប្រសិនបើសំណើមខ្ពស់ពេកវាបណ្ដាលឱ្យមានជំងឺរលួយឫសដោយសារតែកង្វះអុកស៊ីសែន
- សកម្មភាពសរីរៈធម្មតាគឺនៅសីតុណ្ហភាព ១៥ អង្សា ជំរុញការស្រូបយកសារធាតុចិញ្ចឹមគឺនៅសីតុណ្ហភាព ២០ អង្សា

- **ប្រភេទដីអាស៊ីត និងការលូតលាស់ដំណាំ**

- កម្រិតជាតិអាស៊ីតនៅក្នុងដីប្រែប្រួលអាស្រ័យទៅតាមប្រភេទដំណាំ ប៉ុន្តែភាគច្រើន ដីមានកម្រិតអាស៊ីតបន្តិចបន្តួចហើយការលូតលាស់ដំណាំគឺល្អបំផុត។

**តារាងទី៦៖** ដែលកំណត់ការលូតលាស់របស់ដំណាំបន្លែ និង EC ក្នុងដី (ឯកតា ds/m)

| ប្រភេទដី | ភាពស្ងួត | កម្រិតឆ្អែត ៥០ភាគរយ | កម្រិតឆ្អែត ១០០ភាគរយ |
|---|---|---|---|
| ដីខ្សាច់ | 0,៣0២ | 0,0៥១ | 0,៧១៧ |
| ដីមមោត | 0,១៤៨ | 0,៥២៥ | 0,៩0២ |
| ដីឥដ្ឋ | 0,២៤0 | 0,៥៣២ | 0,៨២៣ |

**តារាងទី៧**៖បរិមាណកាល់ស្យូមអ៊ីដ្រូកស៊ីតត្រូវការដើម្បីបង្កើន pH ដីទៅ ១.0 (ឯកតា៖ គ.ក្រ/១០អា)

| ប្រភេទដី | **ប៉ូតង់ស្យែលអ៊ីដ្រូសែន** (pH) ដី | | |
|---|---|---|---|
| | ២,៥ - ៤,៥ | ៤,៥ - ៥,៥ | ៥,៥ - ៦,៥ |
| ខ្សាច់ | ៧៣ | ១២៤ | ១១0 |
| ល្បាចខ្សាច់គ្រើម | - | ១៩៨ | ២៣៨ |
| ដីជីជាតិ | - | ២៩៧ | ៣១២ |
| ដីល្បាយឥដ្ឋ | - | ៣៤៨ | ៤២១ |
| ដីមមោត | ៥៣១ | ៦៩៦ | ៧៨៧ |

- **ដីសំបូរបាសនិងការលូតលាស់ដំណាំ**

- ការកើនឡើងសមាសធាតុអំបិល ដូចជា -$NH_4$-N,K,Ca និង Mg កើតឡើងដោយសារសកម្មភាពប្រឆាំងគ្នាដែលស្រូបដោយរុក្ខជាតិ
- កំហាប់អំបិលរបស់ដីត្រូវការគេកំណត់តាមរយៈការវាស់កំលាំងអគ្គិសនីដែលជ្រៀបក្នុងដី
- ការធន់ទ្រាំទៅនិងដីដែលមានសមាសធាតុអំបិលគឺអាស្រ័យទៅប្រភេទដំណាំ ប៉ុន្តែភាពធន់ទ្រាំនេះកើតឡើងពេលដែលមានសារជាតុសរីរាង្គកាន់តែច្រើន
- វាស់ពីកំរិតសមាសធាតុអំបិល
- តើត្រូវប្រើប្រាស់ទឹករបៀបណា និងដើម្បីឱ្យវាហូរចេញពីផ្ទះបៃតងបានត្រឹមត្រូវ

- នៅក្នុងកំឡុងពេលដែលដំណាំមិនស្រូប ការដាំដុះក្នុងផ្ទះប៉ៃតងមិនអាចឱ្យមានសីតុណ្ហភាព ខ្ពស់ ដូច្នេះត្រូវតែកាត់បន្ថយសមាសធាតុអំបិលតាមរយៈដាំដំណាំដូចជាពោត និង Sorghum
- ប្រើប្រាស់វិធីសាស្ត្រលាយដីស្រទាប់លើនិងស្រទាប់បន្ទាប់ដោយកាប់គាស់ ឬត្រាក់ទ័រដើម្បីគាស់ឱ្យបានជំរៅ 50cm
- តើគួរគ្រប់គ្រងបរិមាណសមាសធាតុសរីរាង្គរបស់ដីក្នុងទ្រង់ទ្រាយធំដោយរបៀបណា?

○ **សារធាតុសរីរាង្គក្នុងដីនិងការលូតលាស់ដំណាំ**

- សមាសធាតុគីមី៖ បង្កើនសមត្ថភាពការពារការកើនឡើងpH, បង្កើនសមត្ថភាពដុះដូរបាស(10 ដងចំពោះដីឥដ្ឋ)
- រូបសាស្ត្រ៖ សមត្ថភាពដកដង្ហើមដី សមត្ថភាពស្រូបយកទឹកអាចបង្កើនសីតុណ្ហភាពក្នុងដី
- ជីវសាស្ត្រ៖ មានសមត្ថភាពបង្កើនពពួកអតិសុខមប្រាណ សកម្មភាពសរីរៈនិងសារធាតុរារាំង

○ **ការបំពុលដីនិងការលលូតលាស់ដំណាំ**

- ការបំពុលដីតាមរយៈប្រព័ន្ធស្រោចស្រព(ទឹកក្នុងកសិដ្ឋាន ការហូរចូលទឹកឧស្សាហកម្ម)
- ការបំពុលដីដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត ថ្នាំសំលាប់ស្មៅចង្រៃ ជីគីមី សារធាតុគីមី លោហៈធាតុធ្ងន់ ។ល។
- ការពុលដោយថ្នាំសំលាប់សត្វល្អិត(សារធាតុពុលកកនៅក្នុងដីដោយសារការប្រើប្រាស់លើសលប់នូវថ្នាំសំលាប់សត្វល្អិត ជីគីមី និងវត្ថុមានសារធាតុលោហៈធ្ងន់ក្នុងដីរយៈពេលយូរ)។

**តារាងទី៨**៖កម្រិតកំណត់ការលូតលាស់បន្លែ និងEC របស់ដី (ឯកតា: ds/m)

| ដី | ដែនកំណត់ | | | លើសកំណត់ | | |
|---|---|---|---|---|---|---|
| | ត្រសក់ | ប៉េងប៉ោះ | ម្ទេស | ត្រសក់ | ប៉េងបោះ | ម្ទេស |
| ដីខ្សាច់ | ០,៦ | ០,៨ | ១,១ | ១,៤ | ១,៩ | ២,០ |
| ដីល្បប់ឥដ្ឋដីជាតិ | ១,២ | ១,៥ | ១,៥ | ៣, | ៣,២ | ៣,៥ |
| ដីមមោគឥដ្ឋដីជាតិ | ១,៥ | ១,៥ | ២,០ | ៣,២ | ៣,៥ | ៤,៨ |




**រូបភាពទី៤៦៖** ឥទ្ធិពលនៃកម្រិត EC លើការលូតលាស់បន្លែ

### ០ សមាសធាតុប្រឆាំងគ្នា

- ភាពប្រឆាំងនៃសារធាតុចិញ្ចឹម៖ ការស្រូបយកដែលមានលក្ខណៈប្រជែងគ្នារវាងអ៊ីយ៉ុងនិង ប៉ូលដូចគ្នា ឧទាហរណ៍ $NH_4$-N VS K; Mg, Ca, $No_3$ VS Cl
- ភាពជំរុញគ្នានៃសារធាតុចិញ្ចឹម៖ ការដែលលើសកាចុងនៅក្នុងរុក្ខជាតិមួយ អាចជំរុញការស្រូបយកអ៊ីយ៉ុង តាមរយៈការរក្សាទំនាក់ទំនងងដែលបំពេញគ្នាទៅវិញទៅមកនៅក្នុសារពាង្គកាយ
- ភាពប្រឆាំងគ្នានិងបាតុភូតផ្ទុយគ្នាទាំងនេះ បង្កឡើងដោយប្រតិកម្មរវាងអ៊ីយ៉ុងនិងអ៊ីយ៉ុងដើម្បីរក្សា សមាមាត្ររវាងអ៊ីយ៉ុងក្នុងសាតពាង្គកាយនិង កាចុង=អាញ៉ុង=1:1។

### ០ សមាសធាតុដែលភាពប្រឆាំងគ្នាកើតឡើង

- K-Mg, Ca-Mg/K នៅក្នុងកាចុង$NH_3$-K/Mg/Ca
- $NO_3$-Cl នៅក្នុងអាញ៉ុង
- ទំនាក់ទំនងដែលមានលក្ខណៈប្រឆាំងគ្នាជាមួយនិងការកកើតះបណ្ដាលមកពីប្រតិកម្មរលាយចូលគ្នា ប្រព្រឹត្តទៅមិនបានល្អ រឺដោយសារ សារធាតុទាំងនេះគ្មានសកម្មភាព។

### ៣.៤.៣ វិធានការណ៍ការពារការកើតឡើងសារធាតុអំបិល

- ដីមានសារធាតុអំបិល៖ គ្មានបញ្ហាទេក្នុងការប្រើប្រាស់ផ្ទះបៃតងដែលមិនសង់ជាប់នៅមួយកន្លែងបំលែង ឱ្យទៅជាវាលស្រែ ប៉ុន្តែមានបញ្ហាជាច្រើនក្នុងករណីដែលផ្ទះបៃតងសង់ជាប់នៅមួយកន្លែង ដូចជាផ្ទះ កញ្ចក់ជាដើម
- ការបំលែងដី(លោហៈធ្ងន់...។ល។)៖ pH របស់ដីត្រូវធ្វើឱ្យណឹតតាមរយៈធ្វើឱ្យមានលំនឹង pH ក្នុងដីនៅ កន្លែងដីរងការបំពុល។ ប្រសិនបើដីមានជាតិអាស៊ីតគឺត្រូវផ្តល់ជីផូស្វាតឱ្យបានគ្រប់គ្រាន់ដើម្បីរាំងការ ស្រូបយកសារធាតុ សារីរាង្គច្រើនដែលធ្វើឱ្យដីកាន់តែខូចខាត

- បញ្ហាកត្តាចង្រៃ៖ ធ្វើយ៉ាងណាកុំឱ្យដីឆ្លងមេរោគ ដោយការប្តូរប្រព័ន្ធគំរបដីដាំដំណាំឆ្លាស់និងការប្រើប្រាស់ដីសរីរាង្គ។

## ០ លក្ខណៈនិង ការគ្រប់គ្រងដីសិប្បនិម្មិតសំរាប់សួន

- អាស្រ័យលើគោលបំណងនៃការប្រើប្រាស់ដីសម្រាប់ដាំដំណាំដើម្បីបង្កាត់និងដីដាំដំណាំធម្មតា
- ដីសម្រាប់ដាំបន្លែងនិង ដីសម្រាប់ដំណាំលំអ
- ប្រើប្រាស់ភ្នាក់ងារកែលំអដី
- បង្កើតលក្ខខណ្ឌឱ្យល្អសម្រាប់ដី
- ធ្វើឱ្យមានខ្យល់ចេញចូលនិងការបង្ហូរទឹកបានល្អ
- សារធាតុចិញ្ចឹមផ្សេងៗគួរត្រូវបានគេលាងឱ្យបានត្រឹមត្រូវដូច្នេះវាគ្មានការខ្វះខាតសារធាតុចិញ្ចឹមចំពោះដំណាំទេ
- គ្មានវត្តមានពពួកអតិសុខមប្រាណរឺសារធាតុក្នុងដី
- វាគួរតែងាយស្រួលក្នុងការធ្វើការងារពីព្រោះវាជាការងារស្រួលៗ
- ការប្រើប្រាស់ដីសមស្រប៖ ការប្រើប្រាស់ដីឱ្យបានសមស្របជាពិសេសដីអាស៊ីត
- ការប្រើប្រាស់ដីនិងសារធាតុសរីរាង្គ៖ បង្កើតCEC និងកាត់បន្ថយសារធាតុអរីរាង្គអាសូត តាមរយៈសមាមាត្រC/N ខ្ពស់
- ប្រតិកម្មទឹកសាប៖ ប្រើប្រាស់ទឹកសាបដើម្បីបន្សាបសារធាតុអំបិលជាពិសេស
- ការប្រើប្រាស់ដំណាំ៖ បន្សាបដីដែលមានសារធាតុអំបិលដោយការដាំស្រូវដែលមានទិន្នផលខ្ពស់ដោយមិនប្រើប្រាស់ដី
- ប្រើប្រាស់បរិមាណទឹកស្រោចស្រពច្រើន៖ ទឹកដែលស្រោចស្រពហូរទៅស្រទាប់ដីទាប។

# មេរៀនទី៤. ការដាំដំណាំក្នុងប្រព័ន្ធ អ៊ីដ្រូប៉ូនិច

## ៤.១ ប្រភេទ និងលក្ខណៈ អ៊ីដ្រូប៉ូនិច (Hydroponics)

### ៤.១.១ សារធាតុចិញ្ចឹម

- ប្រើប្រាស់ទឹក១រងតូច
- ប្រើប្រាស់ទឹកសារធាតុចិញ្ចឹម និងអុកស៊ីសែន ដូចដែលយើងដាំដំណាំលើដីដែរ
- ផលិតកម្មដំណាំប្រែប្រួលទៅតាមប្រភេទសារធាតុចិញ្ចឹម
- គេបែងចែកប្រព័ន្ធ**អ៊ីដ្រូប៉ូនិច** ជាប្រភេទទឹកវិល និងប្រភេទទឹកមិនវិល។

**គុណសម្បត្តិ**

- មានអុកស៊ីសែនច្រើនសម្រាប់ការលូតលាស់
- គេអាចគ្រប់គ្រងសំណើមបានទៅដល់ឫសគ្រប់គ្រាន់
- គេមិនចាំបាច់ប្រើរងដំណាំ និងអាងស្តុកទឹកហើយគេអាចចំណាយលុយតិច
- គេអាចរុះរើប្រព័ន្ធ **អ៊ីដ្រូប៉ូនិច** ប្រភេទទឹកមិនវិល ទៅកន្លែងមួយផ្សេងទៀតបានយ៉ាងងាយ
- ទោះបីជាម៉ាស៊ីនបូមទឹកខូចក៏ដោយ ក៏មានទឹកគ្រប់គ្រាន់សម្រាប់ការលូតលាស់ដំណាំមួយរយៈពេលដែរ
- វាងាយស្រួលក្នុងការគ្រប់គ្រងបរិមាណសារធាតុចិញ្ចឹម ហើយគេអាចកែតម្រូវសារធាតុចិញ្ចឹមទៅតាមការលូតលាស់ដំណាំ។

**គុណវិបត្តិ**

- មានការលំបាកក្នុងការសម្អាតមេរោគដែលឆ្លង
- កំហាប់សូលុយស្យុងរបស់សារធាតុចិញ្ចឹមប្រែប្រួលដោយសាររំហួត
- មានការពិបាកក្នុងការសំអាត និងចោលកាកសំណល់គីមី
- អ្នកបរិភោគអាចមានអារម្មណ៍ខ្លាច ពីព្រោះការដាំដំណាំនៅលើទឹកនេះប្រើសារធាតុគីមី។

### ៤.១.២ ការស្រោចស្រពប្រើប្រាស់ដំណក់ទឹកតូចៗ

- ដាំតាមវិធីសាស្ត្រធ្វើឱ្យឫសរបស់ដំណាំសម្បូរអុកស៊ីសែន
- ឧបករណ៍៖ រូបរាងថ្នាលដាំជា 3-D
- គុណសម្បត្តិ និងគុណវិបត្តិ៖ ឧបករណ៍ដាំតូច ហើយសមាសធាតុសារធាតុចិញ្ចឹមងាយស្រួលប្តូរ។ ងាយនឹងសម្លាប់មេរោគ ការលូតលាស់ដំណាំលឿនល្អហើយគេអាចដាំបានច្រើន។ ប៉ុន្តែសម្ភារឧបករណ៍មានតម្លៃថ្លៃ។ ការគ្រប់គ្រងទុយោទឹកមានការលំបាក។ ការរីករាលដាលកត្តាចង្រៃមានល្បឿនលឿន។




**រូបភាពទី៤៧៖** ការដាំដុះ **អ៊ីដ្រូប៉ូនិច** ដោយវិធីសាស្ត្រផ្សេងៗ

### ៤.១.៣ ប្រព័ន្ធដាំដុះដោយប្រើប្រាស់សារធាតុចិញ្ចឹមតាមបំពង់ទុយោ

- ការផ្គត់ផ្គង់អុកស៊ីសែនទៅឱ្យឫសគ្រប់គ្រាន់ហើយមានតែសារធាតុចិញ្ចឹមតិចតួចហូរទៅលើស្លឹកជាពិសេសទៅទៀតសារធាតុចិញ្ចឹមមិនដក់ជាប់នៅក្នុងថ្នាលបណ្តុះទេ។
- ថ្នាលដាំ៖ រាងជម្រាល ១/១២៥-១/២៥ ចំពោះដំណាំយកផ្លែ និងបន្លែ ប្រើប្រាស់ទឹក៥លីត្រ ក្នុងមួយសប្តាហ៍។
- គុណសម្បត្តិ និងគុណវិបត្តិ៖ ខាតបង់ទឹកតិចតួច ងាយស្រួលក្នុងការគ្រប់គ្រងសារធាតុចិញ្ចឹម។ ក៏ប៉ុន្តែមានការពិបាកក្នុងការរុះរើប្តូរថ្នាលដាំ។




**រូបភាពទី៤៨៖** វិធីសាស្ត្រដាំដំណាំលើទឹកដោយប្រើ NFT

### ៤.១.៤ ប្រព័ន្ធដាំដុះដោយប្រើបច្ចេកទេសទឹកជ្រៅ

- វិធីសាស្ត្រដែលល្អបំផុតដែលចែកចេញជាប្រភេទប្រើប្រាស់សារធាតុរាវ ប្រភេទប្រើប្រាស់សារធាតុរាវតិច ប្រភេទខ្យល់ចេញចូល គឺអាស្រ័យទៅតាមវិធីសាស្ត្រផ្គត់ផ្គង់អុកស៊ីសែន ហើយការបែងចែកជាប្រភេទស៊ីទែន និងប្រភេទមិនប្រើស៊ីទែន គឺអាស្រ័យទៅលើវត្តមាន ឬអវត្តមានស៊ីទែន

- ថ្នាលដាំ៖ ថ្នាលដាំដែលមានបរិមាណច្រើនសារធាតុចិញ្ចឹម គេត្រូវការចាំបាច់ឱ្យមានច្រើនសម្រាប់ទប់ដំណាំ បំពង់បង្ហូរទឹកឧបករណ៍ច្រោះ

  សម្រាប់ដំណាំយកផ្លែ និងបន្លែ, ត្រូវការទឹក ១០-៤០លីត្រ ដើម្បីផលិតមួយផ្លែ។




**រូបភាពទី៤៩៖** ប្រព័ន្ធ អ៊ីដ្រូប៉ូនិចទឹកជ្រៅ

## ៤.២ ប្រភេទ និងលក្ខណៈសារធាតុចិញ្ចឹម

សារធាតុចិញ្ចឹមដែលប្រើសម្រាប់ **អ៊ីដ្រូប៉ូនិច** គឺជាសារធាតុសរីរាង្គដែលបានមកពីធម្មជាតិ ឬសិប្បនិម្មិត ដែលផ្តល់ និងបង្កើនសំណើម សារធាតុចិញ្ចឹម និងអុកស៊ីសែនទៅឱ្យឫស ជំនួសឱ្យដី។

**តារាងទី៩៖** លក្ខណៈរូបរបស់សារធាតុចិញ្ចឹមសម្រាប់ អ៊ីដ្រូប៉ូនិច

| ប្រភេទ | | សារធាតុចិញ្ចឹម |
|---|---|---|
| សារធាតុដែលបានមកពីធម្មជាតិ | អសរីរាង្គ | គ្រួស, ខ្សាច់ |
| | សរីរាង្គ | កាកសំណល់រុក្ខជាតិ, ស្រកីដូង, អាចម៍រណា, ធ្យូង |
| សារធាតុចិញ្ចឹមសិប្បនិម្មិត | អសរីរាង្គ | ប៉េលីត, សំឡីថ្ម, ដីមីគូឡាយ, |
| | សរីរាង្គ | ប៉ូលីអ៊ូរ៉េតាន ប៉ូលីអ៊ីស្ទ័រ, ប៉ូលីផេនុល |

○ **សមាសធាតុរូប គីមី របស់សារធាតុចិញ្ចឹម**

- វាទាក់ទងយ៉ាងខ្លាំងទៅនឹងបរិស្ថាន ដូចជាសំណើមខ្យល់ និងពពួកអតិសុខុមប្រាណ
- កម្រិតសំណើម ដែលមានប្រសិទ្ធភាពបំផុត គឺលើស ៥០% នៅក្នុងផ្ទៃដីរបស់ថ្ម, កំប៉ុស្ត...។ល។
- ក្នុងចំណោមសមាសធាតុគីមី, កំប៉ុស្ត និងសំបកឈើទាមទារការកែតម្រូវ កម្រិតជាតិអាស៊ីតអាល់កាឡាំងខ្សោយ និងអាល់កាឡាំងខ្លាំង
- កាកសំណល់រុក្ខជាតិ និងត្របកឈើត្រូវការដើម្បីគ្រប់គ្រងសារធាតុអាស៊ីត តាមរយៈការប្រើប្រាស់អាស៊ីតផូស្វ័រិច ប៉ូតាស្យូម និងកាល់ស្យូម ហើយនិងស្រកីដូងដើម្បីគ្រប់គ្រងគុណភាពអ៊ីយ៉ុងដោយការប្រើប្រាស់ Ca និង Mgដើម្បីដកចេញ K និង Na

**តារាងទី១០៖** លក្ខណៈគីមីនៃសារធាតុចិញ្ចឹមសម្រាប់ អ៊ីដ្រូប៉ូនិច

| សារធាតុគីមី | pH | CEC | OM | Ave. P2O2 | K | Ca | Mg |
|---|---|---|---|---|---|---|---|
| | | | | | (me/100g) | | |
| ប៉េលីត | ៦,៩ | ០,៥ | ០,១ | ១៦ | ០,៤១ | ៥,៨៨ | ១,៣១ |
| វើមីគូឡាយ | ៦,៨ | ៤៤,៤ | ០ | ៨៤ | ០,៣៦ | ៦,៧៦ | ១,៦៨ |
| កាកសំណល់រុក្ខជាតិ | ៣,៩ | ១០២,៥ | ៥៣,៤ | ១៨ | ០,១៩ | ១,៥២ | ១,៤១ |
| អង្កាម | ៤,៤ | ៤១,០ | ៤៨,៥ | ៦៤ | ០,៤១ | ២,១៨ | ០,២៥ |
| ខ្សាច់ | ៦,៨ | ១ | ០,១ | ១២ | ០,៦៥ | ០,៨៥ | ០,១៩ |
| សំឡីថ្ម | ៧,៥ | ០ | ០ | ០ | ១% | ២៣% | ៧% |
| សំឡីថ្មគីប | ៨,៥ | ០ | ០ | ០ | ១% | ២៣% | ៧% |
| ប៉េ | ៦,០ | ០ | ០ | ០ | ០,០០៣% | ០,០២៧% | ០,០០១% |
| ស្រកីដូង | ៥,៦ - ៦,៩ | ៤៣ - ៦០ | ៩០ | ២ | ០,៨ | ០,០៤ | ០,០២ |

### ៤.២.១ សំឡីថ្ម

- វាមានសមត្ថភាពទប់ទឹកបានល្អ ដោយសារតែការទប់ទឹកភាគច្រើនហើយមានរន្ធតូចៗច្រើន
- ការសាយភាយទឹកបានល្អ ធ្វើឱ្យគេអាចប្រើវាដើម្បីកែតម្រូវ និងរក្សាទឹកស្មើៗគ្នា សម្រាប់ការស្រោចស្រពជាដំណក់ទឹក
- វាមិនផ្លាស់ប្តូរជាសារធាតុរ៉ែទេ វាគ្មានការព្រួយបារម្ភអំពីជំងឺហើយវាជាទូទៅមានស្ថេរភាពស្មើៗគ្នា
- បន្ថយការចំណាយតាមរយៈលប់បំបាត់ផ្នែកនៃថ្នាលដាំ ឬស៊ីទែនទឹក ដែលប្រើប្រាស់សម្រាប់ ការដាំដុះប្រើប្រាស់ អ៊ីដ្រូប៉ូនិច
- វាជាការចាំបាច់ក្នុងការផ្គត់ផ្គង់សារធាតុរាវសម្រាប់ដាំដោយមិនបាច់ធ្វើឱ្យទឹកវិល ចុះវិលឡើង។



**រូបភាពទី៥០៖** សម្ភារសម្រាប់បង្កើតថ្មសំឡី

**៤.២.២ ស្រកីដូង**

- ស្រកីដូង៖ ស្រកីដូងកម្រាស់ ៥-៨ ស.ម នៃស្រទាប់ខាងក្រៅរបស់ផ្លែដូងទុំ
- ជាតិសរសៃនៅក្នុងស្រកីដូង ត្រូវបានគេផ្ដាច់ចេញពីគ្នាហើយគេប្រើជាវត្ថុធាតុដើម សម្រាប់ធ្វើខ្សែព្យួរ និងសម្ភារជូតជើង។ អនុផលនេះផ្សំឡើង ៦០% នៃកោសិកាវុក្ខជាតិហើយ ៤០%ផ្សំពីជាតិសរសៃខ្លីៗ ដែលគេហៅថា ជាតិសរសៃស្រកីដូង កម្ទេចកម្ទីស្រកីដូង និងកាកសំណល់ស្រកីដូង។
- ប្រទេសដែលផលិតស្រកីដូងរួមមានឥណ្ឌា ស្រីលង្កា ឥណ្ឌូនេស៊ី ហ្វីលីពីន វៀតណាម ម៉ាឡេស៊ី។
- បំណែកតូចៗភាគច្រើនមានទំហំ ០.១៥-២.០ មីលីម៉ែត្រ។
- ហើយ ប៉េហាស នៃសារធាតុចិញ្ចឹមដែលផ្សំពីស្រកីដូងមាន ៥.៥ ទៅ ៦.៦ ហើយកម្រិតសំណើមអាចស្រូបយកពី ៨ ទៅ១០ ដងនៃទំងន់ របស់សារធាតុចិញ្ចឹម។
- កម្រិតខ្ពស់របស់ប៉ូតាស្យូម និងក្លរីន(ក្លរ) នៅក្នុងល្បាយសារធាតុចិញ្ចឹម គឺដោយសារទឹកភ្លៀងសំបូរសារធាតុទាំងនេះនៅក្នុងទឹកសមុទ្រមុនវាដែលគេយកទៅកែច្នៃ។




**រូបភាពទី៥១៖** អនុផលស្រកីដូង

## ៤.២.៣ ប៉េលីត

- **ប៉េលីត** កើតឡើងដោយការធ្វើសីតុណ្ហភាពកំអែភ្នំភ្លើងស៊ីលីកា និងបរិមាណទឹកគ្រីស្តាល់២-៥%
- ត្បូងថ្មនេះត្រូវបានគេដុតនៅកម្តៅ ១០០០អង្សារយៈពេល៥-២០នាទី។ វាមានទម្ងន់ស្រាលហើយវាមានសមត្ថភាពស្រូបយក ៣-៤ដង
- មាន ប៉េហាស ៦.៨-៨.០ ត្រូវបានប្រើជាទូទៅផ្សំជាមួយដីកំប៉ុស






**រូបភាពទី៥២៖** ប៉េលីត

## ៤.២.៤ ដីខ្សាច់

- ដីខ្សាច់ត្រូវបានគេប្រើដោយមានអង្កត់ផ្ចិត ០.៥-២ មីលីម៉ែត្រ ហើយគេរកវាបាននៅក្នុងទន្លេ
- ប្រសិនបើ គេយកខ្សាច់ចេញពីតំបន់មាត់សមុទ្រ គេត្រូវលាងសំអាតខ្សាច់នៅក្នុងទឹក ដើម្បីសំអាតជាតិអំបិល និងរ៉ែ ខ្សាច់បាយអរចេញពីព្រោះវាស្តើងពេកដោយសារតែសមត្ថភាពខ្យល់ចេញចូលមានកម្រិតទាប
- ដីខ្សាច់ថ្មកំបោរ ទទួលរងការប្រែប្រួល pH យ៉ាងខ្លាំងហើយខ្សាច់ពណ៌ស អាចខ្វះខាតសារធាតុដែលមានសូលុយស្យុងទាប ដូច្នេះគេគួរពិចារណាពេលដែលជ្រើសរើសសារធាតុចិញ្ចឹម។





**រូបភាពទី៥៣៖** ដីខ្សាច់

## ៤.៣ ការគ្រប់គ្រងការស្រោចស្រព

### ៤.៣.១ ការផ្គត់ផ្គង់ និងការបង្ហូរសំងួត

- បង្កើនការលូតលាស់ដំណាំកាត់បន្ថយការបាត់បង់សារធាតុចិញ្ចឹមនិងត្រូវការត្រួតពិនិត្យកម្រិតទឹកដើម្បីបង្កើនគុណភាពទឹក
- វិធីសាស្ត្រធ្វើឱ្យទឹកវិល គួរតែពិចារណាពីបរិមាណទឹកនៅក្នុងថ្នាលបណ្តុះ និងកំហាប់សារធាតុចិញ្ចឹម។

o **វិធីសាស្ត្រគ្រប់គ្រងពេលវេលា**

- វិធីសាស្ត្រដែលសាមញ្ញ និងចំណាយតិចបំផុតគឺត្រូវកំណត់ដោយយោងទៅតាមលក្ខណៈប្រភេទសារធាតុចិញ្ចឹម លក្ខណៈលូតលាស់របស់ដំណាំ និងលក្ខណៈបរិស្ថាន។ ការកែតម្រូវនេះជាប្រចាំត្រូវចាំបាច់ជារៀងរាល់ថ្ងៃ ហើយក្នុងករណី ការប្រើប្រាស់ទឹក និងបរិមាណទឹកលើសជារឿយៗ គេសង្កេតឃើញមានកើតឡើង។

o **វិធីសាស្ត្រត្រួតពិនិត្យកាំរស្មីព្រះអាទិត្យចម្រុះ**

- ប្រើប្រាស់ឧបករណ៍វាស់ពន្លឺ, កំណត់ពីបរិមាណផ្គត់ផ្គង់ទឹក និងពេលវេលាផ្គត់ផ្គង់។ បរិមាណទឹកប្រើប្រាស់វាអាស្រ័យលើអត្រាលូតលាស់
- វាត្រូវបានគេប្រើប្រាស់ជាលក្ខណៈផ្គុំចូលគ្នាជាមួយម៉ោងកំណត់ពីព្រោះវាមានបញ្ហាខ្លះដូចជា កង្វះខាតសំណើមនៅពេលយប់ដែលដុះលូតលាស់លឿនហើយការផ្គត់ផ្គង់ទឹកពេលដែលវាមេឃស្រឡះ និងមានភ្លៀង។

o **វិធីសាស្ត្រត្រួតពិនិត្យដោយផ្ទាល់តាមរយៈការវាស់កម្រិតសំណើម**

**១. វិធីសាស្ត្រត្រួតពិនិត្យទម្ងន់**

- ត្រូវត្រួតពិនិត្យកម្រិតទឹកដោយការវាស់ទម្ងន់ថ្នាលដាំ ឬទម្ងន់សារធាតុរាវ បង្ហូរចេញពីថ្នាលដាំ។

**២. វិធីសាស្ត្រប្រើអេឡិចត្រូត**

- ប្រមែប្រមូលទឹកដែលបង្ហូរចេញដាក់នៅក្នុងធុងហើយដាក់ **អេឡិចត្រូត** នៅក្នុងទីតាំងណាមួយដើម្បីកំណត់ពីការចាប់ផ្តើមនិងបញ្ចប់នៃការផ្គត់ផ្គង់សារធាតុរាវ ឬពេលកម្រិតទឹកកើនឡើងដល់កម្រិតណាមួយទឹកដែលកើនឡើងហើយការកំណត់កម្រិតទឹកត្រូវធ្វើឡើងដោយម៉ោងកំណត់។






**រូបភាពទី៥៤៖** ការប្រើប្រាស់ អេឡិចត្រូត ដើម្បីគ្រប់គ្រងបរិមាណទឹក

### ៣. វិធីសាស្ត្រប្រើ សេនសឺសំណើម

- បរិមាណសំណើមគឺត្រូវវាស់និងត្រួតពិនិត្យដោយ**សេនសឺ**សំណើមនៅក្នុងសារធាតុចិញ្ចឹម

### ៤. ការការពារទុកជាមុន

- ទីតាំងដាក់ **សេនសឺ** ដោយការចែកចាយជាលក្ខណៈបញ្ឈរ។
- ការកម្រិតពេលម៉ោងណាមួយអាស្រ័យលើកម្រិតទឹក

### ៥. វិធីសាស្ត្រប្រើកុំព្យូទ័រ

- ពេលដែលវិធីសាស្ត្រផ្គត់ផ្គង់សារធាតុរាវដែលបានលើកឡើងខាងលើ គឺត្រូវបានគេលាយយ៉ាងសមរម្យដោយការប្រើប្រាស់កុំព្យូទ័រ ដែលធ្វើឱ្យប្រសិទ្ធភាពគ្រប់គ្រងការផ្គត់ផ្គង់កើនឡើង។

## ៤.៣.២ ការបកស្រាយទិន្នន័យ និងវិធីសាស្ត្រប្រើប្រាស់

- ដំណាំ៖ ភាពប្រែប្រួលរបស់ដំណាំចំពោះសំណើមត្រូវតែគ្រប់គ្រងឱ្យបានច្បាស់លាស់ ចំណែកឯដំណាំមិនប្រែប្រួល ចំពោះសំណើមអាចឱ្យគេគ្រប់គ្រងដោយមិនចំណាយច្រើនទេ
- វិធីសាស្ត្រដាំដុះ៖វាគ្រប់គ្រាន់ដើម្បីគ្រប់គ្រងវិធីសាស្ត្រប្រើប្រាស់ម៉ោងកំណត់នៅក្នុងដំណាំដែលគ្មានការបាត់បង់ការហូរចេញនិងសំណើមបន្តិចបន្តួចនៅក្នុងការដាំដុះប្រើប្រាស់ប្រព័ន្ធអ៊ីដ្រូប៉ូនិចទឹកវិល
- លទ្ធភាពដំណើរការរបស់អ្នកប្រើប្រាស់៖ វាគួរតែអាចឱ្យយល់គ្រប់គ្រាន់
- សេដ្ឋកិច្ច៖ គួរតែកំណត់ឱ្យច្បាស់លាស់ដោយយោងទៅតាមលក្ខខណ្ឌដីទៃទៀត។

**០ ការពិចារណាពេលដែលជ្រើសរើសការចំណាយ**

- តំបន់ពេលវេលាផ្គត់ផ្គង់ប្រចាំថ្ងៃ (ការចំណាយចាប់ផ្តើម និងបញ្ចប់), ចន្លោះពេលផ្គត់ផ្គង់បរិមាណផ្គត់ផ្គង់តែម្តងគួរត្រូវបានគេត្រួតពិនិត្យ។

- ចំណុចត្រួតពិនិត្យនៃកត្តាត្រួតពិនិត្យដែលរួមមានប្រភេទដំណាំ ពេលវេលានៃដាំដុះ, ដំណាក់កាលលូតលាស់, គោលបំណងអ្នកដាំ, ប្រភេទនិងបរិមាណសារធាតុចិញ្ចឹម, ប្រភេទប្រព័ន្ធ អ៊ីដ្រូប៉ូនិចរយៈពេលលូតលាស់ដំណាំ និងថ្លៃចំណាយលើការដំណើរការ។
- នៅពេលដែលការគ្រប់គ្រងការផ្គត់ផ្គង់ទឹកឈានដល់ការលូតលាស់អតិបរិមាល្អ គឺទាមទារតម្រូវការទឹកកាន់តែច្រើន។ ពេលដែលការស្រោចស្រពចាប់ផ្តើមកាន់តែលឿន ការបញ្ឈប់កាន់តែយឺតចន្លោះពេលផ្គត់ផ្គង់មានរយៈពេលខ្លីហើយបរិមាណគឺកើនឡើង។
- គេអាចផ្តល់អនុសាស្ត្រ ចំពោះសារធាតុចិញ្ចឹមដែលមានសមត្ថភាពទប់ទឹកបានខ្ពស់មានពេលផ្គត់ផ្គង់រយៈពេលខ្លីក្នុងមួយថ្ងៃ បរិមាណផ្គត់ផ្គង់កាន់តែច្រើនចន្លោះផ្គត់ផ្គង់កាន់តែយូរ។
- ចន្លោះផ្គត់ផ្គង់ និងបរិមាណផ្គត់ផ្គង់៖ គេសម្រេចចិត្តអាស្រ័យលើប្រភេទ និងសមត្ថភាពរបស់សារធាតុចិញ្ចឹម ដូច្នេះសារធាតុចិញ្ចឹមទាំងអស់អាចធ្វើបរិមាណជាមួយគ្នា គ្រប់ពេលចំណាយ។

## ៤.៤ សមាសធាតុសារធាតុចិញ្ចឹម និងការគ្រប់គ្រង

### ៤.៤.១ លក្ខណៈសារធាតុចិញ្ចឹម

- **លក្ខខណ្ឌសម្រាប់សារធាតុដាំដុះ**

- រួមមានសារធាតុអសរីរាង្គសំខាន់ៗ (ធាតុ ១៣ ក្នុងចំណោម ១៦ ធាតុ៦ មានបរិមាណច្រើន និងជាសារធាតុកម្រ)
- ជាសារធាតុរំលាយក្នុងទឹក
- អ៊ីយ៉ុងនីមួយៗមានកំហាប់សមស្រប ហើយកំហាប់អ៊ីយ៉ុងសរុប គឺសមស្រប។
- គ្មានអ៊ីយ៉ុងដែលធ្វើឱ្យមានគ្រោះថ្នាក់
- ប៉េហាស របស់សូលុយស្យុង ៥,៥-៦,៥
- ប្រើប្រាស់ជីដែលមានតម្លៃថោក
- កំហាប់ សមាមាត្រធាតុ អសរីរាង្គ និងការប្រែប្រួល ក្នុងកំឡុងពេលដាំដុះគួរតែមានកម្រិតិចតួច។

- **និយមន័យ**

- អាញ៉ុង៖ ជាអាតូមដែលមានបន្ទុកវិជ្ជមាន
- ទម្ងន់អាតូម៖ គឺជាម៉ាស់កាបូនស្មើ ១២ និងម៉ាស់នៃទម្ងន់អាតូម

- **ប្រភេទនៃការស្រូបយកសារធាតុចិញ្ចឹម**

**តារាងទី១១៖** ការស្រូបយកសារធាតុចិញ្ចឹម

| ធាតុសំខាន់ | ការស្រូបយក | ធាតុបន្ទាប់បន្សំ | ការស្រូប |
|---|---|---|---|
| N | $NO3^{-}$, $NH4^{+}$ | Fe | $Fe3^{+}$, $Fe2^{+}$ |
| P | $H2PO4^{-}$, $HPO42^{-}$ | Mn | $Mn2^{+}$ |
| K | $K^{+}$ | Zn | $Zn2^{+}$ |
| Ca | $Ca2^{+}$ | Cu | $Cu2^{+}$ |
| Mg | $Mg2^{+}$ | B | $H2BO3^{2-}$ |
| S | $SO4^{2-}$ | Mo | $MoO4^{2-}$ |

### ៤.៤.២ ទំនាក់ទំនងពិសេសរវាងធាតុ និងធាតុ

- **ប្រភេទជីប្រែសម្រាប់សមាសធាតុដាំ**

- សារធាតុរាវដែលមានកំហាប់ខ្ពស់ (១០០ដង) ត្រូវបានរៀបចំដោយការរំលាយសារធាតុរាវនៅស៊ីទែន ដោយប្រើប្រាស់ជី ពិសេសសម្រាប់ការដាំ អ៊ីដ្រូប៉ូនិច និងភ្នាក់ងារសារធាតុគីមី (ជីទោល) ដើម្បីផ្តាច់ពីអ៊ីយ៉ុងដែលរឹងនៅកំហាប់ខ្ពស់។
- Ca Vs $SO_4$, $HPO_4$, $H_2PO_4$
- Fe Vs $HPO_4$, $H_2PO_4$

- **ការគ្រប់គ្រងpH នៃប្រព័ន្ធឫសដំណាំ**

- ការធ្វើតេស្តគុណភាពទឹកដែលរួមមាន ប៉េហាស, អ៊ីស៊ី, អ៊ីយ៉ុងអសរីរាង្គ ការវិភាគលោហៈធ្ងន់
- ប៉េហាស ៥,៥-៦,៥ ហើយការស្រូបយកសារធាតុចិញ្ចឹមអសរីរាង្គទាំងអស់មានតុល្យភាព
- ពេលដែលកាចុងត្រូវបានស្រូបយកដោយសារធាតុចិញ្ចឹមពេលនោះ $H^+$ ត្រូវបានស្រូបយក ហើយពេលដែលអាញ៉ុងត្រូវបានស្រូបយកពេលនោះ វាបញ្ចេញ $OH^-$ ហើយpH ធ្វើការផ្លាស់ប្តូរ។

**តារាងទី១២៖** សមាសធាតុសារធាតុចិញ្ចឹម

| សារធាតុចិញ្ចឹម A | | សារធាតុចិញ្ចឹម B | |
|---|---|---|---|
| កាល់ស្យូមនីត្រាត | $Ca(NO_3)_2 \cdot 4H_2O$<br>$5[Ca(NO_3)_2 \cdot 2H_2O]NH_4NO_3$ | ប៉ូតាស្យូមនីត្រាត | $KNO_3$ |
| ប៉ូតាស្យូមនីត្រាត | $KNO_3$ | ប៉ូតាស្យូមផូស្វាត | $KH_2PO_4$ |
| ដែកឆេឡេត | Fe-EDTA, Fe-DTPA | អាម៉ូញ៉ូមផូស្វាត | $NH_4H_2PO_4$ |
| អាម៉ូនីញ៉ូមនីត្រាត | $NH_4NO_3$ | ម៉ាញ៉េស្យូមស៊ុលហ្វេត | $MgSO_4 \cdot 7H_2O$ |
| | | តាស្យូមស៊ុលហ្វេត | $K_2SO_4$ |
| | | សារធាតុកម្រ | B, Mn, Zn, Mo, Cu |

- **ប៉េហាស** pH (potential hydrogen)

- **ប៉េហាស** តំណាងឱ្យអាស៊ីតសូលុយស្យុង ដែលជាឡូការីតបញ្ច្រាស់ទៅ នឹងកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន ដែលមានវត្តមាននៅក្នុងសូលុយស្យុង (-log[$H^+$])
- អាស៊ីតផូស្វ័រិច និងអាស៊ីតនីទ្រិចត្រូវបានប្រើប្រាស់ដើម្បីបញ្ចុះតម្លៃ pH ហើយប៉ូតាស្យូមអ៊ីដ្រុកស៊ីតត្រូវបានប្រើប្រាស់ដើម្បីបង្កើនតម្លៃ **ប៉េហាស**
- **ប៉េហាស** រក្សាកំណើនក្នុងកំឡុងពេលការលូតលាស់សារធាតុចិញ្ចឹម
- ដោយសារតែ $NO_3$ ត្រូវបានស្រូបយក, $NH_4$ ត្រូវបានផ្គត់ផ្គង់ដើម្បីរារាំងការកើនឡើង
- មានការថយចុះតម្លៃ **ប៉េហាស** ក្នុងកំឡុងពេលបន្តពូជរបស់រុក្ខជាតិ

- ប៉ូតាស្យូម...។ល។ រារាំងការកើនឡើង ប៉ូតាស្យូមកាបូណាត
- គេគួរផ្គត់ផ្គង់ក្នុងទម្រង់ជាសមាសធាតុដោយសារតែវាកករឹងជាដែកអ៊ីដ្រុកស៊ីតពេល**ប៉េហាស**កើនឡើង
- ចំពោះទំហំសារធាតុចិញ្ចឹមរឹង ប្រើ $NH_4$-H និង $KHCO_3$ ដើម្បីឱ្យស៊ីគ្នាទៅនឹងលក្ខណៈ (ជាប់ចម្លង ជាមួយ **ប៉េហាស**) របស់សារធាតុចិញ្ចឹម។

# មេរៀនទី៥ បច្ចេកទេសដំណាំយកផ្លែ

## ៥.១ ដំណាំប៉េងប៉ោះ

### ៥.១.១ ប្រភព

- មានប្រភពពីដំបន់ទំនាប នៃប្រទេសអាមេរិចប៉េកខាងត្បូងហើយបានរីករាលដាលទៅដល់តំបន់អឺរ៉ុបមុនពេលដែលទ្វីបអាមេរិចត្រូវបានគេរកឃើញ
- ប៉េងប៉ោះស្ថិតនៅក្នុងគ្រួសារ *Solanacea* ដែលមានមែកស្រដៀងទៅនឹងមែកម្ទេសដែរ ។ ផ្ការបស់វាស្ថិននៅចន្លោះមែកនិងដើម។ ផ្ការបស់វាជាប្រភេទផ្កាទ្វេភេទ ដែលមានចាប់ពី ៥ទៅ៦ស្រទាប់។

### ៥.១. ២ លក្ខណៈសរីរ និងជីវសាស្ត្រ

**ក. ទំនាក់ទំនងរវាងការបន្តពូជ និងការលូតលាស់(*Vegetative and generative*)**

វាជាប្រភេទដំណាំ កូទីលេដូន ។ បន្ទាប់ពីវាដុះបានប្រហែលជា ៨ ទៅ៩សន្លឹក វាចាប់ផ្តើបចេញពន្លកផ្កា។ ការចេញផ្កាអស្រ័យទៅលើបរិស្ថានដាំដុះកូនសាបកូន។ជាទូទៅប៉េងប៉ោះចេញផ្កាក្នុងរយៈពេល ២៥ ទៅ៣០ថ្ងៃក្រោយសាបកូន។ ផ្កាប៉េងប៉ោស្ថិតនៅចន្លោះថ្នាំងស្លឹក។

















**រូបភាពទី៥៥៖** ការចេញផ្ការបស់ប៉េងប៉ោះចេញផ្កាបន្ទាប់ពី ៣០ ទៅ ៣៥ថ្ងៃ បន្ទាប់ពីសាប

**ខ. សីតុណ្ហភាព**

- ប៉េងប៉ោះជាដំណាំដុះលូតលាស់នៅតំបន់ក្ដៅបង្គួរ
- សីតុណ្ហភាពសមស្របសម្រាប់ដំណុះគ្រាប់ ២៥ ទៅ ៣០ អង្សារសេ
- សីតុណ្ហភាពសមស្របសម្រាប់ដុះលូតលាស់ ២៤ ទៅ ២៦ អង្សារសេ
- (ពេលថ្ងៃ) និង ១៨អង្សារសេ (ពេលយប់)
- សីតុណ្ហភាពខ្ពស់ពេក និងសំណើមខ្ពស់បណ្ដាលឲ្យផ្លែលូតលាស់មិនល្អ និងមិនកាន់ផ្លែ
- អាចដុះលូតលាស់នៅសីតុណ្ហភាពរហូតដល់ ៣៣ អង្សារសេ ប៉ុន្តែការលូតលាស់យឺតនៅសីតុណ្ហភាពក្រោម ១៣អង្សារសេ។

**គ.ពន្លឺ**

ដំណាំប៉េងប៉ោះចូលចិត្តពន្លឺជាងបន្លែដទៃទៀត។ សម្រាប់លក្ខ័ណ្ឌនៅក្នុងផ្ទះបៃតង វាមិនមានពន្លឺគ្រប់គ្រាន់សម្រាប់ប៉េងប៉ោះនៅរដូវត្រជាក់។ កាលណាពន្លឺមិនគ្រប់គ្រាន់វាធ្វើឱ្យត្បូនាទីរបស់លំអងឈ្មោលខ្សោយ។

**ឃ. ដី**

- ដីដែលល្អសម្រាប់ដំណាំប៉េងបោះគឺជាប្រភេទដីដែលសំបូរទៅដោយមមោកនៅស្រទាប់ខាងលើ និងផុសល្អងាយស្រួលក្នុងការភ្ជួរ ឬកាប់
- ជាដីដែលមិនដក់ទឹក ឬជាំទឹកក្នុងរយៈពេលយូរ
- ជាដីដែលមានសំណើម និងចាប់យកសារធាតុចិញ្ចឹមបានល្អ
- សំបូរទដោយអតិសុខុមប្រាណ
- មាន ប៉េហាស ចាប់ពី ៦.២ -៦.៤

**ង. សារធាតុចិញ្ចឹម**

នៅក្នុងប៉េងប៉ោះមានកាឡូរីទាប ប៉ុន្តែមានវីតាមីនអេ និងវីតាមីនសុីច្រើន រួមទាំងវីតាមីន ប៊ីផងដែរ។

**ច.បច្ចេកទេសដាំដុះ**

**ល្បាយបណ្ដុះកូន**

ជាប្រភេទល្បាយដែលសោះទឹកល្អ ខ្យល់ចេញចូលល្អ ផ្សំពីធាតុស្រាលៗ និងមិនមានមេរោគផ្សិត និងសត្វល្អិត ។ pH ៥.៨ ទៅ ៦ និង EC ០.៥ ទៅ ០.៨ dS·m$^{-1}$។ EC អាចដល់ ១.៥ dS·m$^{-1}$ ក្នុងករណីប្រើជីគីមី

**ស្រកីដូងម៉ដ្ឋ**

- ជក់ទឹកបានយូ
- ប៉េហាស & EC សមស្រប
- មានសមត្ថភាពចាប់យកសារធាតុចញ្ចឹមបានល្អ
- មិនជាំទឹក និងខ្យល់ចេញចូលបានល្អ
- ទំងន់ស្រាល
- ជួយឲ្យឫសលូតលាស់បានល្អ
- ពេលវេលា វិធីសាស្ត្របណ្តុះកូនប៉េងប៉ោះ
- ត្រូវដឹងពីពេលវេលាដែលត្រូវដាំដុះ
- កូនប៉េងប៉ោះត្រូវបណ្តុះ ២៥ ទៅ ៣០ថ្ងៃមុនពេលយកទៅដាំ
- ត្រាំគ្រាប់ក្នុងទឹក (២៥ ទៅ៣០អង្សារសេ) រយះពេល១៥ ទៅ២០ម៉ោង
- បន្ទាប់មករក្សាគ្រាប់ដែលបានត្រាំនៅសីតុណ្ហភាព ៣០អង្សារសេ រយះពេល១ ទៅ២ ថ្ងៃ
- បន្ទាប់មកទៀតយកគ្រាប់ទៅសាបក្នុងត្រេបណ្តុះដែលមានល្បាយបណ្តុះ

**ឆ. ការស្រោចស្រព និងសារធាតុចញ្ចឹម**

- ការស្រោចសស្រពគឺប្រើប្រាស់ប្រព័ន្ធតំណក់
- ដែលការផ្តល់សារធាតុចញ្ចឹមក៏តាមរយៈប្រព័ន្ធនេះដែរ
- សារធាតុចញ្ចឹមដែលផ្តល់ឲ្យរុក្ខជាតិរួមមាន

| ប្រភេទជី | ចំនួន | ជីទ្រាប់បាត | ការបំប៉នសារធាតុចិញ្ចឹម | | | |
|---|---|---|---|---|---|---|
| | | | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ |
| ជីកំប៉ុស្ត | ២៥០០ | ២៥០០ | - | - | | - |
| ជីអ៊ុយរ៉េ | ៤៥ | ២៥ | ៥ | ៥ | ៥ | ៥ |
| ជីផូស្វាត(P) | ៥២ | ៥២ | - | - | - | - |
| ជីប៉ូតាស្យូម(K) | ២៤ | ១២ | ៤ | ៤ | 4 | |

**ជ.ការតាង់តែងមែក**

- ប៉េងប៉ោះជាដំណាំស្វ័យដំណើរលំអង
- ដើម្បីបង្កើនចំនួនផ្លែ យើងអាចប្រើ ប៉ូតាស្យូម ជីDPA 0.15% បាញ់ផ្កានៅពេលមានផ្កាបើក ០២ ទៅ០៣ ផ្កានៅក្នុងមួយចង្កោមផ្កា
- កាត់ខ្នែងដុះចេញទាំងអស់ ដោយទុកតែខ្នែងនៅខាងក្រោមចង្កោមផ្លែដំបូងគេ ដើម្បីរក្សាម្លប់ឲ្យផ្លែ
- រក្សាចង្កោមផ្លែក ៥ ទៅ១០ចង្កោមក្នុងមួយដើម
- នៅក្នុងចង្កោមនីមួយៗរក្សាផ្លែតែ៤ ទៅ ៥ផ្លែ ដែលមានទំហំប្រហាក់ប្រហែលគ្នា
- បេះចោលផ្លែណាដែលមានទំហំតូច

### ៥.១.៣ ភាពមិនប្រក្រតី ជម្ងឺ និងសត្វល្អិត

